The NGO Forum on Cambodia
Working Together for Positive Change

Adaptation Fund NGO Network

GERMANWATCH

DCA actalliance

Southern Voices on Climate Change



# ការឃ្លាំមើលមូលនិធិបន្សាំ និងផែនការបន្សាំជាតិ




ប្រភព៖ ក្រសួងបរិស្ថាន










ភ្នំពេញ ប្រទេសកម្ពុជា
ខែវិច្ឆិកា ឆ្នាំ២០១៦

**ការឃ្លាំមើលមូលនិធិបន្សាំ និងផែនការបន្សាំជាតិ**

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែវិច្ឆិកា ឆ្នាំ២០១៦
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីបរិស្ថាន, គម្រោងតាមដានគោលនយោបាយការប្រែប្រួលអាកាសធាតុ

ស្រាវជ្រាវដោយ៖ លោក ឡុង សូណា, ទីប្រឹក្សាឯករាជ្យ
រចនាអត្ថបទដោយ៖ លោក ភួន យូ អ្នកសម្របសម្រួលប្រព័ន្ធព័ត៌មាន និងទំនាក់ទំនង

## សេចក្តីបញ្ជាក់៖

ទស្សនៈបង្ហាញក្នុងរបាយកាណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈផ្ទាល់របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, Dan Church Aid (DCA), Germanwatch, និង Southern Voices នោះទេ។ នៅពេល ដែលខ្លឹមសារនៃរបាយការណ៍នេះត្រូវបានដកស្រង់ ឬ ផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតិពីអ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវបានឱ្យតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា, ខែវិច្ឆិកា ឆ្នាំ ២០១៦**

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមសម្តែងនូវការកោតសរសើរចំពោះការចូលរួមចំណែករបស់អ្នកពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវនេះ ដូចជាអ្នកដែលបានផ្តល់បទសម្ភាសន៍ រួមមានមន្ត្រីរាជរដ្ឋាភិបាល ម្ចាស់ជំនួយ អង្គការជាតិ និងអន្តរជាតិ និងអ្នកជំនាញការ សម្រាប់ការផ្តល់ពេលវេលាដ៏មានតម្លៃក្នុងអំឡុងពេលសម្ភាសន៍ និងអ្នកចូលរួមទាំងអស់ក្នុងសិក្ខាសាលាពិគ្រោះយោបល់ដែលបានផ្តល់ជាធាតុចូលក្នុងរបាយការណ៍នេះ។

អ្នកនិពន្ធសូមថ្លែងអំណរគុណ និងសំដែងការកោតសរសើរដល់ការគាំទ្រ និងកិច្ចសហការពីថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលមានដូចជា លោកបណ្ឌិត តឹក វណ្ណារ៉ា លោក អ៊ុក វណ្ណារ៉ា លោក សី ពៅ និង លោក ភាព សុភា ដែលបានផ្តល់ការណែនាំនៅក្នុងកំឡុងពេលអនុវត្តគម្រោង និងផ្តល់ជាតុចូលយ៉ាងសំខាន់ដើម្បីរៀបចំសកម្មភាពស្រាវជ្រាវ។

## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាបណ្តាញនៃអង្គការជាតិ និងអន្តរជាតិ ដែលធ្វើការលើភាពយុត្តិធម៌នៃសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព។ អង្គការនេះជំរុញឱ្យមានការជជែកពិភាក្សា និងការតស៊ូមតិ ដើម្បីសិទ្ធិប្រជាពលរដ្ឋ និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តក្នុងការអភិវឌ្ឍ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.ngoforum.org.kh

## សម្រាប់ព័ត៌មានបន្ថែម


**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

ផ្ទះលេខ ០៩-១០ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូងទី១

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (៨៥៥) ២៣ ២១៤ ៤២៩

លេខទូរសារ៖ (៨៥៥) ៩៩៤ ០៦៣

អ៊ីម៉ែល៖ngoforum@ ngoforum.org.kh

គេហទំព័រ៖ www.ngoforum.org.kh

# មាតិកា


សេចក្តីសង្ខេប ........ vi
និយមន័យ ........ x
១. សាវតា ........ ១
២. គោលបំណងនៃការសិក្សា ........ ៣
៣. វិធីសាស្ត្រ ........ ៤
៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ ៥
៥. ទិដ្ឋភាពទូទៅនៃមូលនិធិការប្រែប្រួលអាកាសធាតុ ........ ៥
 ៥.១ មូលនិធិការប្រែប្រួលអាកាសធាតុសកល ........ ៥
 ៥.២ មូលនិធិវិនិយោគលើការប្រែប្រួលអាកាសធាតុ (CIF) ........ ៦
 ៥.៣ មូលនិធិបន្សាំ ........ ៧
 ៥.៤ សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល (GCCA) ........ ៨
 ៥.៥ មូលនិធិអាកាសធាតុបៃតង (GCF) ........ ៩
៦. របបគំហើញនៃការសិក្សាស្រាវជ្រាវ ........ ១១
 ៦.១ យន្តការហិរញ្ញប្បទានអាកាសធាតុ ........ ១១
 ៦.២ មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពបន្សាំនៅលើពិភពលោក . ១២
 ៦.៣ មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងពិភពលោក ........ ១៦
៧. ដំណើរការត្រៀមផែនការជាតិបន្សាំការប្រែប្រួលអាកាសធាតុ ........ ១៨
 ៧.១ ផែនការរដ្ឋាភិបាល និងគោលនយោបាយឆ្លើយតបការប្រែប្រួលអាកាសធាតុ.. ១៨
 ៧.២ ក្របខណ្ឌស្ថាប័នសម្រាប់ការប្រែប្រួលអាកាសធាតុ ........ ២០
៨. ការអនុវត្តផែនការជាតិបន្សាំក្នុងប្រទេសកម្ពុជា ........ ២៣
 ៨.១ ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការដាក់បញ្ចូលសម្រាប់ដំណើរការរៀបចំគម្រោងបន្សាំ ........ ២៣
 ៨.២ ដំណើរការប្រកបដោយប្រសិទ្ធភាពនៃការប្រើប្រាស់មូនិធិបន្សាំ និងការទទួលបានជាសាធារណៈ ........ ២៣
 ៨.៣ ដំណើរការផែនការបន្សាំកម្រិតមូលដ្ឋាន និងការចូលរួមពីសហគមន៍ងាយរងគ្រោះ ........ ២៣

៩. ស្ថានភាពមូលនិធិបន្សាំនៅក្នុងប្រទេសកម្ពុជា ........................................ ២៥
៩.១ ហិរញ្ញប្បទានអាកាសធាតុក្នុងប្រទេសកម្ពុជា ........................................ ២៥
៩.២ ប្រភពមូលនិធិ ........................................ ២៧
៩.៣ គម្រោងបន្សាំ និងគម្រោងកាត់បន្ថយ ........................................ ២៧
៩.៤ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ ........................................ ២៩
១០. គម្រោងមូនិធិបន្សាំនៅក្នុងប្រទេសកម្ពុជា ........................................ ៣០
១១. ទំនាក់ទំនងជាមួយនឹងផែនការជាតិបន្សាំ ........................................ ៣២
១១.១ ភាពបន្សុីគ្នាទៅនឹងកម្រិតជាតិ ........................................ ៣២
១១.២ ភាពបន្សុីគ្នាទៅនឹងផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ ........................................ ៣២
១១.៣ ទំនាក់ទំនងរវាង CCAPs និង INDCs ........................................ ៣៤
១២. បរិយាកាសអំណោយផលផ្នែកការគាំទ្របរិស្ថាន និងរដ្ឋាភិបាលសម្រាប់ដំណើរការបន្សាំជាតិ ........................................ ៣៧
១២.១ កង្វះចន្លោះនៃការរៀបចំ NAP នៅកម្ពុជា ........................................ ៤០
១២.២ ការគៀងគរធនធានសម្រាប់សកម្មភាពបន្សាំ ........................................ ៤១
ករណីសិក្សា ........................................ ៤១
ករណីសិក្សាទី១៖ លើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ជនបទរស់នៅក្នុងតំបន់ការពារនៃប្រទេសកម្ពុជា ........................................ ៤១
ករណីសិក្សាទី២៖ អភិបាលកិច្ចមូលដ្ឋាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ .. ៤៤
ករណីសិក្សាទី៣៖ បច្ចេកវិទ្យាកសិកម្មសមស្របត្រូវបានអនុវត្តន៍សាកល្បងនៅក្នុងខេត្តព្រៃវែង ........................................ ៤៧
១៣. សេចក្តីសន្និដ្ឋាន ........................................ ៤៨
១៤. អនុសាសន៍ ........................................ ៤៨
ឯកសារយោង ........................................ ៥១

# អក្សរកាត់ និងពាក្យចំរួញ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CBA | ការវិភាគថ្លៃចំណាយ និងផលចំណេញ |
| CBD | អនុសញ្ញាស្តីពីជីវៈចម្រុះ |
| CCAP | ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ |
| CCCA | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCA-TFS | លេខាធិការដ្ឋានមូលនិធិកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា |
| CDC/CRDB | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDP | ផែនការអភិវឌ្ឍន៍ឃុំ |
| CPEIR | ការពិនិត្យលើការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ និងការរៀបចំស្ថាប័ន |
| CCSAP | យុទ្ធសាស្ត្រ និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ |
| CSOs | អង្គការសង្គមស៊ីវិល |
| CI | អង្គការអភិរក្សអន្តរជាតិ |
| DCC | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| EU | សហភាពអឺរ៉ុប |
| EFI | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| GSSD | អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. |
| GEF | មូលនិធិបរិស្ថានសាកលលោក |
| IIED | វិទ្យាស្ថានអន្តរជាតិដើម្បីបរិស្ថាន និងអភិវឌ្ឍន៍ |
| INC | របាយការណ៍ជាតិលើកទី១ |
| INDC | ការចូលរួមចំណែករបស់ជាតិក្នុងការអនុវត្តអនុសញ្ញា UNFCCC |
| IUCN | សហព័ន្ធអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| KAP | ឥរិយាបទនៃការអនុវត្តចំណេះដឹង |
| LDCF | មូលនិធិសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| M&E | ការតាមដាន និងវាយតម្លៃ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoE | ក្រសួងបរិស្ថាន |

| | |
|---|---|
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MoRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MoT | ក្រសួងទេសចរណ៍ |
| MoInf | ក្រសួងព័ត៌មាន |
| MOWA | ក្រសួងកិច្ចការនារី |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MLMUPC | ក្រសួងគ្រប់គ្រងដែនដី រូបនីយកម្ម និងសំណង់ |
| MRC | គណៈកម្មការទន្លេមេគង្គ |
| NAPA | កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NAP | ផែនការជាតិបន្សាំ |
| NCCC | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុជាតិ |
| NCDD-S | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| POC | ចំណាយប្រតិបត្តិការអាទិភាព |
| POPs | អនុសញ្ញាស្តុកខុមស្តីពីសារធាតុពុលមិនងាយបំបែកធាតុ |
| PPCR | កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ |
| PSB | ក្រុមប្រឹក្សាភិបាលគាំទ្រកម្មវិធី |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| REDD+ | ការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងសឹករិចរិលនៃព្រៃឈើ |
| SNAs | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNC | របាយការណ៍ជាតិលើកទី២ |
| SNIF | មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ |
| SBSTA | ក្រុមការងារបំពេញបន្ថែមសម្រាប់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា |
| UN | អង្គការសហប្រជាជាតិ |
| UNCBD | អនុសញ្ញាសហប្រជាជាតិសម្រាប់ជីវៈចម្រុះ |
| UNCCD | អនុសញ្ញាសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងឱនភាព |

| | |
|---|---|
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFCCC | អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNEP | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNITAR | វិទ្យាស្ថានសហប្រជាជាតិសម្រាប់ការបណ្តុះបណ្តាល និងស្រាវជ្រាវ |
| WOMEN | អង្គការស្ត្រីសម្រាប់សេដ្ឋកិច្ចទំនើប និង គិលានុបដ្ឋ |

# សេចក្តីសង្ខេប

កម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេស ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ និងជាប្រទេសមួយក្នុងចំណោមប្រទេសចំនួនបី ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុនៅអាស៊ី[1] ដោយសារតែប្រទេសនេះ ជាញឹកញាប់បានរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ របបទឹកភ្លៀងមិនទៀងទាត់ ទទួលឥទ្ធិពលព្យុះត្រូពិច ព្រមទាំងការកើនឡើងនៃកម្ពស់ទឹកសមុទ្រ ប៉ុន្តែប្រទេសកម្ពុជាមានសមត្ថភាពបន្សុាំទាបនៅឡើយ[2]។ ការវាយតម្លៃភាពពីភាពងាយរងគ្រោះថ្មីមួយបានរកឃើញថា ១៧,២% នៃចំនួនឃុំទាំងអស់ត្រូវបានរកឃើញថាមានកម្រិតនៃភាពងាយរងគ្រោះខ្ពស់ និង ៣១,៥% មានកម្រិតភាពងាយរងគ្រោះបង្គួរ ទៅនឹងគ្រោះថ្នាក់នៃការប្រែប្រួលអាកាសធាតុច្រើនផ្សេងៗគ្នា ដែលមានដូចជាទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត[3]។ នៅក្រោមក្របខណ្ឌនៃអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ មានមូលនិធិសកលដែលអាចប្រើបានដូចជា មូលនិធិបរិស្ថានពិភពលោក មូលនិធិវិនិយោគអាកាសធាតុ (CIF) មូលនិធិបន្សុាំ, សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុសកល(GCCA), មូលនិធិអាកាសធាតុបៃតង។ យន្តការមូលនិធិទាំងនោះត្រូវបានបង្កើតឡើងនៅក្នុងបំណង និងប្រធានបទផ្សេងគ្នា ដើម្បីគាំទ្រដល់ប្រទេស ដែលមានការអភិវឌ្ឍតិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា។

ការសិក្សាស្រាវជ្រាវបានបង្ហាញថា យន្តការហិរញ្ញវត្ថុ គឺត្រូវបានបញ្ជូនតាមរយៈមូលនិធិពហុភាគីដូចជាស្ថាប័នសម្របសម្រួលបរិស្ថាន សកល និងមូលនិធិវិនិយោគលើអាកាសធាតុ ព្រមទាំងការកើនឡើងតាមរយៈបណ្តាញទ្វេភាគី។ លើសពីនេះទៀត ការកើនឡើងនៃចំនួន បណ្តាប្រទេសដែលទទួលមូលនិធិត្រូវបានរៀបចំឡើងជាមូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ ដែលទទួលមូលនិធិពីប្រទេសអភិវឌ្ឍន៍ជាច្រើន ដែលខិតខំប្រឹងប្រែងសម្របសម្រួល និងបន្សីចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយជាមួយនឹងអាទិភាពថ្នាក់ជាតិ។ ការចំណាយសម្រាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងចន្លោះពី ២៨-៦៧ ពាន់លានដុល្លារអាមេរិកនៅក្នុងមួយឆ្នាំ នៅក្រោមក្របខ័ណ្ឌ UNFCCC រហូតដល់ឆ្នាំ ២០៣០ នៅពេលដែលមូលនិធិសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ហើយមូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុពិសេស នឹងត្រូវបានផ្តល់មូលនិធិច្រើនបំផុតសម្រាប់ការបន្សុាំ។

ការចំណាយសម្រាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានច្រើន ដោយប្រទេសអភិវឌ្ឍន៍មានការប្តេជ្ញាចិត្តក្នុងការបង្កើនការគាំទ្រសម្រាប់ការបន្សុាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍តិចតួច និង ប្រទេសកំពុងអភិវឌ្ឍន៍តំបន់កោះតូច ដែលមានការទទួលខុសត្រូវតិចតួចនៅក្នុងប្រវត្តិសាស្ត្រ និងទទួលការចំណាយទាំងឡាយដែលពាក់ព័ន្ធនឹងការ

[1] ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុនៅកម្ពុជា, NCSD, សីហា ២០១៥
[2] ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុនៅកម្ពុជា (ពង្រាង២០១៤)
[3] ក្របខ័ណ្ឌនៃការត្រួតពិនិត្យនិងការវាយតម្លៃលើការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា, NCSD, មេសា ២០១៦

ប្រែប្រួលអាកាសធាតុ។ ទិន្នន័យរបស់ CFU បានស្នើថាប្រទេសអភិវឌ្ឍន៍បានសន្យានឹងបន្ថែម ៣ពាន់លានដុល្លារអាមេរិកទៀតលើមូលនិធិសម្រាប់ការបន្សាំពហុភាគី។ ប្រភពដ៏ធំបំផុតនៃមូលនិធិដែលត្រូវបានអនុម័តរួចសម្រាប់គម្រោងនៃការបន្សាំនាពេលបច្ចុប្បន្ននេះ គឺជាកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) នៃមូលនិធិវិនិយោគលើអាកាសធាតុរបស់ធនាគារពិភពលោក និងមូលនិធិសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍តិចតួច (LDCF) ដែលគ្រប់គ្រងដោយស្ថាប័នសម្របសម្រួលបរិស្ថានសកល។ មូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុពិសេស (SCCF) និងមូលនិធិសម្រាប់ការបន្សាំ (AF) ក៏មានការកើនឡើងនូវមូលនិធិសម្រាប់ការបន្សាំផងដែរកាលពីឆ្នាំមុន។ ការផ្ដួចផ្ដើមនៃការបន្សាំថ្មី និងធំមួយ គឺជាការផ្ដួចផ្ដើមដែលមានទឹកប្រាក់ ៣៥៣ លានដុល្លារអាមេរិកសម្រាប់កម្មវិធីកសិកម្មខ្នាតតូច (ASAP) ក្រោមមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) ។

តម្រូវការក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងមួយឆ្នាំៗ ជាពិសេសដូចជាការរីកចម្រើនក្នុងការកាត់បន្ថយការបំភាយឧស្ម័នមានភាពយឺតយ៉ាវ។ មូលនិធិអាកាសធាតុដើរតួយ៉ាងសំខាន់នៅក្នុងការជួយប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការធ្វើឱ្យមានការផ្លាស់ប្ដូរទៅជាប្រព័ន្ធ ដែលជានានិរន្តរភាពបរិស្ថានកាន់តែច្រើនចំពោះការផលិតថាមពល និងការប្រើប្រាស់ ស្របពេលដែលការដោះស្រាយអាទិភាពនៃការអភិវឌ្ឍនៃសុវត្ថិភាពថាមពល និងកង្វះថាមពល។ ប្រភពហិរញ្ញវត្ថុសាធារណៈធំបំផុតសម្រាប់ការបង្ការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺមូលនិធិបច្ចេកវិទ្យាស្អាតរបស់ធនាគារពិភពលោក និងបរិស្ថានសកល ខណៈពេលដែលមូលនិធិថាមពលកកើតឡើងវិញ និងប្រសិទ្ធិភាពថាមពលសកលរបស់សហគមន៍អឺរ៉ុប (GEEREF) និងធនាគារពិភពលោកបានកំពុងតែបង្កើនកម្មវិធីថាមពលកកើតឡើងវិញ (SREP) បានផ្ដល់ហិរញ្ញប្បទានបង្ការដល់គម្រោងខ្នាតតូច។ ចាប់តាំងពីឆ្នាំ ២០០៨ មក ៥៣% នៃមូលនិធិអាកាសធាតុបានផ្ដល់ការគាំទ្រដល់សកម្មភាពបង្ការនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់រហ័ស ក្នុងគោលបំណងអភិវឌ្ឍន៍បច្ចេកវិទ្យាថាមពលកកើតឡើងវិញ។ ហើយមូលនិធិបង្ការការសាយភាយឧស្ម័នបានកើនឡើងកាលពីឆ្នាំមុនពី ៥.៧២ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៣ ដល់ ៦.៦៣ ពាន់លានដុល្លាររហូតដល់ខែតុលា ឆ្នាំ២០១៤។

កម្ពុជាបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការបន្សាំ តាមរយៈការអភិវឌ្ឍ និងការពង្រឹងស្ថាប័ន ដោយបង្កើតជាក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព រួមសមាសភាពរួមមាន រដ្ឋលេខា និងអនុរដ្ឋលេខាធិការជាសមាជិក ដែលមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣ រួមទាំងផែនការអនុវត្តសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុទៅតាមវិស័យ និងក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) គឺជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ

តាមរយៈការពង្រឹងសមត្ថភាពទាក់ទងនឹងការបន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅឆ្នាំ២០១៤ ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ២០១៤-២០២៣ និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង២០១៣-២០៣០ ត្រូវបានអនុម័ត។ ក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុបានបង្កើតឡើង ដើម្បីរៀបចំរចនាសម្ព័ន្ធនៃការរៀបចំថវិកា ខណៈពេលដែលផែនទីបង្ហាញផ្លូវរបស់របស់ការបន្សាំជាតិបាននឹងកំពុងពិភាក្សា និងរៀបចំ។ ផែនការអនុវត្តការប្រែប្រួលអាកាសធាតុទៅតាមវិស័យបានអនុម័តដោយក្រសួងវិស័យ និងភ្នាក់ងារផ្សេងៗរួចមកហើយ។ គម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ បានកំពុងរៀបចំ និងអនុវត្តន៍ជាបន្តបន្ទាប់ ដោយមានការចូលរួមពីក្រសួងនានា អង្គការសង្គមស៊ីវិល ដូចជា WWF, World Vision, WCS, IUCN, CDRI, MRC, FFI, WA, NTFP, RECOFT, ។ល។ នៅឆ្នាំ២០១៥ ទិន្នន័យហិរញ្ញប្បទាន ODA របស់ការប្រែប្រួលអាកាសធាតុមានចំនួន ៧,១លានដុល្លារ ដែលកើនឡើង ១៤,៥% ប្រៀបនឹងឆ្នាំ២០១៤ ខណៈពេលដែលថវិកាគាំទ្រការបញ្ជ្រាបការប្រែប្រួលអាកាសធាតុបានធ្លាក់ចុះ ១៥% ពី ១៥៩,៥លានដុល្លារនៅឆ្នាំ២០១៤។ វិស័យកសិកម្ម សាធារណការ និងដឹកជញ្ជូន និងបរិស្ថាន គឺជាវិស័យនៃការគាំទ្រការបញ្ជ្រាបការប្រែប្រួលអាកាសធាតុធំជាងគេ ដែលមានថវិកាប្រមាណ ១០០លានដុល្លារ ស្មើនឹង៧០% នៃថវិកាគាំទ្រការបញ្ជ្រាបការប្រែប្រួលអាកាសធាតុសរុប។

ឆ្លើយតបទៅនឹងតម្រូវការ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព បានសហការជាមួយ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការកែសម្រួលកាតកត់ត្រាទិន្នន័យ ODA ដើម្បីតាមដានលំហូរហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ។ យោងតាមទិន្នន័យ ODA អេឡិចត្រូនិចចន្លោះឆ្នាំ២០០៩-២០១៤ បានបង្ហាញថាមូលនិធិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានកត់ត្រា ហើយយោងតាមការវិភាគបង្ហាញថាវិស័យបន្សាំមានប្រមាណ ៧៦៧លានដុល្លារ ខណៈពេលដែលវិស័យត្រៀមបង្ការមានប្រមាណ ៣២លានដុល្លារ។ ថវិកាចំណាយការប្រែប្រួលអាកាសធាតុបានកើនឡើងពី ០,៩% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០០៩ ទៅ ១,៣% ( ៨៤៧ ពាន់លានរៀល) ក្នុងឆ្នាំ២០១៤។ នេះមិនមែនគ្រាន់តែជាលទ្ធផលនៃការកើនឡើងការគាំទ្រពីខាងក្រៅទេ ប៉ុន្តែជាក៏ជាកាកើនឡើងនៃការវិភាជថវិកាបស់រាជរដ្ឋាភិបាល ដែលបច្ចុប្បន្នមានប្រហាក់ប្រហែល ២៥% នៃការចំណាយសាធារណៈរបស់រដ្ឋទាក់ទងនឹងការប្រែប្រួលអាកាសធាតុ (២១១ ពាន់លានរៀល)។

ជាទូទៅការពិនិត្យ និងវិភាគបានបង្ហាញថា វាជាការកាត់តម្រឹមដ៏ល្អចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចជាផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ ផែនការអនុវត្តការប្រែប្រួលអាកាសធាតុទៅតាមវិស័យ និងផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញា UNFCCC (INDC) ដូចដែលបានបរិយាយនៅផ្នែកខាងក្រោម។ ការអនុម័ត ១៥ CCAPs [4] រួមមាន ១៧១ សកម្មភាពដែលតម្រូវការមានច្រើនជាង ៨៦៥,៤៧លានដុល្លារ ដើម្បីអនុវត្តន៍ក្នុងឆ្នាំ២០១៤-២០១៨។

---

[4] MAFF, MIH, MLMUPC, MME, MOE, MOEYS, MOH, MOINFO, MOT, MOWA, MOWRAM, MPWT, MRD, NCDM, and MPTC (not yet approved)

ថ្មីៗនេះកិច្ចការទាំងនេះ បានអនុវត្តដោយកម្មវិធីត្រៀមខ្លួនរួចជាស្រេចសម្រាប់ហិរញ្ញប្បទានអាកាសធាតុរបស់អង្គការ GIZ ដែលបានវាយតម្លៃចំណុចចន្លោះប្រហោងផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការសកម្មភាពប្រែប្រួលអាកាសធាតុ និងបានបង្ហាញថាមានកង្វះខាតថវិកាប្រមាណ៧១,៦៨% នៃការប៉ាន់ប្រមាណសរុប។

តាមរយៈវិសាលភាពនៃការស្រាវជ្រាវ ទៅលើការតាមដានមូលនិធិបន្សាំ និងមូលនិធិជាតិសម្រាប់ការបន្សាំ អនុសាសន៍ជាច្រើនត្រូវបានផ្តល់ដូចខាងក្រោម៖

1. ការពង្រឹងសមត្ថភាពស្ថាប័នក្រសួងបរិស្ថាន និងក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព ដើម្បីធ្វើអោយប្រសើរឡើងនូវការសម្របសម្រួលមូលនិធិដែលទាក់ទងទៅនឹងផែនការជាតិបន្សាំ រួមបញ្ចូលទាំងការវាយតម្លៃសំណើរមូលនិធិអាកាសធាតុបៃតង (GCF)។
2. ព្រងឹងសមត្ថភាពក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុក្នុងការតាមដាន និងវាយតម្លៃឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើសេដ្ឋកិច្ច ហើយនឹងប្រើប្រាស់សមត្ថភាពនោះក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈដំណើរការនៃថវិកាជាតិ។
3. ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងថវិកាជាតិ
4. ការផ្លាស់ប្តូរ និងការកែតម្រូវទិន្នន័យ ODA លើមូលនិធិបន្សាំ
5. ផ្តល់ហិរញ្ញវត្ថុទាក់ទងនឹងការប្រែប្រួលអាកាសធាតុបន្ថែម ស្របតាមការប្តេជ្ញាចិត្តរបស់ UNFCCC ប៉ុន្តែត្រូវធានាថាទិន្នន័យគម្រោង ODA គឺ "កម្មវិធីវៃឆ្លាតខាងអាកាសធាតុ"
6. សម្រាប់គម្រោងដែលបានកំណត់ថាពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវធានាថានៅក្នុងដំណាក់កាលបង្កើតគម្រោងគួរមានការផ្តល់ធាតុចូលពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពពីក្រុមការងារការប្រែប្រួលអាកាសធាតុរបស់ក្រសួង រួមបញ្ចូលទាំងបទដ្ឋាន ចំណាយ និងធាតុចូលផ្សេងៗ
7. ការគាំទ្រតាមវិស័យ ឬ ថវិកាគាំទ្រទូទៅត្រូវរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងក្របខ័ណ្ឌលទ្ធផល (ស្របតាមផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) និងក្របខ័ណ្ឌការតាមដាន និងវាយតម្លៃសម្រាប់គម្រោងការប្រែប្រួលអាកាសធាតុ) ព្រមទាំងផ្តល់នូវហិរញ្ញវត្ថុអាកាសធាតុ ដើម្បីគាំទ្រទៅដល់គោលបំនងទាំងនេះ
8. បង្កើនថវិកាសម្រាប់ការប្រែប្រួលអាកាសធាតុទៅដល់ថ្នាក់មូលដ្ឋានតាមរយៈ CSF, DMF និង SNIF, ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងនីតិវិធីនៃការធ្វើផែនការ និងថវិកាសម្រាប់គម្រោងទាំងនេះ
9. បញ្ចូលការគាំទ្រការអភិវឌ្ឍសមត្ថភាព និងការអន្តរាគមន៍ទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ ដល់មន្ត្រី និងស្ថាប័ន (កំនត់បទដ្ឋាន ក្បួនច្បាប់ នីតិវិធី ការស្រាវជ្រាវ និងការអភិវឌ្ឍ)។

# និយមន័យ

| | |
|---|---|
| ការបន្សាំ | ជាដំណើរការនៃការកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន និងការព្យាករណ៍ការប្រែប្រួលអាកាសធាតុនៅពេលអនាគត។ នៅក្នុងប្រព័ន្ធរបស់មនុស្ស ការបន្សាំមានន័យថាជាការស្វែងរកការទទួលយកបាននូវគ្រោះភ័យ ឬទាញយកឱកាសដែលមានប្រយោជន៍។ នៅក្នុងប្រព័ន្ធធម្មជាតិ ការអន្តរាគមន៍របស់មនុស្សអាចជួយសម្រួលដល់ការរំពឹងទុក និងផលប៉ះពាល់នៃអាកាសធាតុ។ |
| ការចំណាយលើការបន្សាំ | ជាការចំណាយទៅលើការធ្វើផែនការ ការរៀបចំ ការសម្របសម្រួល និងការអនុវត្តបន្សាំ រួមបញ្ចូលទាំងការចំណាយក្នុងកំឡុងពេលប្រែប្រួលផងដែរ។ |
| សមត្ថភាពបន្សាំ | ជាសមត្ថភាពជាប្រព័ន្ធ ស្ថាប័ន ធនធានមនុស្ស និងយន្តការដ៏ទៃទៀតដែលចូលរួមក្នុងការកាត់បន្ថយការខូចខាតចម្បងៗ និងដើម្បីទាញយកប្រយោជន៍ពីឱកាស ឬការឆ្លើយតបទៅនឹងផលវិបាក។ |
| គណនេយ្យភាពកាបូន | ជាការតាមដានការផ្លាស់ប្តូរនៅក្នុងស្តុកកាបូន ដែលមានទំនាក់ទំនងជាមួយមនុស្ស និងបណ្តាលមកពីប្រភពនិងការលេចនៃការបំភាយឧស្ម័នផ្ទះកញ្ចក់។ |
| កាបូនឌីអុកស៊ីត ($CO_2$) | ជាឧស្ម័នធម្មជាតិកើតឡើងដោយការដុតឥន្ធនៈហ្វូស៊ីល ដូចជាប្រេង ឧស្ម័ន និងធ្យូងថ្ម ការដុតជីវម៉ាស់និងការផ្លាស់ប្តូរក្នុងការប្រើប្រាស់ដីធ្លី និងដំណើរការឧស្សាហកម្មផ្សេងៗ។ វាជាឧស្ម័នផ្ទះកញ្ចក់ ដែលប៉ះពាល់ដសំខាន់ដល់តុល្យភាពបរិស្ថានលើផែនដី ហើយវាជាឧស្ម័នផ្ទះកញ្ចក់ ដែលបង្កើនកំដៅផែនដីជាសកល។ |
| អាកាសធាតុ | អាកាសធាតុនៅក្នុងន័យតូចចង្អៀត ត្រូវបានកំណត់ថាជាអាកាសធាតុមធ្យម ឬក្នុងន័យម្យ៉ាងទៀតជាការបរិយាយអំពីការប្រែប្រួល នៃបរិមាណពាក់ព័ន្ធក្នុងរយៈពេលចាប់ពីរាប់ខែ ដល់រាប់ពាន់ ឬរាប់លានឆ្នាំ។ កំឡុងពេលសម្រាប់អថេរទាំងនេះគឺជាមធ្យម៣០ឆ្នាំ ដូចដែលបានកំណត់ដោយអង្គការឧតុនិយមពិភពលោកដែលជាញឹកញាប់មានការប្រែប្រួលលើ សីតុណ្ហភាព ទឹកភ្លៀង និងខ្យល់។ អាកាសធាតុនៅក្នុងន័យទូលំទូលាយមួយ គឺជាការពន្យល់ស្ថិតិនៃប្រព័ន្ធអាកាសធាតុ។ |

| | |
|---|---|
| ការប្រែប្រួលអាកាសធាតុ | ការប្រែប្រួលនៃអាកាសធាតុ ដែលត្រូវបានសន្មតដោយផ្ទាល់ ឬដោយប្រយោល ដោយសារសកម្មភាពរបស់មនុស្ស ដែលបានប្តូរសមាសភាពនៃបរិយាកាសសកល និងបានបន្ថែមទៅនឹងការប្រែប្រួលអាកាសធាតុ ធម្មជាតិបានសង្កេតឃើញក្នុងរយៈពេលប្រៀបធៀបមួយ។ មាត្រា១ UNFCCC |
| ការបង្ការ | ជាសកម្មភាពនៃការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយបរិយាកាសមួយដែលគ្របដណ្តប់ថាមពលស្អាត ប្រសិទ្ធិភាពថាមពល និងការផ្លាស់ប្តូរការប្រើប្រាស់ប្រេងឥន្ធនៈ ការប្រើប្រាស់ព្រៃឈើ និងដី ការដឹកជញ្ជូន និងគម្រោងលក់កាបូន (ហិរញ្ញវត្ថុអាកាសធាតុ និងគេហទំព័រទីផ្សារ)។ |

# ១. សាវតា

កម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេស ដែលងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ និងជាប្រទេសមួយក្នុងចំណោមប្រទេសចំនួនបី ដែលងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុនៅអាស៊ី [5] ដោយសារតែប្រទេសនេះ ជាញឹកញាប់បានរងផលប៉ះពាល់ទៅនឹងទឹកជំនន់ របបទឹកភ្លៀងមិនទៀងទាត់ ទទួលឥទ្ធិពលព្យុះត្រូពិច ព្រមទាំងការកើនឡើងនៃកម្ពស់ទឹកសមុទ្រ ដោយឡែកប្រទេសកម្ពុជាមានសមត្ថភាពបន្សាំទាបនៅឡើយ [6] ។ ការវាយតម្លៃភាពងាយរងគ្រោះថ្មីមួយបានរកឃើញថា ១៧,២% នៃចំនួនឃុំទាំងអស់ត្រូវបានរកឃើញថាមានកម្រិតនៃភាពងាយរងគ្រោះខ្ពស់ និង ៣១,៥% មានកម្រិតភាពងាយរងគ្រោះបង្គួរ ទៅនឹងគ្រោះថ្នាក់នៃការប្រែប្រួលអាកាសធាតុ ដែលមានសណ្ឋានច្រើនផ្សេងៗគ្នា មានដូចជាទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត[7]។

ការវិភាគក្នុងក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ (CCFF) ដោយផ្អែកលើសេណារីយ៉ូនៃការកើនឡើងសីតុណ្ហភាព ២អង្សាសេ នៅឆ្នាំ ២០៥០ បានប៉ាន់ប្រមាណថាការខូចខាតទាំងស្រុង នៃការប្រែប្រួលអាកាសធាតុទៅនឹងផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជាអាចនឹងមានយ៉ាងហោចណាស់ ១,៥% នៅក្នុងឆ្នាំ ២០៣០ និង ៣,៥% នៅក្នុងឆ្នាំ ២០៥០ ។ ផ្ទុយមកវិញប្រសិនបើគ្មានការប្រែប្រួលអាកាសធាតុ អត្រាកំណើនប្រចាំឆ្នាំនៃ ផសស ត្រូវបានគេរំពឹងថានឹងមាន ៤,៥% នៅឆ្នាំ ២០៣០ ដែលនឹងត្រូវបានកាត់បន្ថយចំនួន ៣% ដោយសារតែផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ នៅឆ្នាំ ២០៥០ កំណើន ផសស អាចនឹងត្រូវបានថយចុះ (ការថយចុះ ១% ប៉ុណ្ណោះ) ដោយការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ប្រជាជនមួយភាគធំដែលធ្វើកសិកម្មពឹងផ្អែកទឹកភ្លៀង និងធនធានធម្មជាតិសម្រាប់ជីវភាពរស់នៅ គឺជាប្រជាជនដែលសមត្ថភាពរបស់ពួកគេដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុនូវមានកម្រិត។ យោងតាមវិទ្យាស្ថានធនធានពិភពលោក បើទោះបីជាចំណែកទីផ្សាររបស់ប្រទេសកម្ពុជា ដែលអាស្រ័យលើការបំភាយឧស្ម័នផ្ទះកញ្ចក់ ចំនួនសរុបនៅមានកម្រិតទាបគឺ ០,១% នៅក្នុងឆ្នាំ ២០១២ ក៏កម្ពុជាកំពុងមានកំណើនសេដ្ឋកិច្ចរឹងមាំ និងស្ថិតនៅក្នុងដំណាក់កាលសំខាន់មួយនៅក្នុងដំណើរការឧស្សាហូបនីយកម្មរបស់ខ្លួន។

ដោយផ្អែកលើយន្តការអាកាសធាតុរបស់ UNFCCC និងការចរចាអាកាសធាតុបានប្រើពេលជាង ២០ឆ្នាំ ក៏កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានអនុម័តក្នុង COP21 នៅទីក្រុងប៉ារីសប្រទេសបារាំង និងបានចុះហត្ថលេខាដោយភាគីអាកាសធាតុនៅថ្ងៃទី ២២ ខែមេសាឆ្នាំ ២០១៦ នៅ

---

[5] ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ, NCSD, សីហា ២០១៥

[6] ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុនៅកម្ពុជា (ពង្រាង២០១៤)

[7] ក្របខ័ណ្ឌនៃការត្រួតពិនិត្យនិងការវាយតម្លៃលើការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា, NCSD, មេសា ២០១៦

ទីក្រុងញូវយ៉កសហរដ្ឋអាមេរិក។ រាជរដ្ឋាភិបាលកម្ពុជាគឺជាសមាសភាពមួយ នៃភាគីដែលបានចុះហត្ថលេខា នៅក្រោមដំណើរការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ខណៈពេលដែលសហរដ្ឋអាមេរិក និង សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់សច្ចាប័ន និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសរួច ហើយ។

ជាលទ្ធផលនៃការចរចាអាកាសធាតុ ប្រទេសឧស្សាហកម្មបានសន្យាផ្លាស់ប្តូរមូលនិធិអាកាសធាតុ ដើម្បីគាំទ្រដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍តស៊ូជាមួយនឹងគ្រោះថ្នាក់ ជាពិសេសការបង្កើនសមត្ថភាព សម្របសម្រួលទៅនឹងអាកាសធាតុ ។ ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន UNFCCC បានប្តេជ្ញាចិត្ត ដើម្បីគោលដៅមួយ "នៃការបំផុសចលនារួមគ្នា ១០០ពាន់លានដុល្លារក្នុងមួយឆ្នាំ នៅត្រឹមឆ្នាំ២០២០ ដើម្បីដោះស្រាយតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ពីប្រភពធនធានផ្សេងៗជាច្រើនដូចជា សាធារណៈ ឬ ស្ថាប័នរដ្ឋ និងឯកជន ទ្វេភាគី និងពហុភាគី ដែលរួមមានប្រភពធនធានផ្សេងៗ" ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុបានថ្លែងថាភាគីប្រទេសអភិវឌ្ឍន៍ត្រូវផ្ត ល់ធនធានហិរញ្ញវត្ថុ ដើម្បីជួយដល់ការអភិវឌ្ឍ របស់ភាគីប្រទេសដៃគូ ដោយគោរពទៅនឹងកាត់បន្ថយ និង បន្សាំ ដោយបន្តកាតព្វកិច្ច ដែលមានស្រាប់របស់ខ្លួនក្រោមអនុសញ្ញានេះ។ ការបង្កើនធនធានហិរញ្ញវត្ថុ គួរ មានគោលបំណង ដើម្បីសម្រេចបាននូវតុល្យភាពរវាងការបន្សាំ និងការបង្ការ ការទទួលយកនូវយុទ្ធសាស្រ្ត ជំរុញគណនេយ្យភាព អាទិភាព និងតម្រូវការនៃការអភិវឌ្ឍរបស់ភាគីប្រទេសដៃគូ[8]។

ការសិក្សាថ្មីមួយនៅលើមូលនិធិអាកាសធាតុនៅឆ្នាំ ២០១៣-២០១៤ និងគោលដៅ ១០០ពាន់ លានដុល្លារអាមេរិក បានឆ្លុះបញ្ចាំងថា អាស៊ីខាងកើត និងអាស៊ីប៉ាស៊ីហ្វិច នៅតែជាគោលដៅធំបំផុត សម្រាប់មូលនិធិអាកាសធាតុដែលមានចំនួន ៣១% នៃចំនួនទឹកប្រាក់សរុប ឬ ១១៩ ពាន់លានដុល្លារ[9]។ ការសិក្សានេះក៏បាននិយាយអំពីស្ថានភាព នៃការសន្យាអាកាសធាតុរបស់ប្រទេសអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ ការផ្តួចផ្តើមអាកាសធាតុនៃប្រទេសកំពុងអភិវឌ្ឍន៍។

ផលប៉ះពាល់ចម្បងនៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា និងថ្នាក់តំបន់គឺ ១)ការ កើនឡើងសីតុណ្ហភាពខ្ពស់និងរដូវពីរនៅក្នុងអាកាសធាតុត្រូពិច ២)សីតុណ្ហភាពជាមធ្យមគឺមានសណ្ឋាន នៅទូទាំងប្រទេស ៣)តំបន់ខ្លះមានភ្លៀងធ្លាក់ច្រើនជាង ៥០០០ មីលីម៉ែត្រក្នុងអំឡុងពេលរដូវវស្សា ៤) ការប្រែប្រួលអាកាសធាតុនៅក្នុងរយៈពេល៦ខែ នៅលំយោលអែលនីណូភាគខាងត្បូង ដែលមានឥទ្ធិពល លើធម្មជាតិនៃរដូវមូសុងនៅក្នុងតំបន់ ហើយជាទូទៅក្តៅ និងស្ងួតជាង រដូវរងាមធ្យមនៅទូទាំងតំបន់អាស៊ី អាគ្នេយ៍ ខណៈដែលឡានីណានាំយកភាពត្រជាក់ជាងធម្មតា។

---

[8] កិច្ចព្រមព្រៀងទីក្រុងប៉ារីស, UNFCCC ២០១៥

[9] ការផ្តួចផ្តើមគោលនយោបាយអាកាសធាតុ and OECD ២០១៥

និន្នាការនៃហានិភ័យអាកាសធាតុនៅកម្ពុជានាពេលអនាគត ១) អត្រានៃការកើនឡើងកំដៅយ៉ាងលឿនបំផុតនៅក្នុងរដូវប្រាំង (ខែធ្នូ រហូតដល់ខែឧសភា) ដែលកើនពី ០.២-០.២៣°C ក្នុងមួយទសវត្សរ៍ និងរដូវវស្សាឃើត (ខែមិថុនាដល់ខែវិច្ឆិកា) ដែលកើនពី ០.១៣-០.១៦°C ក្នុងមួយទសវត្សរ៍) មានន័យថាការធ្លាក់ភ្លៀងមិនទៀងទាត់នៅកម្ពុជា ដោយមានតំបន់ខ្លះជួបប្រទះការកើនឡើង និងតំបន់ខ្លះជួបប្រទះការថយចុះ ប៉ុន្តែការផ្លាស់ប្តូរទាំងនេះគឺមិនមានស្ថិតិជាក់លាក់ឡើយ[10]។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) គឺជាអង្គការធំត្រ របស់អង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិ ដែលមានអាណត្តិដើម្បីសម្របសម្រួលក្រុមអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ងាយរងគ្រោះទៅនឹងការតស៊ូមតិ ជាមួយរដ្ឋាភិបាល និងម្ចាស់ជំនួយសម្រាប់គោលនយោបាយគាំទ្រប្រជាពលរដ្ឋក្រីក្រ។ គម្រោងឃ្លាំមើលគោលនយោបាយប្រែប្រួលអាកាសធាតុ គឺជាគម្រោងសកម្មមួយ ដើម្បីចូលរួមពិនិត្យវឌ្ឍនភាពនៃការចរចាផ្លាស់ប្តូរអាកាសធាតុ ការធ្វើផែនការ និងថវិកាឆ្លើយតបទៅនឹងអាកាសធាតុ ព្រមទាំងតាមដានមូលនិធិអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។ NGOF បានកំពុងធ្វើការយ៉ាងសកម្មជាមួយបណ្តាញអង្គការក្រៅរដ្ឋាភិបាល សម្របសម្រួលដោយ Gemanwatch ក្រោមមូលនិធិបន្សាំ ដែលមានមូលដ្ឋាននៅទីក្រុង Bonn ប្រទេសអាល្លឺម៉ង់ ដែលបានបង្កើតឡើងនៅឆ្នាំ២០១០។ បណ្តាញនេះមានអាណត្តិជាយន្តការផ្តល់មតិ ដែលមានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនកំពុងបានអនុវត្តន៍ផែនការ ដើម្បីធានាបាននូវឥទ្ធិពលវិជ្ជមានដើម្បីប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

## ២. គោលបំណងនៃការសិក្សា

- វិភាគគោលនយោបាយជាតិ ស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- យល់ដឹងអំពីការអនុវត្តគោលនយោបាយ នៅកម្រិតមូលដ្ឋាន ក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធនឹងផែនការបន្សាំថ្នាក់ជាតិ
- តាមដានការអនុវត្តការបន្សាំ ដែលមាននៅកម្ពុជាជាអាណត្តិរបស់ក្រសួងបរិស្ថាន និងភ្នាក់ងារផ្សេងៗទៀត
- ចងក្រងការអនុវត្តល្អ នៃការបញ្ជ្រាបការបន្សាំនៅថ្នាក់ក្រោមជាតិ ការបន្សាំរបស់គម្រោងបឹងពេ និងករណីសិក្សាមួយរបស់គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ADB

10 http://sdwebx.worldbank.org/climateportalb/home.cfm?page=country_profile&CCode=KHM&ThisTab=Climate ទិន្នន័យគោល

# ៣. វិធីសាស្រ្ត

ការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់វិធីសាស្រ្តជាច្រើន រួមបញ្ចូលគ្នាដូចជា ទិន្នន័យបែបគុណភាព និងបែបបរិមាណ ដែលប្រមូលបានពីការស្រាវជ្រាវទិន្នន័យដែលមានស្រាប់ កិច្ចសំភាសជាមួយជនបង្គោលសំខាន់ៗ និងករណីសិក្សាផ្សេងៗ។

- **ទិន្នន័យដែលមានស្រាប់:** ការសិក្សានេះត្រូវបានធ្វើឡើងដើម្បីសិក្សាលំហូរសកលនៃការផ្តល់មូលនិធិការប្រែប្រួលអាកាសធាតុ និន្នាការនៃការផ្តល់មូលនិធិការប្រែប្រួលអាកាសធាតុទៅតំបន់អាស៊ី និងអាស៊ីប៉ាស៊ីហ្វិក គោលនយោបាយការប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាលកម្ពុជា ការសិក្សាក្នុងតំបន់ និងអន្តរជាតិទាក់ទងទៅនឹងការផ្តល់មូលនិធិការប្រែប្រួលអាកាសធាតុ ឯកសារគម្រោងមូលដ្ឋាន ទិន្នន័យនៅតាមបណ្តាញនានានិងវេបសាយ។

- **កិច្ចសំភាសជាមួយជនបង្គោល:** ភាគីពាក់ព័ន្ធពីក្រសួងរាជរដ្ឋាភិបាល (នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) លេខាធិការដ្ឋាន NCDD ម្ចាស់ជំនួយ (ADB, UNDP, SIDA, សហភាពអឺរ៉ុប និងអង្គការ JICA) អង្គការមិនមែនរដ្ឋាភិបាល SPCR អាជ្ញាធរមូលដ្ឋាន អ្នកជំនាញ និងអ្នកទទួលផលត្រូវបានសម្ភាសន៍ ដើម្បីផ្ទៀងផ្ទាត់ និងបំពេញលទ្ធផលនៃការស្រាវជ្រាវទិន្នន័យដែលមានស្រាប់នេះ។

- **ករណីសិក្សា:** ករណីសិក្សាចំនួនបីនៅក្នុងគម្រោងប្រែប្រួលអាកាសធាតុ ដែលទទួលថវិកាពីម្ចាស់ជំនួយផ្សេងៗគ្នាត្រូវបានជ្រើសរើសសម្រាប់ការវិភាគបន្ថែមទៀត។ គោលបំណងនៃករណីសិក្សានេះ គឺដើម្បីរកឱ្យឃើញពីភាពជោគជ័យ និងការប្រឈមក្នុងការអនុវត្តគម្រោងបន្ស៊ាំ។ ក្នុងករណីសិក្សានីមួយៗអ្នកស្រាវជ្រាវបានធ្វើការចុះផ្ទាល់ទៅតំបន់របស់គម្រោង ធ្វើបទសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយអ្នកទទួលផល និងអ្នកអនុវត្តន៍គម្រោង។

- **សិក្ខាសាលាពិគ្រោះយោបល់:** ធ្វើបទបង្ហាញអំពីការរកឃើញបឋម ទៅភាគីអ្នកពាក់ព័ន្ធបច្ចុប្បន្នរួមមានក្រសួងរដ្ឋាភិបាលពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ភ្នាក់ងារអង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍អាស៊ីបណ្តាញអង្គការក្រៅរដ្ឋាភិបាល សហគមន៍មូលដ្ឋាន ដែលមានអ្នកចូលរួមប្រមាណ ៧១នាក់ ដើម្បីផ្ទៀងផ្ទាត់ និងផ្តល់នូវធាតុចូលបន្ថែមទៀតទៅក្នុងរបាយការណ៍នេះអោយកាន់តែប្រសើរ។

# ៤. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ទិដ្ឋភាពជាទូទៅនៃការសិក្សានេះ បានផ្តោតទៅលើលំហូរមូលនិធិអាកាសធាតុមកពីប្រទេសអភិវឌ្ឍន៍ ទៅនឹងគម្រោងការបន្សាំនៅកម្ពុជា។ ដោយផ្អែកលើលក្ខខណ្ឌយោង ការសិក្សានេះនឹងផ្តោតលើការធ្វើបច្ចុប្បន្នភាព នៃមូលនិធិអាកាសធាតុប្រើដើម្បីគាំទ្រដល់សហគមន៍ដែលរងផលប៉ះពាល់ឱ្យកាន់តែធន់ទៅនឹងផលប៉ះពាល់អាកាសធាតុ។ ករណីសិក្សាចំនួនបីត្រូវបានជ្រើសរើសសម្រាប់ធ្វើការវិភាគលើបញ្ហាប្រឈម ការអន្តរាគមន៍របស់គម្រោង និងបានជាប្រយោជន៍ដល់សហគមន៍ក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែព័ត៌មានមួយចំនួនត្រូវបានដាក់កម្រិតដោយរដ្ឋាភិបាល ដូចជារបាយការណ៍ការចំណាយជាតិនៅឆ្នាំ២០១៥ និងឆ្នាំ២០១៦ ដោយព័ត៌មានទាំងនេះត្រូវបានកំពុងតែនៅដំណើរការដើម្បីបញ្ចប់ឡើយ និងមិនអាចចេញផ្សាយជាព្រឹត្តិការណ៍សាធារណៈនៅឡើយទេ បើទោះជាអ្នកនិពន្ធព្យាយាមធ្វើការទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងក៏ដោយដូច្នេះអ្នកនិពន្ធ ធ្វើការវិភាគទៅលើទិន្នន័យដែលត្រូវបានប្រមូលតែប៉ុណ្ណោះ។

# ៥. ទិដ្ឋភាពទូទៅនៃមូលនិធិការប្រែប្រួលអាកាសធាតុ

## ៥.១ មូលនិធិការប្រែប្រួលអាកាសធាតុសកល

ស្ថាប័នមូលនិធិការប្រែប្រួលអាកាសធាតុសកល បានបង្កើតឡើងនៅមុនថ្ងៃកិច្ចប្រជុំកំពូលទីក្រុងរីយ៉ូ ១៩៩២ គឺជាកាតាលីករដ៏សំខាន់សម្រាប់សកម្មភាពការពារបរិស្ថាន និងសកម្មភាពជាច្រើនលើសពីនេះ។ តាមរយៈការវិនិយោគជាយុទ្ធសាស្ត្ររបស់ខ្លួន GEF បានធ្វើការជាមួយដៃគូដើម្បីដោះស្រាយបញ្ហាបរិស្ថានធំៗជាច្រើន។ មូលនិធិនេះបានជួយដល់ការកាត់បន្ថយភាពក្រីក្រ ពង្រឹងអភិបាលកិច្ច និងសម្រេចបាននូវសមភាពរវាងស្ត្រីនិងបុរស ក្នុងភាពជាដៃគូសកលសម្រាប់ភពផែនដីប្រកបដោយនិរន្តរភាព។

i. ភាពជាដៃគូសកលរបស់ស្ថាប័នទាំង១៨ រួមមានទីភ្នាក់ងារអង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍ពហុភាគី អង្គភាពជាតិ និងអង្គការអន្តរជាតិ ដែលធ្វើការជាមួយប្រទេសចំនួន១៨៣ ដើម្បីដោះស្រាយបញ្ហាបរិស្ថាននៅលើពិភពលោក។ GEF មានបណ្តាញសំខាន់មួយ ដែលរួមមានអង្គការសង្គមស៊ីវិលបានកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជននៅជុំវិញពិភពលោក និងទទួលបានធាតុចូលជាបន្តបន្ទាប់ពីការិយាល័យវាយតម្លៃឯករាជ្យ និងជាក្រុមប្រឹក្សាវិទ្យាសាស្ត្រលំដាប់ពិភពលោក។

ii. យន្តការមូលនិធិ មាននៅក្នុងអនុសញ្ញាបរិស្ថានអន្តរជាតិធំ ចំនួន ៥: អនុសញ្ញា Minamata Stockholm ស្តីអំពីការបំពុលសរីរាង្គ (POP) អនុសញ្ញាសហប្រជាជាតិស្តីពីជីវចម្រុះ (UNCBD)

អនុសញ្ញាអង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងភាពក្លាយជាវាលរហោស្ថាន (UNCCD) និងក្របខ័ណ្ឌអង្គការសហប្រជាជាតិ អនុសញ្ញាស្ដីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

iii. នវានុវត្តន៍ និងកាតាលីករ ដែលគាំទ្រការចងសម្ព័ន្ធភាពនៃអ្នកពាក់ព័ន្ធ ដើម្បីការពារប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែងនៅលើដី និងនៅក្នុងសមុទ្រ ការកសាងទីក្រុងបៃតង បង្កើនសន្តិសុខស្បៀងនិងជំរុញថាមពលស្អាតសម្រាប់វិបុលភាព ភាពធន់ទៅនឹងអាកាសធាតុពិភពលោកដែលបានបង្កើនមូលនិធិ ៥,២ដុល្លារ បន្ថែមលើរាល់ការវិនិយោគ១ដុល្លារ។




*ក្រាហ្វិច 1: ក្របខណ្ឌនៃស្ថាប័នមូលនិធិបរិស្ថានពិភពលោក ( GEF)*

## ៥.២ មូលនិធិវិនិយោគលើការប្រែប្រួលអាកាសធាតុ (CIF)

មូលនិធិវិនិយោគបានផ្ដល់នូវធនធានចាំបាច់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសមានប្រាក់ចំណូលមធ្យម ដើម្បីកាត់បន្ថយនិងគ្រប់គ្រងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ។ ចាប់តាំងពីឆ្នាំ២០០៨ មកក្រុមម្ចាស់មូលនិធិCIF បានដឹកនាំការវិនិយោគប្រកបដោយភាពច្នៃប្រឌិតលើបច្ចេកវិទ្យាស្អាត ថាមពលកកើតឡើងវិញ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងភាពធន់ទៅនឹងអាកាសធាតុ។ CIF មានមូលនិធិចំនួនពីរ គឺមូលនិធិបច្ចេកវិទ្យាស្អាត និងមូលនិធិអាកាសធាតុជាយុទ្ធសាស្ត្រ ដែលគ្រប់គ្រងដោយគណៈកម្មាធិការ និងអនុគណៈកម្មាធិការ។ CIF មានកម្មវិធីសំខាន់ចំនួនបួន ដែលជួយ

ដល់ប្រទេសកំពុងអភិវឌ្ឍន៍សាកល្បងការបំភាយឧស្ម័នកម្រិតទាប និងភាពធន់ទៅនឹងអាកាសធាតុ រួមមាន (១)មូលនិធិបច្ចេកវិទ្យាស្អាត (២)កម្មវិធីវិនិយោគព្រៃឈើ (៣)ការសាកល្បងសម្រាប់ភាពធន់ទៅនឹងអាកាសធាតុ និង (៤)បង្កើនថាមពលកកើតឡើងវិញនៅបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប។ កម្ពុជាទទួលបានប្រាក់សរុប ៩១លានដុល្លារ (៥៥លានសម្រាប់ធនធាន និង៣៦លានជាជំនួយឥណទានការប្រាក់ទាបបំផុត) ពីកម្មវិធី PPCR តាមរយៈ ADB សម្រាប់អនុវត្តន៍គម្រោងវិនិយោគ ៧ SPCR និងគម្រោងជំនួយការបច្ចេកទេសមួយរួប។ មានប្រទេសអភិវឌ្ឍន៍ចំនួន១៤បានចូលរួមផ្តល់ថវិកា ៨,១៣ន់លានដុល្លារទៅ CIF ដែលត្រូវបានគេរំពឹងថានឹងពង្រីកបន្ថែមថវិកាសរុបចំនួន ៥៧ពាន់លានរួមបញ្ចូលពីប្រភពផ្សេងទៀត។ កាលពីខែកញ្ញាឆ្នាំ ២០០៨ ប្រទេសម្ចាស់ជំនួយបានសន្យាផ្តល់ជំនួយជាង ៦,១ ពាន់លានដុល្លារដល់មូលនិធិបច្ចេកវិទ្យាស្អាត និងមូលនិធិយុទ្ធសាស្ត្រអាកាសធាតុ។ មូលនិធិនេះត្រូវបានផ្តល់ជាជំនួយឥតសំណង កម្ចីសម្បទានខ្ពស់ និង ឬជាឧបករណ៍ការបន្ថយហានិភ័យ។

រចនាសម្ព័ន្ធរបស់ CIF ចែកជាមូលនិធិចំនួនពីរ គឺមូលនិធិបច្ចេកវិទ្យាស្អាត និងមូលនិធិយុទ្ធសាស្ត្រអាកាសធាតុ ដែលមូលនិធិនីមួយៗមានគណៈកម្មាធិការ និងអនុគណៈកម្មាធិការ ដែលមានតំណាងពីប្រទេសម្ចាស់ជំនួយ និងប្រទេសទទួលជំនួយ ដើម្បីគ្រប់គ្រង និងផ្តល់ការណែនាំដល់កម្មវិធីគោលដៅទាំងបី។ មូលនិធិមានគោលបំណង ក្នុងការជំរុញការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ និងភាពធន់ទៅនឹង ការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

## ៥.៣ មូលនិធិបន្សាំ

មូលនិធិបន្សាំបានបង្កើតឡើងនៅឆ្នាំ២០០១ ដើម្បីផ្តល់មូលនិធិដល់គម្រោងបន្សាំរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិកពិធីសារ ក្យូតូ ដែលរងផលប៉ះពាល់ទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងកំពុងប្រឈមទៅនឹងកង្វះធនធាន។ កម្ពុជាបានទទួលបាននូវគម្រោងកម្មវិធីស្តីពី "ការលើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអកាសធាតុរបស់សហគមន៍ជនបទនៅក្នុងតំបន់ការពារ" ដែលមានទឹកប្រាក់សរុបប្រមាណ ៥លានដុល្លារនៅចុងឆ្នាំ ២០១២ ហើយគម្រោងនេះបានអនុវត្តន៍ដោយក្រសួងបរិស្ថាន និង UNEP។

មូលនិធិនេះទទួលបានពីបណ្តាប្រទេសអឺរ៉ុប អូស្ត្រាលី ស្វីស និងវិស័យឯកជន ដែលមូលនិធិនេះគ្រប់គ្រងដោយគណៈកម្មាការមូលនិធិបន្សាំ (AFB) រួមមានសមាសភាព ១៦រូបមកពីបណ្តាប្រទេសម្ចាស់ជំនួយ និងតំណាងវិស័យឯកជនធំៗ។ គណៈកម្មការមូលនិធិមានកិច្ចប្រជុំចំនួនពីរដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃ និងឯកភាពលើគម្រោង ដោយមានការសម្របសម្រួលដោយលេខាធិការដ្ឋាន (GEF) និងគ្រប់គ្រងថវិកាជាបណ្តោះអាសន្នដោយធនាគារពិភពលោក។

គោលបំណងមូលនិធិបន្សាំ គឺដើម្បីផ្តល់មូលនិធិដល់គម្រោងបន្សាំ និងសហគមន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលរងផលប៉ះពាល់ទៅនឹងឥទ្ធិពលនៃប្រែប្រួលអកាសធាតុ និងកំពុងប្រឈមទៅនឹងកង្វះ

ធនធាន។ មូលនិធិបន្សាំផ្តោតទៅលើ ការបន្សាំ និងភាពធន់ដែលចូលរួមក្នុងការដោះស្រាយបញ្ហាទាក់ទង នឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មូលនិធិមានពីរ ដែលមូលនិធិកម្រិតតូចមាន គម្រោងថវិកាហូតដល់១លានដុល្លារ រីឯមូលនិធិទំហំធម្មតាមានថវិកាប្រមាណ១០លានដុល្លារ។ មូលនិធិ នឹងគាំទ្រទៅរាល់គម្រោងសំណើររបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានគុណវឌ្ឍន៍ខ្ពស់។

## ៥.៤ សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល (GCCA)

សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល បានបង្កើតឡើងដោយសហគមន៍អឺរ៉ុបក្នុងឆ្នាំ២០០៧ ដើម្បីពង្រឹងការចរចា និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសប្រទេសមានការ អភិវឌ្ឍតិចតួច (LDCs) និងរដ្ឋនៅតាមបណ្តាកោះ (SIDS) ហើយសម្ព័ន្ធប្រែប្រួលអាកាសធាតុសកល មានតួនាទីក្នុងការគាំទ្រដល់កិច្ចខិតខំរបស់ពួកគេក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធា តុ។ បច្ចុប្បន្ន សម្ព័ន្ធបានប្រែក្លាយជា GCCA+ ក្រោមក្របខណ្ឌហិរញ្ញប្បទាន (២០១៤-២០២០) ដែលជា គំនិតផ្តួចផ្តើមរបស់សហគមន៍អឺរ៉ុប កំពុងគាំទ្រកម្មវិធីប្រែប្រួលអាកាសធាតុចំនួន៣៨ ទាំង ៨តំបន់ និងអនុ តំបន់ទូទាំងពិភពលោក។

អាទិភាពសំខាន់ចំនួន៥ ត្រូវបានកំណត់សម្រាប់សម្ព័ន្ធ៖

- បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកាត់បន្ថយភាពក្រីក្រ និងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍។
- បង្កើនចំនេះដឹងទាក់ទងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការរៀបចំគម្រោង អនុវត្តន៍ការបន្សាំសមស្រប ជាពិសេសនៅផ្នែកទឹក និងកសិកម្ម។
- កាត់បន្ថយការបំភាយឧស្ម័នដែលកើតឡើងពីការកាប់បំផ្លាញ និងការសឹករិចរិលព្រៃឈើ (REDD)។
- ជំរុញការចូលរួមការលក់កាបូនសកល រួមបញ្ចូលទាំងយន្តការអភិវឌ្ឍន៍ស្អាត (CDM)។
- ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (DRR)។

មូលនិធិផ្តោតសំខាន់លើវិស័យចំនួន៣ដូចខាងក្រោម

- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកាត់បន្ថយភាពក្រីក្រ (កិច្ចសន្ទនាគោល នយោបាយ ការចូលរួម UNFCCC អនុវត្តន៍កិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីសម្រេចបាននូវការ អភិវឌ្ឍប្រកបដោយចីរភាព ។ល។)
- វិស័យបន្សាំ និងការកាត់បន្ថយប្រែប្រួលអាកាសធាតុ (ការបញ្ជ្រាបប្រែប្រួលអាកាសធាតុទៅក្នុង ការកាត់បន្ថយភាពក្រីក្រ, បង្កើនចំនេះដឹងទាក់ទងទៅនឹងការបន្សាំនៅក្នុងវិស័យទឹក និងកសិកម្ម REDD CDM DRR។
- លើកកម្ពស់ភាពធន់ទៅនឹងប្រែប្រួលអាកាសធាតុ ទាក់ទងទៅនឹងភាពតានតឹង និងតក់ស្លុត

## ៩.៩ មូលនិធិអាកាសធាតុបៃតង (GCF)

មូលនិធិអាកាសធាតុបៃតង បានបង្កើតឡើងដោយសមាជិក UNFCCC ក្នុងកិច្ចប្រជុំ Cancún នាខែធ្នូ ឆ្នាំ២០១០ និងបានដំណើរការជាផ្លូវការនៅឆ្នាំ២០១១ នៅពេលដែលយន្តការគ្រប់គ្រងជំនួយត្រូវបានបង្កើត និងឯកភាព។ មូលនិធិនេះជាយន្តការក្នុងការផ្តល់ជំនួយរបស់ UNFCCC ស្របទៅនឹងមាត្រា ១១ នៃអនុសញ្ញា សំដៅគាំទ្រដល់ការកាត់បន្ថយ និងការបន្ស៊ាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកម្រិតរឺកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ និងបន្ស៊ាំទៅនឹងឥទ្ធិពលនៃប្រែប្រួលអាកាសធាតុ របស់ប្រទេសក្រីក្រ។ មូលនិធិមានគោលបំណងក្នុងការចូលរួមដល់កិច្ចខិតខំរបស់ពិភពលោក ដើម្បីសម្រេចបាននូវគោលបំណងចុងក្រោយរបស់ UNFCCC ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងប្រែប្រួលអាកាសធាតុ។ មូលនិធិត្រូវបានគ្រប់គ្រងដោយគណៈកម្មការ ជាមួយនឹងការគាំទ្រប្រតិបត្តិដោយលេខាធិការដ្ឋាន អ្នកទទួល និងក្រុមផ្តល់យោបល់បច្ចេកទេស។ ដើម្បីទទួលមូលនិធិនេះ ប្រទេសកម្ពុជា តាមរយៈ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (CCD/NCSD) ក្រោមការគាំទ្ររបស់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA) កំពុងសម្របសម្រួលបង្កើតអង្គភាពអនុវត្តរបស់ជាតិ សម្រាប់ការអនុវត្តមូលនិធិបៃតង ដែលក្រសួងបរិស្ថានដើរតួនាទីជាអាជ្ញាធរជាតិ។ មូលនិធិបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់មូលនិធិទៅប្រទេសកំពុងអភិវឌ្ឍន៍ ជាកាតាលីករនៃមូលនិធិអាកាសធាតុ ស្ថាប័នរដ្ឋ និងឯកជន នៅថ្នាក់ជាតិ និងអន្តរជាតិ។ មូលនិធិនេះបានខិតខំបង្កើនឥទ្ធិពលរបស់ខ្លួនសម្រាប់ការបន្ស៊ាំ ការបង្ការ និងស្វែងរកតុល្យភាពរវាងយន្តការពីរខាងលើ ខណៈពេលដែលការលើកកម្ពស់បរិស្ថាន សង្គម សេដ្ឋកិច្ច និងការអភិវឌ្ឍបានផ្តល់សហប្រយោជន៍ និងការទទួលយកវិធីសាស្រ្តឆ្លើយតបចំពោះយេនឌ័រ។

មូលនិធិនេះត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាល ដែលមានការទទួលខុសត្រូវពេញលេញសម្រាប់ការសម្រេចចិត្តលើមូលនិធិនេះ និងទទួលការណែនាំពីសន្និសីទបណ្តាភាគីជាសមាជិក(COP)។ សមាជិកក្រុមប្រឹក្សាភិបាល មានសមាសភាពមកពីបណ្តាប្រទេសសំខាន់ៗ នៃការចូលរួមចំណែករបស់មូលនិធិនេះ រួមមានសហរដ្ឋអាមេរិក ជប៉ុន ចក្រភពអង់គ្លេស បារាំង អាល្លឺម៉ង់ ស៊ុយអែត អ៊ីតាលី កាណាដា ន័រវេស អូស្ត្រាលី អេស្ប៉ាញ ហូល្លង់ ហ្វាំងឡង់ កូរ៉េ ស្វីស ដាណឺម៉ាក បែលហ្ស៊ិក អូទ្រីស និង ម៉ិកស៊ិកូ។ ក្រុមប្រឹក្សាភិបាល GCF អនុម័តការបង្កើតលេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតងឯករាជ្យនៅក្នុងខែតុលាឆ្នាំ២០១៣។ លេខាធិការដ្ឋានមានតួនាទីឆ្លើយតបចំពោះការគ្រប់គ្រងប្រតិបត្តិ និងការប្រតិបត្តិនៃមូលនិធិនេះដែរ រួមមានការផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស រដ្ឋបាល និងការផ្គត់ផ្គង់ទៅឱ្យក្រុមប្រឹក្សាភិបាលដោយមានលក្ខណៈឯករាជ្យភាព។ មូលនិធិនេះមានអ្នកទទួលដែលមានតួនាទី និងគណនេយ្យភាពទៅក្រុមប្រឹក្សាភិបាលក្នុងការគ្រប់គ្រងទ្រព្យសកម្ម ធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងផ្តល់បច្ចេកទេសប្រឹក្សាឯករាជ្យ ដើម្បីផ្តល់នូវការវាយតម្លៃបច្ចេកទេសឯករាជ្យ និងជំរុញនូវលើសំណើរថវិការបស់មូលនិធិ។

## គោលបំណងជាក់លាក់នៃមូលនិធិនេះគឺ៖

- ដើម្បីចូលរួមចំណែកយ៉ាងសំខាន់ និងប្រកបដោយមហិច្ឆតា ដល់កិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការសម្រេចបានគោលដៅដែលបានកំណត់ដោយសហគមន៍អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ

- ដើម្បីរួមចំណែកដល់សមិទ្ធផលនៃគោលដៅចុងក្រោយនៃអនុសញ្ញាក្រោមក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និង

- ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរជាគំរូ ឆ្ពោះទៅរកការបំភាយឧស្ម័នទាប និងការអភិវឌ្ឍធន់ទៅនឹងអាកាសធាតុ ដោយផ្តល់ការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកម្រិត ឬកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន និងដើម្បីសម្របខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងមានគណនេយ្យភាពទៅនឹងតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ ពិសេសបណ្តាប្រទេសងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

មូលនិធិនេះផ្តោតលើការកាត់បន្ថយ ការបន្សាំ និងការរួមបញ្ចូលគ្នានៃយន្តការទាំងពីរនេះបានជាកម្មវិធីកាត់បន្ថយឧស្ម័នពីការបាត់បង់ និងការរិចរឹលនៃព្រៃឈើ (REDD+)ដើម្បីដោះស្រាយ ក្តីបារម្ភទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកំពុងអភិវឌ្ឍ។ ការបន្សាំសំដៅទៅលើសកម្មភាពដែលធ្វើឡើងនៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលពិតប្រាកដ និងការរំពឹងថានឹងអាចមានការប្រែប្រួលអាកាសធាតុ ដែលសកម្មភាពទាំងនេះនឹងអាចកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលទាំងនេះ។ កិច្ចប្រជុំអំពីការបន្សាំបានចំណាយធនធានជាច្រើនរបស់សហគមន៍អន្តរជាតិ UNFCCC បានចំណាយប្រមាណ២៨ – ៦៧ពាន់លានដុល្លារក្នុងមួយឆ្នាំសម្រាប់ប្រទេសកំពុងអភិវឌ្ឍរហូតដល់ឆ្នាំ២០៣០។ ការបង្ការសំដៅទៅលើការអន្តរាគមន៍របស់មនុស្សក្នុងការកាត់បន្ថយការបំភាយឧស្ម័នពុល រឺឧស្ម័នផ្ទះកញ្ចក់ ផ្ទុយមកវិញការចាំបាច់ដើម្បីចាត់វិធានការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ នៅមិនបានគិតថាបន្ទាន់នៅឡើយ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ ដោយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅតែបន្តកើនឡើង។ ប្រភេទមូលនិធិ ដែលបានស្នើឡើងមានទំហំគម្រោង/កម្មវិធីបួនប្រភេទ: មីក្រូ តូច មធ្យម និងសំណើធំ។ សំណើខ្នាតមីក្រូមានទំហំទឹកប្រាក់សរុបរហូតដល់ទៅ ១០លានដុល្លារ សំណើតូចនឹងមានទំហំទឹកប្រាក់សរុបលើសពី ១០លានដុល្លាររហូតដល់ ៥០លាន សំណើមធ្យមនឹងមានទំហំទឹកប្រាក់សរុបលើសពី ៥០លាន រហូតដល់ ២៥០លាន និងសំណើដែលមានទំហំធំនឹងមានទំហំទឹកប្រាក់សរុបចំនួន ២៥០លានឡើង។

# ៦. របកគំហើញនៃការសិក្សាស្រាវជ្រាវ

## ៦.១ យន្តការហិរញ្ញប្បទានអាកាសធាតុ

### ៦.១.១ ស្ថាបត្យកម្មនៃហិរញ្ញប្បទានអាកាសធាតុសាកល

ស្ថាបត្យកម្មនៃហិរញ្ញប្បទានអាកាសធាតុសាកលគឺមានភាពស្មុកស្មាញ៖ ហិរញ្ញប្បទានគឺលំហូរតាមរយៈមូលនិធិពហុភាគី ដូចជា មូលនិធិបរិស្ថានពិភពលោក(GEF) និងមូលនិធិវិនិយោគអាកាសធាតុ និងការកើនឡើងនៃលំហូមូលនិធិតាមរយៈទ្វេភាគីផងដែរ។ បន្ថែមពីនេះ មានការកើនឡើងនៃចំនួនប្រទេសដែលអាចទទួលបានមូលនិធិអាកាសធាតុបានបង្កើតឡើងនូវមូលនិធិប្រែប្រួលអាកាសធាតុជាតិ ដែលយន្តការនេះអាចទទួលបានមូលនិធិពីប្រទេសអភិវឌ្ឍន៍ពហុភាគីក្នុងកិច្ចខំប្រឹងប្រែងសម្របសម្រួល និងផ្សារភ្ជាប់ចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយទៅនឹងអាទិភាពរបស់ជាតិ។




*ក្រាហ្វិច២៖ ស្ថាបត្យកម្មនៃហិរញ្ញប្បទានអាកាសធាតុសាកល (បច្ចុប្បន្នភាពនៃហិរញ្ញប្បទានអាកាសធាតុ ខែតុលា ឆ្នាំ២០១៦)*

ជាទូទៅ មានតម្លាភាពច្រើនអំពីស្ថានភាពនៃការអនុវត្តគំនិតផ្តួចផ្តើមហិរញ្ញប្បទានអាកាសធាតុពហុភាគីប្រសើរជាងគំនិតផ្តួចផ្តើមហិរញ្ញប្បទានអាកាសធាតុត្រីភាគី។ យន្តការនៃការបែងចែកហិរញ្ញប្បទានអាកាសធាតុបានបង្កើតនូវបញ្ហាប្រឈមក្នុងការសម្របសម្រួលមូលនិធិ និងការទទួលបានហិរញ្ញប្បទាន។




*ក្រាហ្វិច៣៖ និន្នាការសកលសម្រាប់ហិរញ្ញប្បទានអាកាសធាតុក្នុងពិភពលោក*
(ប្រភព: http://www.climatefundsupdate.org/global-trends/size-spending)

## ៦.២ មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពបន្សាំនៅលើពិភពលោក

កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុគឺខ្លាំងក្លា ហើយវាមានសារៈសំខាន់ណាស់ក្នុងការជួយប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលមានបទពិសោធន៍រួចរាល់ហើយកាលពីអតីតកាល និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នាពេលបច្ចុប្បន្ន។ ហិរញ្ញប្បទានអាកាសធាតុមានសារៈសំខាន់ណាស់ក្នុងការផ្តល់មូលនិធិគាំទ្រដល់សកម្មភាពដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដូចជា ទឹកជំនន់ ព្យុះស៊ីក្លូន ការហូរច្រើននៃតំបន់ឆ្នេរ រាំងស្ងួត និងមានការកើនឡើងនៃការប្រែប្រួលនៃរបបទឹកភ្លៀង។

បច្ចុប្បន្ននេះប្រហែលជា ២៤%នៃមូលនិធិអាកាសធាតុត្រូវបានអនុម័តកាលពីឆ្នាំ២០០៣ ដោយលំហូរពីកម្មវិធីគំនិតផ្តួចផ្តើមហិរញ្ញប្បទានអាកាសធាតុដែល បច្ចុប្បន្នភាពហិរញ្ញប្បទានអាកាសធាតុ (CFU) ត្រួតពិនិត្យលើការគាំទ្រដល់ការបន្សាំ។ ការផ្តល់ហិរញ្ញប្បទានអាកាសធាតុនេះបានធ្វើឱ្យមានភាពស្មុគស្មាញជាច្រើនដែលមានភាពមិនស្មើគ្នាលើផលប៉ះពាល់ពីការប្រែប្រួល អាកាសធាតុនៅក្នុងប្រទេសក្រីក្រដែលរងផលប៉ះពាល់អាក្រក់បំផុត(ពិសេសរដ្ឋកំពុងអភិវឌ្ឍន៍នៅលើតំបន់កោះតូចៗ) និងប្រទេស

អភិវឌ្ឍន៍តិចតួចនានា។ ប្រទេសទាំងនេះមានភាពខុសប្លែកគ្នាលើសមត្ថភាពស្ថាប័នដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងធានាថាការប្រើប្រាស់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព និងសមភាពដោយរួមបញ្ចូលនូវយេនឌ័រ។ ទិន្នន័យនៃបច្ចុប្បន្នភាពហិរញ្ញប្បទានអាកាសធាតុបានលើកឡើងថា ៥៧% មានការកើនឡើងលើការអនុម័តមូលនិធិពហុភាគីសម្រាប់ការបន្សាំកាលពីប៉ុន្មានឆ្នាំកន្លងទៅ។ ទោះបីយ៉ាងណាក៏ដោយ ការវាយតម្លៃចំនួនដែលបានទូទាត់ត្រូវបានពន្យាដោយសារកង្វះផ្ទៃកតម្លាភាព និងការរាយការណ៍ពីប្រទេសទទួលជំនួយ។

តារាង១ បញ្ជីមូលនិធិពហុភាគី ដែលបានបញ្ជាក់ពីការប្រែប្រួលអាកាសធាតុដោយផ្ដោតលើសកម្មភាពដែលមានគោលដៅលើការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុពេញលេញ។ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុសាកលរបស់សហគមន៍អឺរ៉ុប បានផ្តល់មូនិធិអាកាសធាតុដោយផ្តោតលើការប្រែប្រួលអាកាសធាតុ ប៉ុន្តែមិនបានធ្វើបញ្ជីអំពីសកម្មភាពបន្សាំទេ តែផ្តោតលើការគាំទ្រសកម្មភាព និងពហុគោលបំណងដែលមានការបន្សាំផងដែរ។ កម្មវិធីសាកល្បងភាពធន់នឹងអាកាសធាតុ(PPCR) បានអនុម័តថវិកាទំហំធំសម្រាប់ការបន្សាំរហូតមកដល់បច្ចុប្បន្ន និងបានចុះបញ្ជីប្រហែល៩៣%កើនឡើងក្នុងឆ្នាំនេះ (៣៨៣លានដុល្លារអាមេរិច) បើយ៉ាងនេះក្តី ការគាំទ្រនេះផ្តោតសំខាន់តែលើប្រទេសមួយពីរ បី ប៉ុណ្ណោះដែលទទួលបានមូលនិធិគាំទ្រ ពីព្រោះអភិក្រមនៃកម្មវិធីសាកល្បងនេះមានលក្ខណៈបញ្ច្រាសពីមូលនិធិប្រទេសកំពុងអភិវឌ្ឍន៍(LDCF) គឺជាមូលនិធដែលមានចំនួនគម្រោងដែលបានអនុម័តច្រើនបំផុត(១៩៩ គម្រោង) ក្នុងប្រទេសចំនួន៥២ខុសគ្នា បើទោះបីជាគម្រោងឯកជនមានចំនួនតូចៗក៏ដោយ។ មូលនិធិបន្សាំ និងមូលនិធិអាកាសធាតុពិសេស(SCCF) បានអនុម័តដែលមានចំនួនប្រហាក់ប្រហែលគ្នា ដោយមានការកើនឡើងនៃការអនុម័តមូលនិធិនេះពី ២២% ទៅ៤១%។ មូលនិធិបន្សាំដែលទទួលបានពីការរួមចំណែកពីចំណូលពីគម្រោងអភិវឌ្ឍន៍ស្អាតនៅតែប្រឈមនឹងការធ្លាក់ចុះនៃតម្លៃកាបូន និងការចូលរួមពីប្រទេសឧស្សាហកម្ម។ការធ្លាក់ចុះកើតចេញពីការចូលរួមផ្តល់ជំនួយឥតសំណងពីប្រទេសអភិវឌ្ឍន៍ផងដែរ។

### *តារាង១៖ ការគាំទ្រមូលនិធិលើការបន្សាំពេញលេញ (២០០៣-២០១៤)*

| មូលនិធិ | ប្តេជ្ញា(លាន) | ការផ្តល់ | ការអនុម័ត |
|---|---|---|---|
| កម្មវិធីសាកល្បងភាពធន់នឹងអាកាសធាតុ | 1,160 | 973.0 | 796. |
| មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច(LDCF) | 914 | 903.0 | 733 |
| កម្មវិធីបន្សាំសម្រាប់កសិកម្មខ្នាតតូច(ASAP) | 352 | 300.6 | 149. |
| មូលនិធិប្រែប្រួលអាកាសធាតុពិសេស(SCCF) | 347 | 336.0 | 253 |
| មូលនិធិបន្សាំ(AF) | 226 | 213.7 | 231. |




*ក្រាហ្វិច៤៖ ការប្ដេជ្ញា និងការផ្ដល់មូលនិធិទៅមូលនិធិបន្សាំ*

ជាយូរមកហើយ ប្រទេសចក្រភពអង់គ្លេស តាមរយៈមូលនិធិអាកាសធាតុអន្តរជាតិ អាឡឺម៉ង់ ស៊ុយអែត និងកាណាដា បានចូលរួម៦៩%នៃថវិកាសរុប៣ពាន់លានដុល្លាអាមេរិចដែលបានប្ដេជ្ញាសម្រាប់មូលនិធិបន្សាំ ក្រៅពីនេះលុយប្រហែលជា ២.៧២ពាន់លានដុល្លាត្រូវបានផ្ដល់ជូន។ ៧៩%នៃហិរញ្ញប្បទានដែលបានផ្ដល់ជូនត្រូវបានអនុម័តដើម្បីគាំទ្រដល់គម្រោង និងកម្មវិធី។ កង្វះចន្លោះរវាងចំនួនមូលនិធិដែលបានប្ដេជ្ញា និងមូលនិធិដែលបានផ្ដល់នៅមានទំហំតូចប្រហែលជា ៩%។ នេះបញ្ជាក់ថាមូលនិធិបន្សាំបានដើរស្របតាមផែនការបើទោះបីជាមូលនិធិដែលបានទូទាត់ជាក់ស្ដែងពិបាកទទួលបានក៏ដោយ។




*ក្រាហ្វិច៥: មូនិធិដែលបានគាំទ្រលើការបន្សាំពេញលេញ*

កម្រិតតំបន់ មូលនិធិបន្សាំបានផ្តល់ដោយផ្ទាល់ជាដំបូងដល់តំបន់អាស៊ី និងអនុតំបន់អាហ្វ្រិចសាហារ៉ាន់ និងប៉ាស៊ីហ្វិច ដូចគ្នាទៅនឹងគម្រោង សកម្មភាព និងកម្មវិធីសាកលនៅក្នុងប្រទេសអាមេរិចឡាទីន និងការីបៀន។ ប្រទេសទាំង ២០ដែលទទួលបានចំនួនច្រើនជាងគេបំផុតពីមូលនិធិបន្សាំ(ក្នុងចំណោម ១១៨ប្រទេស) ទទួលបានថវិកាសុរប ៥៤%នៃថវិកាអនុម័តសរុប ដែលបង្ហាញពីចំនួនតិចជាងមូលនិធិសម្រាប់ការកាត់បន្ថយ (ដែលមានប្រទេស ២០ទទួលបានថវិកាសរុប ៨៩%នៃថវិកាដែលបានអនុម័ត)។ ប្រទេសដែលបានជំនួយច្រើនបំផុតដូចជា បង់ក្លាដេស នេប៉ាល់ ណៃជឺ ម៉ូហាប៊ីក ហ្សែមបៀរ ប្រទេសនីមួយៗបានទទួលពី ៩៤ ទៅ ១៩០លានដុល្លារអាមេរិច (ក្នុងនោះ ៥ ជាប្រទេសដែលទទួលជំនួយពីគម្រោង PPCR) ហើយប្រទេសទាំងប្រាំដែលទទួលបានមូលនិធិបន្សាំតិចតួចបំផុតរួមមាន សូម៉ាលី និងសាធារណៈរដ្ឋអាហ្វ្រិចកណ្តាល ទាំងពីរនេះជាប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុក្នុងពិភពលោក បើយោងលើការវាយតម្លៃភាពងាយរងគ្រោះផ្សេងៗ ហើយបច្ចុប្បន្នទទួលបានប្រហែល ៨លាន ទៅ ១០លានដុល្លារអាមេរិចពីមូលនិធិបន្សាំអាកាសធាតុ។

ទំហំនៃអ្វីដែលស្ថាប័នគម្រោងបន្សាំមានគឺមានភាពទូលំទូលាយ។ មូលនិធិខ្នាតធំដែលបានអនុម័តថ្មីៗគឺជាមូលនិធិសកម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងកសិកម្មខ្នាតតូច(ASAP) សម្រាប់តំបន់ខ្ពង់រាប(ASHA) ថវិកា១៥លានដុល្លាដែលផ្តល់ឱ្យប្រទេសនេប៉ាល់គឺមានគោលបំណងលើការពង្រឹងផែនការសកម្មភាពបន្សាំកម្រិតមូលដ្ឋាន(LAPA)សម្រាប់អនុវត្តន៍ការងារនៃកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ(NAPA) នៅមូលដ្ឋាន និងកម្ចីសម្បទានរបស់កម្មវិធី PPCR លើគម្រោងកាត់បន្ថយភាពងាយរងគ្រោះនៃគ្រោះមហន្តរាយ(១៥លានដុល្លារ) ក្នុងប្រទេស St. Lucia ដែលទទួលបានមូលនិធិដើម្បីគាំទ្រលើគម្រោងលំនៅដ្ឋានសរុប ១៧៤000 ដោយកាត់បន្ថយការបរាជ័យនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ កែលម្អការស្វែងយល់ជាទូទៅកម្រិតជាតិលើហានិភ័យ ការស្តារហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយសារមហន្តរាយធម្មជាតិ ។




*ក្រាហ្វិច ៦៖ ការទូទាត់ថវិកានៃហិរញ្ញប្បទានបន្សាំ*

## ៦.៣ មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងពិភពលោក

របាយការណ៍លើកទី៥ ដែលបានសិក្សាដោយក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុបានបង្ហាញថា សីតុណ្ហភាពនឹងបន្តកើនឡើងដែលគួរតែកម្រិតត្រឹម២អង្សាសេ ទើបផលប៉ះពាល់ធ្ងន់ធ្ងរអាចជៀសវាងបាន ហើយឱកាសក្នុងសកម្មភាពការកាត់បន្ថយឧស្ម័នត្រូវតែធ្វើឱ្យឆាប់បំផុត។ របាយការណ៍នេះបានប៉ាន់ស្មានថា ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងត្រូវកាត់បន្ថយឱ្យបានយ៉ាងហោចណាស់ ៤០ ទៅ៧០% នៅឆ្នាំ២០៥០ ដោយធៀបនឹងកម្រិតឆ្នាំ២០១០ ដើម្បីសម្រេចបានគោលដៅនេះ (IPCC, 2014)។ បន្ទុកដ៏ធំនេះនឹងរំខានដល់ប្រទេសអភិវឌ្ឍន៍ក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលនៅសេសសល់ ប៉ុន្តែវាជាការចាំបាច់ណាស់ដែលប្រទេសកំពុងអភិវឌ្ឍន៍ត្រូវចូលរួមចំណែកដល់ការកាត់បន្ថយឧស្ម័ន ដើម្បីដាក់បញ្ចូលទៅក្នុងផែនការរបស់ពួកគេដោយការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍កាបូនទាប។ មូលនិធិអាកាសធាតុអន្តរជាតិអាចជួយប្រទេសក្រីក្រក្នុងការអនុវត្តផែនការសកម្មភាពកាត់បន្ថយអាទិភាព រួមមានថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងការដឹកជញ្ជូនដោយនិរន្តរភាពជាងមុន។




### *ក្រាហ្វិច៧៖ មូលនិធិគាំទ្រដល់ការកាត់បន្ថយ*

តើអ្វីដែលហៅថាមូលនិធិអាកាសធាតុដែលផ្តោតលើការកាត់បន្ថយ?តារាងទី ២បង្ហាញអំពីមូលនិធិអាកាសធាតុដែលគាំទ្រអាទិភាពលើកសកម្មភាពកាត់បន្ថយក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មូលនិធិនេះមានភាពខុសគ្នាខ្លាំងនៅក្នុងទំហំនៃគម្រោង និងកម្មវិធីកាត់បន្ថយ ពួកគេអាចជាធាតុផ្សំ និងចំនួនដែលបានគាំទ្រដោយប្រទេសកំពុងអភិវឌ្ឍន៍។ ជាឧទាហរណ៍ គម្រោងដែលបានអនុម័តចំនួន៦៩ ផ្តល់ផលប្រយោជន៍តិចតួចដល់ទីផ្សារសេដ្ឋកិច្ចក្រោមមូនិធិបច្ចេកវិទ្យាស្អាត(CTF)មានចំនួនថវិកា ៣.៨ ពាន់លានដុល្លាដែលបានអនុម័តជាកម្មវិធីខ្នាតធំ និងមូលនិធិកម្ចី។ ដោយប្រាស់ចាកទៅនឹងគម្រោងតូចជាង៤០០ គម្រោងដែលទទួលបានពីមូលនិធិឥតសំណងពី GEF ជំហានទី៤ និងទី៥ ដែលជួយដល់ប្រទេសក្រីក្របំផុត ប្រហែលជាងពាក់កណ្តាលនៃចំនួននេះ។ ប្រព័ន្ធមូលនិធិជំហានទី៥ ដែលបានផ្តោតលើការវិភាជន៍

ធនធានប្រកបដោយតម្លាភាព(STAR) បានផ្តល់ជាចំនួនត្រីគុណដល់ប្រទេសដែលបានកំណត់នឹងទទួលបានមូលនិធិពី៥០ ទៅ ១៤៤ ដោយអនុលោមតាមប្រទេសកំពុងអភិវឌ្ឍន៍ដែលមានចំណូលកម្រិតទាបអាចទទួលបានមូលនិធិខ្នាតតូចសម្រាប់គម្រោងកាត់បន្ថយ(GEF,2011)។ ម្យ៉ាងវិញទៀត CTF មានបំណងប្រើប្រាស់ចំនួនសរុបនៃកម្ចីដើម្បីសម្រេចផែនការពង្រីករបស់ខ្លួននៅក្នុងក្រុមប្រទេសដែលបានជ្រើសរើសជាកាសាកល្បង។

កម្មវិធីពង្រីកថាមពលកកើតឡើងវិញ(SREP) នៃមូលនិធិវិនិយោគអាកាសធាតុដែលផ្តោតសំខាន់លើការផលិតថាមពលកកើតឡើងវិញ និងការកែលម្អការទទួលបានថាមពលក្នុងប្រទេសក្រីក្រដែលមានគម្រោងអនុម័តសរុប ១៤គម្រោង កាលពីខែកញ្ញា ឆ្នាំ២០១៤ ប៉ុន្តែមិនទាន់បានទូទាត់ការចំណាយនៅឡើយទេ។

*តារាង២៖ មូលនិធិផ្តោតអាទិភាពលើការកាត់បន្ថយ*

| មូលនិធិ | ការប្តេជ្ញា (USD) | ការផ្តល់ជូន | អនុម័ត | ចំនួនគម្រោងដែលបានអនុម័ត |
|---|---|---|---|---|
| មូលនិធិបច្ចេកវិទ្យាស្អាត (CTF) | 5,242 | 4,599 | 3,840 | 69 |
| កញ្ចប់មូលនិធិបរិស្ថានពិភពលោក៤(GEF 4) | 754 | 754 | 956 | 240 |
| កញ្ចប់មូលនិធិបរិស្ថានពិភពលោក៥(GEF 5) | 1,350 | 777 | 799 | 232 |
| មូលនិធិថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពលពិភពលោក (GEEREF) | 170 | 164 | 89.07 | 11 |
| កម្មវិធីពង្រីកថាមពលកកើតឡើងវិញសម្រាប់ប្រទេសចំណូលទាប (SREP) | 521 | 506 | 135.99 | 14 |

រហូតមកដល់ពេលនេះ សហរដ្ឋអាមេរិច ជប៉ុន អាឡឺម៉ង់ និងបារាំងបានប្តេជ្ញាផ្តល់នូវមូលនិធិប្រាំប្រភេទនៅក្នុងតារាង១ ប្រហែលជា ៧៧%នៃថវិកាប្តេជ្ញាចំនួន ៩ពាន់លានដុល្លារ។ ប្រហែលជា ៥.៣ពាន់លានដុល្លារអាមេរិចបានផ្តល់ដោយប្រទេសទាំងនេះដែលបានដាក់រួចរាល់ហើយ។ ៥.៨ពាន់លានដុល្លារ ឬ៨៦% នៃថវិកាដែលបានផ្តល់សរុបដោយម្ចាស់ជំនួយត្រូវបានអនុម័តសម្រាប់គម្រោង ឬកម្មវិធីកាត់បន្ថយដែលបានទូទាត់ដោយតម្លាភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅថ្នាក់តំបន់។

មូលនិធិត្រូវបានទូទាត់នៅកម្រិតជាតិ មានប្រទេសចំនួន ២០ ទទួលបាន៨៨%នៃមូលនិធិគាំទ្រលើការកាត់បន្ថយ។ ប្រទេសកំពុងអភិវឌ្ឍន៍ដែលត្រូវការថវិកាបន្ថែមសម្រាប់សកម្មភាពកាត់បន្ថយរួមមាន ម៉ារុក(USD 615.51 លានដូល្លារ),ឥណ្ឌា (USD 592.08លាន), ម៉ិចស៊ិចកូ(USD 570.98លាន),

អាហ្វ្រិចខាងត្បូង (USD 485.81 លាន) និងឥណ្ឌូនេស៊ី(USD 382.86 លាន)គឺជាប្រទេសដែលត្រូវទទួលជំនួយផ្នែកកាត់បន្ថយកម្រិតខ្ពស់បំផុត។ មានភាពតានតឹងរវាងឱកាសនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ខ្នាតធំជាក់ស្តែងនៅក្នុងប្រទេសតូចៗ និងការវិនិយោគនៅក្នុងដំណោះស្រាយកម្រិតតូចដែលប្រទេសកំពុងអភិវឌ្ឍន៍អាចទទួលបានប្រយោជន៍។ គម្រោងដែលទទួលបានការគាំទ្រដោយ GEF និង SREP បានកែលម្អការទទួលបានថាមពល សម្រាប់ជនក្រីក្រដោយគាំទ្រលើអគ្គិសនីជនបទដោយប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ។ អាទិភាពរបស់គម្រោងកាត់បន្ថយទទួលបានហិរញ្ញប្បទានគាំទ្រដើម្បីលើកគម្រោងថាមពលកកើតឡើងវិញ ឬប្រសិទ្ធិភាពថាមពលដែលមានចំនួនច្រើនជាង ៤០% សម្រាប់គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីការផលិតថាមពល និងប្រើប្រាស់។ ប្រទេសម៉ារ៉ុក និងឥណ្ឌាបានទទួលថវិកាចំនួន ៤០០ លានដុល្លារ កាលពីឆ្នាំមុនសម្រាប់គម្រោងពង្រីកគម្រោងថាមពលសូឡា។ ហិរញ្ញប្បទាន សម្រាប់គម្រោងកាត់បន្ថយ ដើម្បីគាំទ្រដល់ដំណោះស្រាយការដឹកជញ្ជូនដែលបញ្ចេញកាបូនទាបដោយនិរន្តរភាពជាងមុន ពិសេសហេដ្ឋារចនាសម្ព័ន្ធទីក្រុង។




*ក្រាហ្វិច៨: ការទូទាត់ហិរញ្ញប្បទានសម្រាប់ការកាត់បន្ថយថ្នាក់តំបន់*

# ៧.ដំណើរការរៀបចំផែនការជាតិបន្សាំការប្រែប្រួលអាកាសធាតុ

## ៧.១ ផែនការរដ្ឋាភិបាល និងគោលនយោបាយឆ្លើយតបការប្រែប្រួលអាកាសធាតុ

ផែនទីបង្ហាញផ្លូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាថា កាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងសមត្ថភាពបន្សាំនិងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅក្នុងឆ្នាំ២០១៤ ផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣(ផ.យ.ប.ក.) និងគោលនយោបាយជាតិអភិវឌ្ឍន៍បៃតងនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង ២០១៣-២០៣០ ត្រូវបានអនុម័ត។

ផ.យ.ប.ក. ២០១៤-២០២៣ បានកំណត់ចង្កោមសកម្មភាពដែលត្រូវអនុវត្តន៍ក្នុង ៣ ដំណាក់កាលគឺ

- ២០១៣-២០១៤៖ បានរៀបចំស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់អនុវត្តន៍ ផ.យ.ប.ក. រៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃថ្នាក់ជាតិ និងសូចនាករ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (២០១៤-២០១៨) របស់ក្រសួងតាមវិស័យ។

- ២០១៤-២០១៨៖ បន្តគាំទ្រការអនុវត្តសកម្មភាពជំហានទី១ ដោយពង្រីកការអនុវត្តដែលគ្របដណ្តប់ផ្សេងៗទៀត ដូចជាការចុះបញ្ជីដើម្បីទទួលបានសេចក្តីទុកចិត្ត(Accreditation) ពីមូលនិធិបន្សាំ អាកាសធាតុបៃតង និងការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងអន្តរវិស័យតាមកម្រិតផ្សេងៗ ប្រតិបត្តិការការតាមដាន និងវាយតម្លៃ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងផ្សព្វផ្សាយកម្មវិធី/គម្រោងអាទិភាពមួយចំនួន នៅក្នុងវិស័យដែលបានរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុ(CCAPs)។ អាទិភាពដំបូងគួរផ្តោតសំខាន់លើសកម្មភាពបន្សាំ ប៉ុន្តែសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នឹងត្រូវដាក់បញ្ចូលផងដែរ។

- ២០១៩-២០២៣៖ ផ្តោតទៅលើការសិក្សាស្រាវជ្រាវ និងរៀនសូត្រ ប៉ុន្តែគោលបំណងចម្បងនឹង ផ្តោតលើការពង្រីកករណីដែលជោគជ័យ និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការជាតិ និងថ្នាក់ក្រោមជាតិ។ ការងារនេះនឹងពាក់ព័ន្ធដល់ការបង្កើននូវការប្រើប្រាស់ថវិកាគាំទ្រដល់កម្មវិធីថ្នាក់ជាតិ។

គោលនយោបាយជាតិអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បៃតង(២០១៣-២០២០) ឯកសារទាំងពីរនេះត្រូវបានអនុម័តនៅក្នុងខែមីនា ឆ្នាំ២០១៣។ គោលបំណងនោះគឺអភិវឌ្ឍន៍កំណើនសេដ្ឋកិច្ចបៃតងដោយប្រើប្រាស់ធនធានជាតិដោយមានប្រសិទ្ធភាព និរន្តរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង ហិរញ្ញវត្ថុបៃតង ឥណទានបៃតង និងការវិនិយោគបៃតង។ ទំហំការងារមានភាពទូលំទូលាយជាង ប៉ុន្តែមានការត្រួតគ្នាជាមួយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយបរិស្ថាននានា។ នៅក្នុងឆ្នាំ២០០៦ កម្ពុជាបានអនុម័តកម្មវិធី NAPA ដែលឥឡូវនេះអស់សុពលភាព និងមានការពាក់ព័ន្ធតិចតួចណាស់។

ក្នុងឆ្នាំ២០១៥ កម្ពុជាបានផ្ញើរនូវរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ជាតិក្នុងការអនុវត្តន៍អនុសញ្ញា UNFCCC ដែលហៅកាត់ថា INDC ទៅលេខាធិការដ្ឋាន UNFCCC ដែលជាផ្នែកមួយនៃការចូលរួម នៅក្នុងកិច្ចប្រជុំសមាជិកភាគីលើកទី២១។ ដំណាក់កាលដំបូង វាបានកំណត់នូវគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នពីការប្រើប្រាស់វិស័យថាមពលឱ្យបាន ២៧% (៣.១ មេហ្គាតោនឧស្ម័នកាបូនិច) នៅឆ្នាំ២០៣០ បើប្រៀបធៀបទៅនឹងសេណារ៉ូប្រើប្រាស់ធម្មតា(BAU) និងកំណើនគម្របព្រៃឈើជាតិឱ្យបាន ៦០% នៅឆ្នាំ២០៣០។

ជាទូទៅ ការកាត់បន្ថយជាគោលដៅតិចតួចជាងការបន្ស៊ាំសម្រាប់ប្រទេសកម្ពុជា[11] ។ ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ (CCFF) ត្រូវបានរៀបចំឡើងដោយបង្ហាញអំពីរចនាសម្ព័ន្ធថវិកា និងការកៀរគរហិរញ្ញប្បទានអាកាសធាតុ។ ឯកសារនេះមានគោលបំណងដើម្បីកំណត់ពីការសម្របសម្រួល អាទិភាព និងហិរញ្ញប្បទានសម្រាប់សកម្មភាពបន្ស៊ាំ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ ប្រភពហិរញ្ញប្បទានអាកាសធាតុត្រូវបានកំណត់នៅក្នុង CCFF ដែលបានគូសបញ្ជាក់ពីថវិការដ្ឋាភិបាល ឬប្រភពមកពីមូលនិធិពិភពលោក ព្រមទាំងម្ចាស់ជំនួយទ្វេភាគី និងពហុភាគីផងដែរ។

នៅកម្រិតវិស័យ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុ(CCAPs) បានអនុម័តដោយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់សកម្មភាពដែលពាក់ព័ន្ធនឹងគោលបំណងនៃផែនការយុទ្ធសាស្ត្រ ផ.យ.ប.ក.។ ផែនការសកម្មភាពតាមវិស័យ(CCAPs) រួមបញ្ចូលនូវសកម្មភាពសរុប៦៨ ជាមួយនឹងគោលនយោបាយ ផែនការ ការពង្រឹងសមត្ថភាព ពង្រឹងស្ថាប័ន ៣៩សកម្មភាពទៀតពាក់ព័ន្ធនឹងការផ្តល់សេវាកម្មដល់ក្រុមទទួលផលគម្រោង និង១០សកម្មភាពទៀតពាក់ព័ន្ធនឹងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ។ ជាឧទាហរណ៍ សកម្មភាពមួយដែលបានកំណត់នៅក្នុងវិស័យដឹកជញ្ជូនដែលនឹងអាចមានឥទ្ធិពលដោយផ្ទាល់ទៅដល់វិស័យឯកជន សង្កតភាពទៅនឹងការជំរុញនូវការថែទាំ ការត្រួតពិនិត្យរថយន្តដែលជាផ្នែកមួយនៃការខិតខំប្រឹងប្រែងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ។

## ៧.២ ក្របខ័ណ្ឌស្ថាប័នសម្រាប់ការប្រែប្រួលអាកាសធាតុ

រវាងឆ្នាំ២០០៦ និង២០១៥ ស្ថាប័នសាធារណៈទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (មិនរួមបញ្ចូល REDD+ ដែលបានបញ្ជាក់អំពីស្ថាប័នទទួលបន្ទុក) គឺជាគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលមានតួនាទីក្នុងការសម្របសម្រួលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា (ឧទាហរណ៍៖ ការរៀបចំ សម្របសម្រួលនិងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ការណែនាំផ្នែកច្បាប់ ផែនការ កម្មវិធីដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ)។

ក្នុងខែឧសភា ឆ្នាំ២០១៥ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(ក.ជ.អ.ច.)បានទទួលរាប់រងតួនាទី និងភារកិច្ចនេះពី NCCC និងគណៈកម្មាធិការផ្សេងៗចំនួនបួនទៀត។ ក.ជ.អ.ច. មានសមាសភាពពីរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការពីក្រសួងនានា និងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ បើប្រៀបធៀបទៅនឹង NCCC សមាជិករបស់ ក.ជ.អ.ច.បានកើនឡើង (ក្រសួងជាច្រើនត្រូវបានបញ្ចូល និងអភិបាលនៃគណៈអភិបាលខេត្តផងដែរ)[12] ។ ក.ជ.អ.ច.បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ និងក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ ។

[11] *Cambodia Climate Change Financing Framework*

[12] Source : SNC

ក្រសួងបរិស្ថានបានដើរតួនាទីជាអ្នកដឹកនាំក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា

- នៅក្នុងក្រសួងបរិស្ថាន នាយកដ្ឋានប្រែប្រួលអាកាសធាតុ(DCC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៩។នាយកដ្ឋាននេះមានតួនាទីទទួលខុសត្រូវសកម្មភាពកម្រិតទូលំទូលាយមួយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនិងជាស្ថាប័នបង្គោលរបស់ប្រទេសកម្ពុជាសម្រាប់អនុសញ្ញា UNFCC ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) និងពិធីសារក្យូតូ។ នាយកដ្ឋានមានតួនាទីសម្របសម្រួលក្រុមការងារលើការងារ ឬបញ្ហាពាក់ព័ន្ធប្រែប្រួលអាកាសធាតុ ដូចជា ថាមពល ព្រៃឈើ សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ភាពងាយរងគ្រោះ និងការបន្សាំជាដើម។ល។
- ក្នុងខែកក្កដា ឆ្នាំ២០០២ ក្រសួងបរិស្ថានត្រូវបានចាត់តាំងជាអាជ្ញាធរជាតិសម្រាប់យន្តការអភិវឌ្ឍស្អាត(DNA)។ នាយកដ្ឋានប្រែប្រួលអាកាសធាតុត្រូវបានចាត់តាំងជាលេខាធិការដ្ឋានរបស់អាជ្ញាធរជាតិ(DNA)។

ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ(CCTT) ត្រូវបានបង្កើតឡើងក្នុងខែឧសភា ឆ្នាំ ២០១១ បានដើរតួនាទីជាក្រុមផ្តល់ប្រឹក្សាដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ជាមួយគ្នាផងដែរ ពួកគេក៏ជាក្រុមដែលផ្តល់នូវការគាំទ្រដល់ក្រសួងពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ។




*ក្រាហ្វិច៩: អង្គការលេខក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព*

# ៨. ការអនុវត្តផែនការជាតិបន្សាំក្នុងប្រទេសកម្ពុជា

## ៨.១ ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការដាក់បញ្ចូលសម្រាប់ដំណើរការរៀបចំគម្រោងបន្សាំ

ផ្អែកលើលទ្ធផលនៃការសិក្សានៅមូលដ្ឋាន និងការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ បង្ហាញថា អ្នកពាក់ព័ន្ធទាំងអស់ត្រូវបានពិគ្រោះយោបល់ពាក់ព័ន្ធនឹងដំណើរការរៀបចំគម្រោង ពិសេសវិធានការបន្សាំ។ ពួកគេបានកំណត់នូវក្រុមដែលងាយរងគ្រោះទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ យោងលើទ្ធផលនៃការពិគ្រោះយោបល់ ព័ត៌មានទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំគម្រោងដើម្បីដាក់សំណើសុំមូលនិធិបន្សាំ។ ផ្អែកលើរបាយការណ៍ពីប្រធានដឹកនាំក្រុមការងារ ការពិគ្រោះយោបល់ បានធ្វើឡើងដូចខាងក្រោមនេះ៖

- ក្រសួងបរិស្ថាន រួមបញ្ចូលនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍តំបន់ការពារ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នាយកដ្ឋានសត្វព្រៃ និងឧទ្យានជាតិ

- ក្រសួងពាក់ព័ន្ធនានារួមបញ្ចូល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងផែនការ ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងអភិវឌ្ឍន៍ជនបទ ជាដើម

- អង្គការមួយចំនួនដូចជា WWF, World Vision, WCS, IUCN, CDRI, MRC, FFI, WA, NTFP, RCOFT, etc.

ការពិគ្រោះយោបល់ចំនួនពីរដងត្រូវបានធ្វើឡើងនៅក្នុងតំបន់ការពារ និងខេត្តគោលដៅ។ គាត់រាយការណ៍ថា យ៉ាងហោចណាស់ ៣៦៤នាក់ និងគណៈកម្មាការគ្រប់គ្រងត្រូវបានសម្ភាសន៍ដើម្បីកំណត់សកម្មភាពអាទិភាពសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ រាល់លទ្ធផលនៃការសិក្សានិងពិគ្រោះយោបល់ត្រូវបានកត់ត្រា និងភ្ជាប់ក្នុងគម្រោងសំណើ។

## ៨.២ ដំណើរការប្រកបដោយប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិបន្សាំ និងការទទួលបានជាសាធារណៈ

មូលនិធិបន្សាំបានប្រើប្រាស់នូវអភិក្រមថ្មីមួយដើម្បីបែងចែកមូលនិធិអាកាសធាតុ។ មូលនិធិនេះជាផ្នែកមួយនៃចំណែកចូលរួមចំនួន ២%ពីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត។ វាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកហិរញ្ញប្បទានអាកាសធាតុដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយចាប់ផ្តើមនូវទិន្នន័យគោលដែលទាបបំផុត និងប្រតិបត្តិការដោយមានតម្លាភាពខ្ពស់បំផុត។ វឌ្ឍនភាពដំបូងលើក្របខ័ណ្ឌលទ្ធផលបានជួយដល់ប្រតិបត្តិការមូលនិធិ និងជំរុញការរៀនសូត្រ។ ការសិក្សាប្រភពមូលនិធិថ្មីប្រមូលបានតាមរយៈកម្មវិធី CDM បានផ្តល់នូវចំណូលទាបជាងការរំពឹងទុក។ បើទោះបីយ៉ាងនេះក្តី ការប៉ាន់ប្រមាណ មូលនិធិនៅតែចោទជាសំណួរនៅឡើយ។ ការត្រួយត្រាយរៀបចំមូលនិធិដែលអាចទទួលបានដោយផ្ទាល់ "direct access" មានបំណងកាត់បន្ថយការចំណាយ និងភាពស្មុគស្មាញនៃការទទួលបានមូលនិធិ និងពង្រឹង

ប្រទេសដែលទទួលមូលនិធិឱ្យក្លាយជាម្ចាស់សម្រាប់គម្រោងដែលបានគាំទ្រ។ ដំណើរការចុះបញ្ជី នៃការផ្តល់សេចក្តីទុកចិត្ត(Accreditation processes) បានបង្កើតឡើងជាច្រើនក្នុងរយៈពេលកន្លងមក ប៉ុន្តែការអនុវត្តជានាបាននូវភាពខ្លាំងផ្នែកសម្របសម្រួល និងភាពជាម្ចាស់នៃកម្មវិធីដែលបានឆ្លងកាត់ពហុភាគីពាក់ព័ន្ធក្នុងប្រទេសនឹងមានបញ្ហាប្រឈម។ មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ឥទ្ធិពលនៃគម្រោងនឹងកែប្រែឱ្យទៅជាមូលដ្ឋាននីយកម្ម និងមានតម្រូវការពិតប្រាកដដើម្បីជានាថាអ្នកពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន និងថ្នាក់ក្រោមជាតិទទួលបានផលប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងបន្សាំ និងមូលនិធិបន្សាំ ។ សកម្មភាពគាំទ្រមាននៅកម្រិតមួយដែលមានលក្ខណៈចម្រាស់ភាព។ ការចូលរួមនៅកម្រិតផ្សេងៗគ្នាគឺជាចំណុចផ្តោតដ៏សំខាន់របស់មូលនិធិបន្សាំ។ រាល់កម្មវិធីដែលបានអនុម័តរួចរួមទាំងសមាសភាគថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវតែផ្តោតលើចំណុចទាំងអស់ខាងលើ។

ទំហំកម្មវិធីខ្នាតតូចតម្រូវជម្រើសជាយុទ្ធសាស្ត្រដែលផ្អែកនៅមូលដ្ឋានអាចចូលរួមបាន។ គម្រោងមួយចំនួនបានស្នើនូវលក្ខណវិនិច្ឆ័យទៅនឹងទីតាំងដែលមានសក្តានុពលត្រូវបានពិចារណា បន្ទាប់មកការចូលរួមរបស់អ្នកពាក់ព័ន្ធដើម្បីឈានដល់ការជ្រើសរើសគម្រោងសម្រាប់មូលនិធិបន្សាំនេះ។ គម្រោងខ្លះបានស្នើឱ្យមានការកំណត់លក្ខ័ណ្ឌដែលអាចកែសម្រួលបាននៅពេលដែលកម្មវិធីដំណើរការ។ មានករណីច្រើនណាស់ ជម្រើសគឺអាស្រ័យការចូលរួមពីអ្នកពាក់ព័ន្ធ អាទិភាព និងចំណាប់អារម្មណ៍របស់ដៃគូអនុវត្តន៍នៅកម្រិតមូលដ្ឋាន។

## ៨.៣ ដំណើរការផែនការបន្សាំកម្រិតមូលដ្ឋាន និងការចូលរួមពីសហគមន៍ងាយរងគ្រោះ

កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ត្រូវបានរៀបចំឡើងដោយអនុលោមតាមសេចក្តីសម្រេចលេខ២៨ នៅក្នុងកិច្ចប្រជុំសមាជិកភាគីអនុសញ្ញា UNFCCC លើកទី០៧។ ការរៀបចំ NAPA អនុលោមតាមរយៈដំណើរការចូលរួមយ៉ាងពេញលេញពីគ្រប់ភាគីពាក់ព័ន្ធដែលទទួលរងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍៖ ស្ថាប័នរដ្ឋាភិបាល ស្ថាប័នសិក្សាធិការ អ្នកសិក្សាស្រាវជ្រាវ តំណាងសហគមន៍ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

**គោលបំណងនៃកម្មវិធី NAPA**

- ស្វែងយល់អំពីលក្ខណៈសំខាន់ៗនៃហានិភ័យអាកាសធាតុក្នុងប្រទេសកម្ពុជា( ទឹកជំនន់ រាំងស្ងួត ព្យុះ ខ្យល់កន្ត្រាក់ កំណើននីវ៉ូទឹកសមុទ្រ និងជម្ងឺគ្រុនចាញ់)
- ស្វែងយល់អំពីយន្តការដោះស្រាយទៅនឹងហានិភ័យអាកាសធាតុ និងការប្រែប្រួលអាកាសធាតុនៅកម្រិតមូលដ្ឋាន
- លើកកម្ពស់ផលិតភាពកសិកម្មតាមរយៈការពង្រីកនូវប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកដើម្បីកាត់បន្ថយភាពងាយរងគ្រោះទៅនឹងគ្រោះធម្មជាតិ និង

- កំណត់នូវសកម្មភាពបន្សាំអាទិភាពចំពោះហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជាមិនបានរៀបចំផែនការបន្សាំកម្រិតមូលដ្ឋាននោះទេ ប៉ុន្តែរដ្ឋាភិបាលបានលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការដែលមានស្រាប់ ពិសេសកម្មវិធីវិនិយោគឃុំជាដើម។ ក.ជ.អ.ប របស់ក្រសួងមហាផ្ទៃមានតួនាទី និងភារកិច្ចចាត់ចែង សម្របសម្រួលការងារនេះដើម្បីគាំទ្រដល់ដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ/កម្មវិធីវិនិយោគឃុំក្នុងប្រទេស កម្ពុជា ។ គម្រោងដែលមានឈ្មោះថា អភិបាលកិច្ចមូលដ្ឋាន និងការបន្សាំកាប្រែប្រួលអាកាសធាតុ ក.ជ.អ.បបានជ្រើសរើសខេត្តចំនួន០២ ស្រុកចំនួន០៨ (៣០ឃុំ)សម្រាប់សាកល្បងគម្រោងបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចល្អ។ ដំណើរការផែនការវិនិយោគឃុំ និងផែនការអភិវឌ្ឍឃុំបានផ្តល់នូវឱកាសដល់សហគមន៍ដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុបានលើកឡើងនូវការព្រួយបារម្ភរបស់ពួកគេតាមរយៈការវាយតម្លៃភាពងាយរងគ្រោះ (VRA)។

# ៩. ស្ថានភាពមូលនិធិបន្សាំនៅក្នុងប្រទេសកម្ពុជា

## ៩.១ ហិរញ្ញប្បទានអាកាសធាតុក្នុងប្រទេសកម្ពុជា

ការចំណាយលើការប្រែប្រួលអាកាសធាតុមានការកើនឡើងគួរកត់សម្គាល់នៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលចាប់ ពី ៣៦៧ពាន់លានរៀលក្នុងឆ្នាំ២០០៩ ទៅដល់ ៨៤៧ ពាន់លានរៀលនៅឆ្នាំ ២០១៤។ ការបែងចែកការចំណាយលើការប្រែប្រួលអាកាសធាតុធៀបនឹងចំណូលក្នុងស្រុកសរុបក៏មានការកើនឡើងផងដែរ ពី ០,៩%នៃGDP ក្នុងឆ្នាំ២០០៩ ទៅ ១,៣% នៃGDP ក្នុងឆ្នាំ២០១៤ តែមានចំណុចមួយធ្លាក់ចុះនៅក្នុងឆ្នាំ២០១១ (០,៨% នៃGDP)។ នៅក្នុងឆ្នាំ២០០៩ និង២០១០ត្រូវបានកត់សម្គាល់ថាមានការចំណាយខ្ពស់លើមហន្តរាយដែលបានកើតឡើងដោយសារព្យុះកេសាណា និងទឹកជំនន់ចុងឆ្នាំ ២០០៩។

នៅឆ្នាំ២០១៤, ១/៣នៃការចំណាយសាធារណៈបានចូលរួមពេញលេញ ឬដោយផ្នែកលើការប្រែប្រួលអាកាសធាតុ (រហូតដល់ ២៨,៩% ក្នុងឆ្នាំ២០០៩)។ ការចំណាយលើការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនឹង ទំងន់/បន្ទុកអាកាសធាតុត្រូវបានអនុវត្តន៍ ហើយហិរញ្ញប្បទានអាកាសធាតុបានកើនឡើង ៤ ,១%នៃការចំណាយសាធារណៈ (មានការកើនឡើងពី ៣,៣%ក្នុងឆ្នាំ២០០៩)។

*ក្រាហ្វិច2: ការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ(2009-2014)*

***តារាង៣៖ ការបែងចែកការចំណាយលើការប្រែប្រួលអាកាសធាតុធៀបនឹងការចំណាយសរុប និងGDP***

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|---|
| ការចំណាយលើការប្រែប្រួលអាកាសធាតុពាក់ព័ន្ធនឹងចំណាយសរុប | 28.9% | 28.9 % | 29.8% | 30.9% | 28.7% | 33.3% |
| ការចំណាយលើការប្រែប្រួលអាកាសធាតុ ទៅនឹងការចំណាយសរុប | 3.3% | 3.5% | 2.9% | 3.1% | 3.3% | 4.1% |
| ការចំណាយលើការប្រែប្រួលអាកាសធាតុ ទៅនឹងGDP | 0.9% | 1% | 0.8% | 0.9% | 1% | 1.3% |

បរិមាណវិភាជន៍ពីធនធានក្នុងស្រុក(ថវិកាជាតិ) សម្រាប់ការចំណាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុបានកើនឡើងគួរកត់សម្គាល់ពី ៨៧ ពាន់លានរៀលក្នុងឆ្នាំ២០០៩ ទៅ ២១១ ពាន់លានរៀលក្នុងឆ្នាំ២០១៤។ នៅក្នុងឆ្នាំ២០១៤ ស្ទើរតែមួយត្រីមាស (២៤,៨%) នៃការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុបានទទួលមូលនិធិពីថវិកាជាតិ។ ហិរញ្ញប្បទានខាងក្រៅនៅតែជាប្រភពដ៏ធំសម្រាប់ការចំណាយ។

ហិរញ្ញប្បទានខាងក្រៅមានទំហំធំសម្រាប់ការចំណាយលើការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា។ វាមានការផ្លាស់ប្តូរច្រើនជាងមូលនិធិក្នុងស្រុកដោយមានការធ្លាក់ចុះនៅក្នុងឆ្នាំ២០១១ នេះប្រហែលជាមកពីមានការកើតឡើងដំណាលគ្នានៃការធ្លាក់ចុះមូលនិធិដែលមានទំហំ ប៉ុន្តែទិន្នាការមានភាពវិជ្ជមានដែលមានការកើនឡើងចន្លោះឆ្នាំ២០១៣ និង២០១៤។

មានតែ ៤១% នៃកម្មវិធីដែលផ្តល់មូលនិធិពីខាងក្រៅទាំងនេះត្រូវបានបញ្ជូនតាមរយៈប្រព័ន្ធនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៩ ស្ថានភាពបានផ្លាស់ប្តូរយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ២០១១ ដោយភាគច្រើននៃការចំណាយអាកាសធាតុដែលផ្តល់មូលនិធិខាងក្រៅហូរតាមរយៈប្រព័ន្ធក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៦៧% នៅឆ្នាំ ២០១៤) ដែលភាគច្រើនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានទំហំធំនិង កសិកម្ម គម្រោង។

## ៩.២ ប្រភពមូលនិធិ

តាមរយៈមូលដ្ឋានទិន្នន័យឆ្នាំ 2014 បានបង្ហាញថា ជំនួយអភិវឌ្ឍន៍ផ្លូវការ ប្រទេសស៊ុយអែត សហគមន៍អឺរ៉ុបនិងអង្គការ UNIDO ជាអ្នកផ្តល់ធនធានសំខាន់ក្នុងការទ្រទ្រង់ដល់វិស័យការប្រែប្រួលអាកាសធាតុជាមួយនឹងគណនីចំណាយចំនួន 24,1%, 23,2% និង 11,7% នៃចំនួនប្រភពធនធានសំខាន់ៗសរុបសម្រាប់អាកាសធាតុ។ នៅឆ្នាំ ២០១៥ មូលនិធិជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសម្រាប់ការប្រែប្រួលអាកាសធាតុជាវិស័យមួយដែលសំខាន់គឺថវិកា ៧,១ លានដុល្លារអាមេរិកសម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុចំនួន ១៤,៥% ចាប់ពីឆ្នាំ 2014 ខណៈដែលបញ្ហាបការប្រែប្រួលអាកាសធាតុត្រូវបានគាំទ្រ "សញ្ញាសម្គាល់" បានធ្លាក់ចុះពី 15% ជុំវិញ 159,5 លានដុល្លារឆ្នាំ 2014 ។ វិស័យកសិកម្ម វិស័យដឹកជញ្ជូន និងបរិស្ថានគឺជាវិស័យដែលមានការបញ្ជ្រាបការប្រែប្រួលអាកាសធាតុធំបំផុត "ជាមួយនឹងការរួមបញ្ចូលគ្នា 100 លានដុល្លារអាមេរិក (70% នៃមូលនិធិការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ) ។ បរិស្ថាន ការប្រែប្រួលអាកាសធាតុ, ការធ្វើផែនការទីក្រុង កសិកម្ម និងអភិវឌ្ឍន៍ជនបទគឺជាវិស័យសំខាន់ ដែលបានបញ្ជ្រាបរួមចំណែកធំបំផុតនៃការប្រែប្រួលអាកាសធាតុនៃឥណទានក្នុងវិស័យរបស់ខ្លួនផ្ទាល់។

## ៩.៣ គម្រោងបន្សាំ និងគម្រោងកាត់បន្ថយ

គម្រោងស្រាវជ្រាវនេះបានចាត់ថ្នាក់ចូលទៅក្នុងការបន្សាំអាកាសធាតុនិងការកាត់បន្ថយនិងបានរកឃើញថាភាគច្រើននៃការផ្តល់ហិរញ្ញប្បទាននេះត្រូវវិភាជន៍សម្រាប់គម្រោងការបន្សាំដោយឆ្នាំ។ មូលដ្ឋាននៅលើ CPEIR, ចាប់តាំងពីឆ្នាំ 2009 ដល់ឆ្នាំ 2014 គម្រោងការបន្សាំត្រូវបានកើនឡើងពី 88,84 លានដុល្លារទៅ 207,69 លានដុល្លារ។

*តារាង៤: ការចំណាយសាធារណៈលើសកម្មភាពការបន្សាំ និងកាត់បន្ថយ*

| វិស័យ | ថវិកា២០០៩ (លានដុល្លារ) | ថវិកា២០១០ (លានដុល្លារ) | ថវិកា២០១១ (លានដុល្លារ) | ថវិកា២០១២ (លានដុល្លារ) | ថវិកា២០១៣ (លានដុល្លារ) | ថវិកា២០១៤ (លានដុល្លារ) |
|---|---|---|---|---|---|---|
| កាត់បន្ថយ | 3.04 | 5.56 | 5.10 | 6.19 | 7.88 | 4.12 |
| បន្សាំ | 88.84 | 105.04 | 97.47 | 116.11 | 152.15 | 207.69 |




*ក្រាហ្វិច១១: ការចំណាយសរុបលើសកម្មភាពបន្សាំ និងកាត់បន្ថយផ្អែកលើទិន្នន័យ ODA និងថវិកាជាតិ*

ប្រភព: MEF and CCCA, 2016, CPER 2009-2014




*ក្រាហ្វិច១២: ការចំណាយហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុតាមវិស័យ*

*ប្រភព: CPER 2009-2014*

## ៩.៤ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ

វិភាជន៍តាមវិស័យបង្ហាញពីការផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើប្រព័ន្ធធារាសាស្ត្រផ្លូវជាតិ និងផ្លូវលំជនបទធន់នឹងអាកាសធាតុមានចំនួន រៀល 433 ពាន់លាន 51% នៃការចំណាយសរុបលើអាកាសធាតុបានប៉ាន់ប្រមាណដោយ 20,7% លើឆ្លើយតបគ្រោះមហន្តរាយ, 16% លើការចិញ្ចឹមជីវិតធន់នឹងអាកាសធាតុ (រួមទាំងវិស័យកសិកម្ម) 3,4% លើសុខភាព, 1,3% លើវិស័យថាមពលនិង 1% លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

ការចំណាយធំបំផុតរបស់ក្រសួងនានា រួមមានធនធានទឹកក្រសួងនិងឧតុនិយម(MOWRAM), ក្រសួងសាធារណៈការនិងដឹកជញ្ជូន (MPWT) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងសុខាភិបាល (MoH) និង ក្រសួងបរិស្ថាន (MoE)។ សរុបមក, តម្រូវការ CCAP ជាមធ្យមប្រចាំឆ្នាំរបស់ក្រសួងទាំង 15 គឺ 716 ពាន់លានរៀល។ នៅឆ្នាំ 2014 ការចំណាយទាក់ទងនឹងអាកាសធាតុបានប៉ាន់ប្រមាណថាសម្រាប់ក្រសួងដូចគ្នាទាំងនេះគឺ 778 ពាន់លានរៀល (847 ពាន់លានរៀលប្រសិនបើភាគីពាក់ព័ន្ធផ្សេងទៀតត្រូវបានរួមបញ្ចូល)។ នេះបង្ហាញថាតម្រូវការហិរញ្ញប្បទានរបស់កម្ពុជាបានបញ្ជាក់នៅក្នុង CCAP គឺមិនប្រាកដប្រជានិងពិតជាស្របជាមួយនឹងកម្រិតនៃការផ្តល់ហិរញ្ញប្បទានដែលអាចរកបាន។ កម្ពុជាពិតជាមានបំណងក្នុងការគៀគរធនធានស្របជាមួយនឹងសេណារីយ៉ូកំណើនខ្ពស់បានបង្ហាញនៅក្នុងក្របខ័ណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ (832 ពាន់លានរៀលសម្រាប់ឆ្នាំ 2014 ទល់នឹង 792 ពាន់លានរៀលក្នុងសេណារីយ៉ូកំណើនទាប)។

ទោះជាយ៉ាងណាវាគួរឱ្យកត់សម្គាល់ថាភាគច្រើននៃមូលនិធិនេះបានចំណាយនៅឆ្នាំ 2014 ត្រូវបានកម្មវិធីអាទិភាពការអភិវឌ្ឍ និងការបើកដំណើរការ CCAPs នេះ។ ជាលទ្ធផលការចំណាយទាក់ទងនឹងអាកាសធាតុមិនត្រូវអនុលោមយ៉ាងពេញលេញជាមួយនឹងផែនការទាំងនេះហើយនៅតែមានគម្លាតមូលនិធិសម្រាប់សកម្មភាពថ្មីដែលបានរួមបញ្ចូលនៅក្នុងការ CCAPs នេះ។ វាមានឱកាសដើម្បីបង្កើនកម្រិតនៃអាកាសធាតុភាពពាក់ព័ន្ធនៃការចំណាយទាំងនេះផងដែរ។ ឧទាហរណ៍, ខណៈពេលដែលប្រព័ន្ធធារាសាស្ត្រមួយរួមចំណែកដល់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈការកាត់បន្ថយការពឹងផ្អែកលើរបបទឹកភ្លៀងពាក់ព័ន្ធអាកាសធាតុរបស់ខ្លួនគួរតែខ្ពស់ជាងនេះ ប្រសិនបើវាត្រូវបានរចនាឡើងជាពិសេសដល់កម្មវិធីដែលគិតគូរពីការប្រួលអាកាសធាតុ(ឧទាហរណ៍៖ ទប់ទល់នឹងគ្រោះទឹកជំនន់)។ សម្លឹងមើលក្រសួងដែលមាន CCAP, ការវិភាជន៍ការចំណាយដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនេះគឺមានភាពទូលំទូលាយស្របជាមួយនឹងការបែងចែកធនធានតាមវិស័យនៅក្នុងCCAPs នេះ។ ក្រសួងធនធានទឹក និងឧតុនិយម (42,7%), ក្រសួងសាធារណៈការ និងដឹកជញ្ជូន (22,6%), ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ (8,9%) និងក្រសួងអភិវឌ្ឍន៍ជនបទ (8%) គឺក្រសួងសំខាន់បំផុតនៃការចំណាយដែលទាក់ទងនឹងអាកាសធាតុ។

ទោះជាយ៉ាងណា, ខណៈពេលដែលហេដ្ឋារចនាសម្ព័ន្ធ (ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងក្រសួងរ៉ែ និងថាមពល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍) ទទួលបានអត្ថប្រយោជន៍គ្រប់គ្រាន់នៃការផ្តល់មូលនិធិ ក្នុងនោះរួមមាន រួមទាំងមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍, CCAP របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតែមិនទាន់បានទទួលមូលនិធិ (តែ 45% នៃសេណារីយ៉ូសុទិដ្ឋិនិយមមួយ សន្មត់ថាហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុទាំងអស់ត្រូវស្របជាមួយ CCAP) ។ នេះក៏ជាករណីរបស់ក្រសួងបរិស្ថាន (34% ប៉ុណ្ណោះដែលបានផ្តល់មូលនិធិ), ក្រសួងសុខាភិបាល (ដែលផ្តល់មូលនិធិ 76%), ក្រសួងឧស្សាហកម្ម និងសិប្បកម្ម(ដែលផ្តល់មូលនិធិ 61%) និងក្រសួងអប់រំ យុវជន និងកីឡា(ដែលផ្តល់មូលនិធិ 7%) ព្រមទាំងក្រសួងផ្សេងៗទៀតបានទទួលហិរញ្ញប្បទានមានទំហំតូច។

ដោយសារតែ CCAPs ត្រូវបានអនុម័តជាលើកដំបូងនៅក្នុងឆ្នាំ 2014 តែវាជាការមិនទំនងដែលថាផែនការទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងលើហិរញ្ញប្បទានអាកាសធាតុសម្រាប់ឆ្នាំនោះ។ ការវាយតម្លៃជាក់លាក់បន្ថែមទៀតនៅថ្នាក់ក្រសួងនឹងត្រូវបានធ្វើឡើងជាផ្នែកមួយនៃដំណើរត្រួតពិនិត្យមើលសម្រាប់ CCAPs មួយ។ ខណៈពេលហិរញ្ញប្បទានអាកាសធាតុគឺអាចរកបាននិងទូលំទូលាយស្របជាមួយនឹងអាទិភាពតាមវិស័យនោះមានឱកាសដើម្បីកែលម្អការបែងចែកមូលនិធិទាំងនេះទៅនឹងសកម្មភាពមានសក្តានុពលខ្ពស់បំផុតបានកំណត់នៅក្នុង CCAPs។




*ក្រាហ្វិច១៣: ការវិភាជន៍ ២០១៤ការចំណាយលើការប្រែប្រួលអាកាសធាតុតាមក្រសួង*

## ១០. គម្រោងមូលនិធិបន្សាំនៅក្នុងប្រទេសកម្ពុជា

គម្រោងមូលនិធិបន្សាំនៅក្នុងប្រទេសកម្ពុជាមានចំណងជើងថា “បង្កើនការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុនៃការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ការពារក្នុងប្រទេសកម្ពុជា” គឺជាគម្រោងបន្សាំមួយដែលបានធ្វើនៅក្នុងតំបន់ការពារដែលបានជ្រើសរើសចំនួន៥ នៅក្នុងប្រទេសកម្ពុជា។ គម្រោង

នេះបានអនុម័តកញ្ចប់ថវិកាចំនួន ៤,៩៥៤,២៧៣ ដុល្លារ ដែលចាប់ផ្តើមអនុវត្តន៍ចាប់ពីខែតុលា ឆ្នាំ ២០១២ ដល់ខែមករា ឆ្នាំ២០១៧។ គម្រោងនេះបានទទួលមូលនិធិដំបូងចំនួន ១,១០៧,២៣១ ដុល្លារ នៅខែមករា ឆ្នាំ២០១២។ មូលនិធិបន្សាំនេះបានអនុវត្តន៍ជោគជ័យលើផ្នែកមួយចំនួននៃគម្រោងដែលបានអនុវត្តន៍ទៅលើការដាំដើមឈើ ការបង្កើតអាងស្តុកទឹកសម្រាប់សហគមន៍ ការពង្រឹងសមត្ថភាពក្នុងការដោះស្រាយបញ្ហា -ល-។ គោលដៅរបស់គម្រោងក្នុងឆ្នាំ២០១៥ នឹងទៅថ្ងៃអនាគតផ្តោតសំខាន់ទៅលើការពង្រីកតំបន់ កសិកម្មធម្មជាតិតាមរយៈ CPAs (ឧ. សួនបន្លែ និងការចិញ្ចឹមសត្វជាដើម) ការបង្កើតតំបន់ទេសចរណ៍ធម្មជាតិ និងការជំរុញអោយដាំដើមឈើឡើងវិញនៅក្នុងតំបន់នោះ។

គម្រោនេះស្ថិតនៅក្នុងអនុវត្តន៍របស់កម្មវិធីបរិស្ថានជាតិ និងក្រសួងបរិស្ថានកម្ពុជា។ គម្រោងនេះមានគោលបំណងបង្កើនការផ្គត់ផ្គង់ស្បៀងអាហារ និងកាត់បន្ថយការសិករិចរិលដីនៅជីឱកបឹងប្រើយ៍, ជុំធ្លកស្តម្រិច (តំបន់ដែនជម្រកសត្វព្រៃបឹងពែ), រន្ទួកខ្វែង (តំបន់ដែនជម្រកសត្វភ្នំប្រិច) និង ជួបតាសុក (ឧទ្យានជាតិភ្នំគូលែន)។ ជាងនេះទៅទៀតសមិទ្ធិផលសំខាន់ៗនៃគម្រោងសកម្មភាពមានយ៉ាងហោចណាស់ ១,៨៧៥ ហិចតានៃតំបន់ព្រៃដែលបានបំផ្លាញ, រួមបញ្ចូលទាំងការដាំពូជរុក្ខាជាតិឡើងវិញ បង្កើតផ្ទៃដីដាំស្រូវ និងតំបន់ដាំដុះផ្សេងៗទៀតដោយពហុប្រយោជន៍ ប្រភេទដើមឈើណាដែលជួយបង្កើនទិន្នផលដំណាំ, យ៉ាងហោចណាស់១,៩០៧គ្រួសារក្នុងតំបន់កសិកម្ម(រួមទាំងការរៀបចំសួនបន្លែ ក្នុងទីទាំង ០,២ ហិចតានៃដីមួយហិចតា) នៅក្នុងសហគមន៍ជុំវិញតំបន់ព្រៃ ដាំពូជស្រូវបង្កាត់ដែលធន់ទ្រាំទៅនឹងភាពរាំងស្ងួត ដើម្បីបង្កើនសក្តានុពលទិន្នផល ការដាំដុះដោយនិរន្តរភាព និងការប្រើប្រាស់រយៈពេលខ្លីហើយទទួលបានផលចំរុះ ។

ការវាយតម្លៃពីភាពងាយរងគ្រោះនៅក្នុងតំបន់គោលដៅរបស់គម្រោង បានរៀបចំឡើងដោយការប្រឹក្សាដោយទូលាយជាមួយដៃគូពាក់ព័ន្ធ រួមមានស្ថាប័នរដ្ឋ អជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល សហគមន៍រងគ្រោះ(អ្នកទទួលផល) និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត។ លទ្ធផលនៃការវាយតម្លៃបានផ្ទេរទៅជាទិន្នន័យមូលដ្ឋាន និងសកម្មភាពគោលនយោបាយដើម្បីដោះស្រាយទៅនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការបន្សាំសហគមន៍មូលដ្ឋានត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនៃការរៀបចំគម្រោង។

ក្នុងរយៈពេលនៃការចុះទស្សនានៅក្នុងតំបន់របស់គម្រោងក្នុងខែសីហា ឆ្នាំ២០១៦ សមាជិករបស់សហគមន៍តំបន់ការពារបានរាយការណ៍ថា ពួកគេមានឱកាសបានចូលរួមក្នុងការរៀបចំ និងអនុវត្តន៍គម្រោង។ ប្រធានសហគមន៍ម្នាក់បាននិយាយថា " ប្រសិនបើមិនមានគម្រោងមូលនិធីបន្សាំ ព្រៃ និងសត្វព្រៃគឺមិនមាននៅទីនេះទេ។ តំណាងសហគមន៍បាននិយាយថា គម្រោងនេះបានផ្តល់អោយពួកគាត់នូវភាពជាម្ចាស់ការលើការអនុវត្តនិងគ្រប់គ្រងគម្រោង។ ស្ទើរតែទាំងអស់នៃអ្នកទទួលផលមានជីវភាពប្រសើរឡើងតាមរយៈការផ្លាស់ប្តូរមុខរបរ។ ពីមុនការរស់នៅរបស់ប្រជាជនគឺពឹងផ្អែកទៅលើអនុផលព្រៃឈើ និងការកាប់ឈើប៉ុន្តែឥឡូវនេះពួកគាត់បានផ្លាស់ប្តូរមកអនុវត្តន៍កសិកម្មខាងអាកាសធាតុវិញ។

# ១១. ទំនាក់ទំនងជាមួយនឹងផែនការជាតិបន្ស៊ាំ

## ១១.១ ភាពបន្សីគ្នាទៅនឹងកម្រិតជាតិ

ការពិនិត្យជាទូទៅ និងការវិភាគឆ្លុះបញ្ចាំងទៅនឹងការតម្រង់ទិសដ៏ល្អរវាងពាក់ព័ន្ធនឹងគោលនោបាយរបស់រដ្ឋាភិបាលដូចជា ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ផែនការសកម្មភាពលើវិស័យប្រែប្រួលអាកាសធាតុ និង INDC ដូចដែលបានរៀបរាប់នៅក្នុងអនុវិស័យខាងក្រោម៖

## ១១.២ ភាពបន្សីគ្នាទៅនឹងផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ

សកម្មភាពនៅក្នុងផែនការសកម្មភាពក្នុងវិស័យប្រែប្រួលអាកាសធាតុ ដកស្រង់ស្ទើតែទាំងស្រុងពីវិស័យអទិភាព និងស្របទៅនឹងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា។ មានសកម្មភាពចប្បងសរុបចំនួន១៧៨ ដែលសកម្មភាពទាំងអស់មានថវិការគ្របផ្សំសម្រាប់ឆ្នាំ១០១៤ ដល់២០១៨។ តារាងទី ១ គឺកំណត់បង្ហាញពីចំនួនសកម្មភាព CCAPដែលគាំទ្រទៅនឹងគោលបណណងទាំង៨របស់CCCSP។

*តារាង៥៖ ភាពបន្សីគ្នារវាង CCAPs និង CCCSP*

| គោលបំណងជាយុទ្ធសាស្ត្ររបស់ CCCSP | CCAP (ចំនួនសកម្មភាព) | CCAP (%) |
|---|---|---|
| 1. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និង ថាមពល។ | 37 | 14% |
| 2. កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាពនៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ | 51 | 20% |
| 3. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ នៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ បឹង) ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ ទន្លេសាប ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។ | 27 | 10% |
| 4. លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។ | 56 | 22% |
| 5. កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ | 68 | 26% |

| | | |
|---|---|---|
| 6. លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងការខូចខាត។ | 8 | 3% |
| 7. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ | 11 | 4% |
| 8. ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងពិភពលោក។ | 2 | 1% |
| សរុប | 260 | 100% |

សកម្មភាពអាទិភាពចម្បងរបស់ CCAP (សរុប៦៦ភាគរយ) គាំទ្រទៅគោលបំណងយុទ្ធសាស្ត្រទាំង៣ ៖

- គោលបំណងយុទ្ធសាស្ត្រ ទី៥៖ បង្កើតសមត្ថភាព ចំណេះដឹង និងបណ្តុះបណ្តាលពីការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

- គោលបំណងយុទ្ធសាស្ត្រ ទី៤៖ ជំរុញផែនការបញ្ចេញកាបូនទាប និងបច្ចេកវិទ្យាដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

- គោលបំណងយុទ្ធសាស្ត្រ ទី២៖ កាត់បន្ថយថ្នាក់វិស័យ ថ្នាក់តំបន់ ភាពងាយរងគ្រោះយេនឌ័រ និងហានិភ័យសុខភាពទៅនឹងផលប៉ះពាល់កាប្រែប្រួលអាកាសធាតុ

គោលបំណងទី៦ ទី៧ និងទី៨ មានទំនាក់ទំនងតិចទៅនឹងផែនការសកម្មភាពរបស់ CCAP ហើយវាផ្តោតសំខាន់ទៅលើការការពារសង្គម ក្របខ័ណ្ឌសម្របសម្រួល និងស្ថាប័ន និងការកិច្ចសហការអន្តរជាតិ។ ទោះជាយ៉ាងណាក្តី វាមិនងាយស្រួលក្នុងការគ្រប់គ្រងការអនុវត្តសកម្មភាពអោយស្របជាមួយនិងលទ្ធផលរំពឹងទុកក្នុងគោលបំណងCCCSP។ ជាពិសេស៖

- M & E៖ សូចនាករគឺមិនទាន់បានបង្កើតនៅឡើយទេនៅក្នុងCCCSP។ បន្ថែមលើនេះទៀតដូចដែលបានពន្យល់នៅក្នុងផ្នែកទី ៣.៤ ដែលវាមិនទាន់បានបញ្ចូលនូវយន្តការសម្របសម្រួលដើម្បីវាស់វែងពីការរីកចម្រើននៅក្នុងការអនុវត្ត CCAP។

- ភាពដែលអាចបត់បែនបាន៖សកម្មភាពរបស់CCAPគឺមិនបានដាក់បញ្ចូលទៅក្នុងការរៀបចំម៉ឺងម៉ាត់នោះទេ៖ មានសកម្មភាពជាច្រើនដែលបានបំពេញទៅនឹងសកម្មភាពដែលមិនបានកំណត់ហើយវាអាចប្រែប្រួលទៅតាមពេលវេលាបានដូចដែលមាននៅក្នុងដំណើរការនៃការអនុវត្តហើយគម្រោងនេះនឹងលើកយកទៅចចារជាមួយដៃគូអភិវឌ្ឍន៍។

- ផ្នែកនៃការប្រែប្រួលអាកាសធាតុ៖ ទោះបីជាមានគោលការណ៍ណែនាំដោយ CCCA មានសកម្មភាពសំខាន់ៗជាច្រើនដែលមានកម្រិតទាបនៅក្នុងជាតុនៃប្រែប្រួលអាកាសធាតុ។

CCCSP ផ្តោតសំខាន់ទៅលើតំបន់រងគ្រោះដែលមិនមានកំណត់នៅក្នុងគោលដៅរបស់ CCAPs ។ CCCSP ផ្តោតសំខាន់ទៅលើអ្នកដែលងាយរងគ្រោះបំផុត។ ទោះបីជាយ៉ាងនេះក្តី CCAOs មិនបានកំណត់អោយច្បាស់នៅឡើយទេ( សម្ភាសន៍ក្រុម CCCA )។ នេះគឺជាស្ថានភាពភូមិសាស្ត្រនៃតំបន់គោលដៅ៖

- ក្រុមគោលដៅរបស់NCDM គឺសហគមន៍នៅតំបន់រងគ្រោះ ជាពិសេសគឺតំបន់ជនបទ និងជាយក្រុងគឺនៅតែជាតំបន់មិនអាទិភាព។

## ១១.៣ ទំនាក់ទំនងរវាង CCAPs និង INDCs

- ការអនុលោមខ្លាំងទៅតាមសកម្មភាពបន្សាំរវាង CCAPs និង INDC ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី២ខាងក្រោមគំនិតសំខាន់ៗនៃសកម្មភាពភាគច្រើនរបស់ INDC គឺដកស្រង់មកពី CCCPs លើលែងតែសកម្មភាពដែលយកមកពី Second National Communication ( SNC ) ( 2016 ).

*តារាង៦៖ ភាពបន្សុីគ្នារវាងការបន្សាំក្នុង INDCs និងការឆ្លើយតបរបស់ CCAPs*

| លេខ សកម្មភាព INDC | សកម្មភាពក្នុង INDC | លេខរៀង សកម្មភាព CCAP. | ក្រសួង |
|---|---|---|---|
| 1 | ការជំរុញ និងការលើកកម្ពស់សមត្ថភាពបន្សាំរបស់សហគមន៍ និងការស្តារប្រព័ន្ធអេកូឡូស៊ីធម្មជាតិដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរអាកាសធាតុ | 121 | MOE |
| 2 | ការអនុវត្តវិធានការនៃការគ្រប់គ្រង និងការការពារតំបន់ដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលប្រួលអាកាសធាតុ | 120 | MOE |
| 3 | ការពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធប្រកាសអាសន្ន | 41 | MOWRAM |
| 4 | ការអភិវឌ្ឍ និងស្តារទំនប់ការពារទឹកជំនន់សម្រាប់ការអភិវឌ្ឍកសិកម្ម / តំបន់ទីក្រុង | 168 | MOWRAM |
| 5 | បង្កើនការប្រើប្រាស់ស្ថានីយ៍បូមចល័ត និងស្ថានីយ៍អចិន្ត្រៃយ៍នៅក្នុងការឆ្លើយតបទៅនឹងការរាំងស្ងួតខ្នាតតូច និងការលើកកម្ពស់ការស្រាវជ្រាវទឹកក្រោមដីឆ្លើយតបទៅនឹងគ្រោះរាំងស្ងួតនិងហានិភ័យអាកាសធាតុ | 167 | MOWRAM |

| | | | |
|---|---|---|---|
| 6 | ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រសហគមន៍អាកាសធាតុដើម្បីបង្កើនទិន្នផលពីផលិតកម្មកសិកម្មនៃដំណាំស្រូវ | 129 | MOWRAM |
| 7 | លើកកម្ពស់ភាពធន់អាកាសធាតុនៃកសិកម្មតាមរយៈការកសាងទំនប់ទឹកសមុទ្រនៅតំបន់ឆ្នេរនិងការពង្រីកបន្ថែមប្រព័ន្ធកសិកម្មឆ្លាតវៃខាងអាកាសធាតុ | 132 | MOWRAM |
| 8 | ការអភិវឌ្ឍពូជដំណាំដែលសមស្របទៅនឹងតំបន់កសិកម្មធម្មជាតិ (AEZ) និងភាពធន់ការប្រែប្រួលអាកាសធាតុ (រួមបញ្ចូលទាំងតំបន់ឆ្នេរសមុទ្រ) | 84 | MAFF |
| 9 | ការលើកកម្ពស់ប្រព័ន្ធផលិតកម្មវារីវប្បកម្មនិងការអនុវត្តដែលមានបន្សាំការប្រែប្រួលអាកាសធាតុ | 108 | MAFF |
| 10 | ការជួសជុលនិងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ និងធានាប្រតិបត្តិការដែលមានប្រសិទ្ធភាព និងថែទាំដោយការយកចិត្តទុកដាក់លើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ | 169 | MPWT |
| 11 | ការពង្រីកប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ឆ្ពោះទៅរកការត្រួតពិនិត្យមុនការលុបបំបាត់-ស្ថានភាពជម្ងឺគ្រុនចាញ់ | 37 | MOH |
| 12 | ការពង្រីកនៃកម្មវិធីជាតិលើការឆ្លងមេរោគតាមផ្លូវដង្ហើមធ្ងន់ធ្ងរ, ជម្ងឺរាគរូស និងជម្ងឺអាសន្នរោគក្នុងតំបន់ងាយជួបនឹងគ្រោះមហន្តរាយក្នុងនោះមានទាំងការឃ្លាំមើលការរៀបចំនិងការស្រាវជ្រាវអំពីជម្ងឺបង្កឡើងដោយទឹក និងជម្ងឺកង្វះអាហារ ដោយផ្សារភ្ជាប់ជាមួយនឹងការប្រែប្រួលអាកាសធាតុ | 38 | MOH |
| *13* | ការពង្រឹងសមត្ថភាពបច្ចេកទេសនិងស្ថាប័នដើម្បីធ្វើការវាយតម្លៃការប្រែប្រួលអាកាសធាតុ ការព្យាករណ៍ការប្រែប្រួល និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍតាមវិស័យ និងអនុវិស័យ | *From SNC* | *MOE ?* |

មិនមានជាការឆ្លើយឆ្លងមួយទៅមួយរវាងសកម្មភាពកាត់បន្ថយនេះក្នុង INDC និងនៅក្នុង CCAPs ដូចដែលបានបង្ហាញនៅក្នុងតារាងទី ៣ ខាងក្រោម, សកម្មភាពកាត់បន្ថយត្រូវបានចេញមកទាំងអស់ពីក្រុម SNC ជាជាង CCAPs នោះប៉ុន្តែការអនុវត្តរំពឹងថាតាមរយៈការ CCAPs។ *SNC បានបង្កើតជាមូលដ្ឋាននៃផ្នែកការកាត់បន្ថយពី INDC នេះដោយសារតែSNC បានផ្តល់នូវការព្យាករណ៍ឧស្ម័នផ្ទះកញ្ចក់, ជម្រើសកាត់បន្ថយ និងចក្ខុវិស័យដល់ឆ្នាំ 2030 ដែលនេះជាអ្វី INDC នេះតម្រូវឱ្យមានខណៈ CCAPs*

*មានការផ្តោតដាក់លាក់តិចជាងនេះមិនបានបង្ហាញការព្យាករណ៍ និងថយចុះ, និងរយៈពេលការអន្តរាគមន៍របស់ពួកគេ(2014-18) ។*

**តារាង៧៖ ភាពបន្សីគ្នារវាងកាត់បន្ថយក្នុង INDCs និងការឆ្លើយតបរបស់ CCAPs**

| លេខក្នុង INDC | សកម្មភាព INDC | លេខក្នុង CCAP | សកមកម្មភាពក្នុងCCAP | ក្រសួង |
|---|---|---|---|---|
| 12 | ការអភិវឌ្ឍនៃការចងក្រងនៃបច្ចេកវិទ្យាថាមពលកកើតឡើងវិញមួយសម្រាប់វិស័យឧស្សាហកម្ម | 14 | ឧស្សាហកម្មថាមពល: តំណភ្ជាប់បណ្តាញថាមពលកកើតឡើងវិញ (ថាមពលព្រះអាទិត្យ, វារីអគ្គិសនី ជីវម៉ាស និងជីវឧស្ម័ន) និងការតភ្ជាប់ថាមពលកកើតឡើងវិញបែបចំរុះទៅបណ្តាញនេះ បណ្តាញអគ្គិសនីមិនតភ្ជាប់ដូចជាប្រព័ន្ធថាមពលព្រះអាទិត្យតាមផ្ទះ, វារីអគ្គិសនី (មធ្យម, តូចនិងខ្នាតតូច); ការលើកកម្ពស់ប្រសិទ្ធភាពថាមពលដោយអ្នកប្រើចុងក្រោយ | MIH |
| 13 | លើកកម្ពស់ការបង្កើតថាមពលកកើតឡើងវិញនៅលើតំបន់និងសហបង្កើតសម្រាប់វិស័យឧស្សាហកម្មព្រមទាំងតំបន់សេដ្ឋកិច្ចពិសេស | | | |
| 15 | សាកល្បងនិងឯកសារយុទ្ធសាស្ត្រសម្រាប់ការបម្លែងកាកសំណល់ទៅជាឧស្សាហកម្មថាមពល | | | |
| 88 | ការវាយតម្លៃនៃសក្តានុពលនៃកម្មវិធីថាមពលកកើតឡើងនៅក្នុងវិស័យឧស្សាហកម្ម | | | |
| 95 | ការវាយតម្លៃតម្រូវការបច្ចេកវិទ្យាសម្រាប់ការកាត់បន្ថយ GHGs ក្នុងវិស័យថាមពល | 15 | ការកាត់បន្ថយការបំភាយឧស្ម័នជាលទ្ធផលពីរោងម៉ាស៊ីនកិនស្រូវកាត់ដេរនិងការងារឡេផ្ទ | MME |
| 55 | ជំរុញការថែទាំ និងត្រួតពិនិត្យយានយន្ត | 16 | ការត្រួតពិនិត្យម៉ូទ័រយានយន្ត ការធ្វើដំណើរសារជារ | MPWT |

| | | | | |
|---|---|---|---|---|
| | | | ណៈ និងការកែលម្អប្រសិទ្ធភាពយានយន្ត | |
| 8 | រៀបចំការអនុវត្ត ធនធាន និងប្រសិទ្ធភាពថាមពលសម្រាប់ឧស្សាហកម្ម និងសហគ្រាសខ្នាតមធ្យម | 17 | ចង្ក្រានប្រសិទ្ធភាព ឡជីវឧស្ម័ន និងផុងចំរោះទឹក | MIH |
| 71 | រៀបចំ និងអនុវត្តន៍ក្របខណ្ឌគតិយុត្តិ និងយន្តការ REDD+ | 18 | បង្កើនគម្រោងព្រៃឈើ 60%នៃផ្ទៃដីរបស់ជាតិ និងរក្សាគម្របនេះរហូតដល់ឆ្នាំ ២០៣០ | MAFF |

ប្រភព: ក្រុមអ្នកវិភាគលើ CCAPs និង INDC

# ១២. បរិយាកាសអំណោយផលផ្នែកការគាំទ្របរិស្ថាន និងរដ្ឋាភិបាលសម្រាប់ដំណើរការបន្សាំជាតិ

ការរៀបចំ CCCSP ជាជំហានយ៉ាងសំខាន់ឆ្ពោះទៅរកការប្រែប្រួលអាកាសធាតុដែលបង្កប់ក្នុងផែនការអភិវឌ្ឍជាតិនិងផែនការអភិវឌ្ឍតាមវិស័យនៃក្រសួងពាក់ព័ន្ធ។ បន្ទាប់ពីការអនុម័ត CCCSP បានគេបញ្ចូលនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ 2014-2018 ។

នៅតាមវិស័យក្រសួងស្ថាប័នពាក់ព័ន្ធបានចាប់ផ្តើមរៀបចំផែនការសកម្មភាពការប្រែប្រួលអាកាសធាតុដោយសម្របទៅ CCCSP និងផែនការអភិវឌ្ឍន៍វិស័យរបស់ពួកគេ។ នៅចុងឆ្នាំ 2014 នេះជាលើកដំបូងដែលមានក្រសួងពាក់ព័ន្ធចំនួនប្រាំបីត្រូវបានអនុម័ត CCAPs របស់ពួកគេពោលគឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), ក្រសួងអប់រំ យុវជន និងកីឡា (អយក), ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ក្រសួងកិច្ចការនារី (MoWA), ក្រសួងសាធារណៈការ និងដឹកជញ្ជូន (MPWT), គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងក្រសួងសុខាភិបាល (MoH)។

នេះជាលើកទីពីរ ដែលមានសង្កត់ភាពជាមួយបណ្តាក្រសួងពាក់ព័ន្ធចំនួនប្រាំមួយបានអនុម័ត CCAPs នៅឆ្នាំ 2015។ ក្រសួងទាំងនោះរួមមាន ក្រសួងបរិស្ថាន (MoE), ក្រសួងទេសចរណ៍ (MOT), ក្រសួងព័ត៌មាន (MoINFO), រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ក្រសួងរ៉ែនិងថាមពល (MME) និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម (MIH) ។

ដូចគ្នានេះផងដែរក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានរៀបចំ CCAP នេះប៉ុន្តែផែនការនេះមិនត្រូវបានអនុម័ត។ ដូច្នេះសរុបមាន 14 ក្រសួងពាក់ព័ន្ធដែលមានផែនសកម្មភាពការប្រែប្រួលអាកាសធាតុបានអនុម័ត។ ការរៀបចំ CCCSP និង CCAP បានអនុវត្តន៍តាមគោលការណ៍ណែនាំសម្រាប់រៀបចំគោលនយោបាយមកពីទីស្តីការគណៈរដ្ឋមន្ត្រី (ឆ្នាំ 2011) ដោយមានការគាំទ្របច្ចេកទេសពីនាយកដ្ឋានការប្រែប្រួលអាកាសធាតុ (DCC) និងសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ។

បានអនុម័តផែនការកម្មភាពការប្រែប្រួលអាកាសធាតុចំនួនសកម្មភាពរហូតដល់ 171 ដែលត្រូវការថវិកាដល់ 865,47លានដុល្លារ សម្រាប់អនុវត្តន៍ឆ្នាំ 2014-2018[13]. ។ នាពេលថ្មីៗនេះ, ការងារដែលអនុវត្តន៍ដោយហិរញ្ញប្បទានត្រៀមអាកាសធាតុ(GIZ)បានវាយតម្លៃកង្វះចន្លោះហិរញ្ញវត្ថុអប្បបរមាសម្រាប់ការប្រតិបត្តិ CCAP ។ វាត្រូវបានគេរកឃើញថាវានៅមានគម្លាតហិរញ្ញប្បទានចំនួន 71,68% នៃចំនួនប៉ាន់ប្រមាណសរុប [14]។

*តារាង ៨: គម្លាតផ្នែកហិរញ្ញវត្ថុ CCAP សម្រាប់អនុវត្តន៍ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់ CCAPsដែលបានអនុម័ត (ប្រភព: សេចក្តីព្រាងរបាយការណ៍ស្តីពីគម្លាតហិរញ្ញវត្ថុជីអាយហ្សិត CCAP ឆ្នាំ 2016)*

| លរ | ក្រសួង | ចំនួនសកម្មភាព | តម្លៃ(លាន USD) | ចំនួនសកម្មភាពដែលទទួលបានមូលនិធិ | ហិរញ្ញប្បទានបានទទួល (លានUSD ) | កង្វះខាត (លាន USD) | កង្វះខាត % |
|---|---|---|---|---|---|---|---|
| 1 | MAFF | 29 | 187.55 | 8 | 54.69 | 132.86 | 70.84 |
| 2 | MIH | 17 | 11 | 2 | 11.70 | -0.70 | -6.39 |
| 3 | MLMUPC | 8 | 9.12 | 1 | 0.25 | 8.87 | 97.26 |
| 4 | MME | 9 | 5.02 | 1 | 0.25 | 4.77 | 95.02 |
| 5 | MOE | 17 | 27.67 | 11 | 19.29 | 8.38 | 30.28 |
| 6 | MOEYS | 7 | 10.6 | 1 | 0.35 | 10.25 | 97.70 |
| 7 | MOH | 11 | 46.8 | 1 | 0.40 | 46.4 | 99.15 |
| 8 | MOINFO | 5 | 4.33 | 1 | 0.13 | 4.205 | 97.12 |
| 9 | MOT | 8 | 3.4 | 1 | 0.13 | 3.28 | 96.79 |

[13] MAFF, MIH, MLMUPC, MME, MOE, MOEYS, MOH, MOINFO, MOT, MOWA, MOWRAM, MPWT, MRD, NCDM, and MPTC (not yet approved)

[14] This number is based on a previous report by GIZ/Ricardo AEA (2016) and may need to be adjusted in the future to a smaller number if all CC-related CDC projects are tracked and reported against the CCAP priority actions

| | | | | | | | |
|---|---|---|---|---|---|---|---|
| 10 | MoWA | 6 | 3.62 | 1 | 0.10 | 3.52 | 97.24 |
| 11 | MoWRAM | 16 | 272.5 | 3 | 75.20 | 197.3 | 72.40 |
| 12 | MPTC ( not yet approved ) | 6 | 4.61 | 0 | 0.00 | 4.61 | 100 |
| 13 | MPWT | 11 | 210.98 | 3 | 8.21 | 202.775 | 96.11 |
| 14 | MRD | 10 | 56.53 | 2 | 74.33 | -17.8 | -31.00 |
| 15 | NCDM | 11 | 11.75 | 1 | 0.10 | 11.65 | 99.15 |
| TOTAL | | 171 | 865.47 | 37 | 245.12 | 620.37 | 71.68 |

ភាគច្រើននៃ CCAPs បានអនុម័តដែលឥឡូវនេះកំពុងត្រូវបានអនុវត្តន៍តាមរយៈមធ្យោបាយផ្សេងៗពោលគឺ (1) ដំណើរការថវិកានិងការធ្វើផែនការថ្នាក់ជាតិ (2) គម្រោងការប្រែប្រួលអាកាសធាតុដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍និង (3) ការផ្តល់ជំនួយពី DCC /កម្មវិធី CCCA ដើម្បីអនុវត្តន៍សាកល្បងលើអាទិភាពរបស់ CCAP ។

ដំណើរការផែនការនិងថវិកាជាតិ តម្រូវឱ្យភ្នាក់ងាររដ្ឋាភិបាលដាក់ស្នើសំណើរថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ(ចំណាយចរន្តនិងចំណាយមូលធន) ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(MEF) តាមរយៈថវិកាកម្មវិធីនិង ក្រសួងផែនការតាមរយៈការធ្វើបច្ចុប្បន្នភាពនិង / ឬការស្នើសុំសកម្មភាពថ្មីនៅក្នុង កម្មវិធីវិនិយោគសាធារណៈ (PIP) ដែលនឹងត្រូវដាក់ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ដើម្បីផ្តល់មូលនិធិទាំងខាងក្នុង និងមូលនិធិខាងក្រៅ។

ការពិនិត្យឡើងវិញនូវចំណាយសាធារណៈលើអាកាសធាតុសម្រាប់ឆ្នាំ 2013-2014 ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងកម្មវិធី CCCA ជាអ្នកផ្តល់ធាតុចូល បច្ចេកទេស។ របាយការណ៍ CPER ឆ្នាំ 2016 នេះបានបង្ហាញថានៅឆ្នាំ 2014 ស្ទើរតែមួយភាគបួន (24,8%) នៃការចំណាយ សាធារណៈលើអាកាសធាតុត្រូវបានឧបត្ថម្ភដោយថវិកាជាតិ។ ជាទូទៅគម្រោងដែលមានបញ្ច្រាបការប្រែប្រួលអាកាសធាតុ ឬផ្តោតលើការប្រែប្រួលអាកាសធាតុទទួលបានមូលនិធិគាំទ្រពីដៃគូអភិវឌ្ឍន៍ខាងក្រៅ។

យោងតាមរបាយការណ៍ CPER ឆ្នាំ២០១៦ នៅកំឡុងឆ្នាំ២០១៤ ថវិកាប្រែប្រួលអាកាសធាតុចំនួនពីរភាគបី រឺស្មើនឹង៦៧% ទទួលបានមកពីដៃគូខាងក្រៅ ដែលផ្តោតទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម លើសពីនេះ ឃើញមានការកើនឡើងប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋ

កិច្ច និងហិរញ្ញវត្ថុ ដែលថវិកាទាំងនេះ បានផ្តល់សារៈសំខាន់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍វិស័យនៅថ្នាក់ជាតិ[15]។

គម្រោងអភិវឌ្ឍន៍ជោគជ័យរបស់ CCCSP និង CCAPs កម្មវិធី CCCA នៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ បានគាំទ្រដល់ក្រសួងចំនួន១៤ ក្នុងការអនុវត្ត សាកល្បងសកម្មភាពអាទិភាពរបស់ CCAP ជាពីរដំណាក់កាលនៃថវិកាគាំទ្រ ដែលមានប្រមាណចន្លោះពី ១០០.០០០ ទៅ ៤៥០.០០០ដុល្លារតាមក្រសួងនីមួយៗ។ ថវិកាដំណាក់កាលទីមួយបានគាំទ្រដល់ក្រសួង កសិកម្មរុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអប់រំ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកិច្ចការនារី, ក្រសួងសាធារណៈការ និងដឹកជញ្ជូន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល ដែលបានចាប់ ផ្តើមនៅឆ្នាំ២០១៥។ ថវិកាដំណាក់កាលទីពីរបានគាំទ្រដល់ក្រសួងដែល នៅសល់ដូចជាក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងរ៉ែ និងថាមពល និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបានចាប់ផ្តើមនៅឆ្នាំ២០១៦។

## ១២.១ កង្វះចន្លោះនៃការរៀបចំ NAP នៅកម្ពុជា

តម្រូវការថវិកាក្នុងការអនុវត្តបានកើនឡើង បានធ្វើអោយសកម្មភាពរបស់ CCAPs នៅមិនទាន់មានថវិកានៅឡើយនៅខែសីហា ឆ្នាំ២០១៥ ក្របខ័ណ្ឌហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុបានព្យាករណ៍ការចំណាយ ក្នុងការឆ្លើយតប ទៅនឹងតម្រូវការសាធារណៈប្រមាណ ១,១ពាន់លានដុល្លារសម្រាប់ឆ្នាំ២០១៤-២០១៨ នេះបើយោងទៅតាម ផែនការសកម្មភាពបច្ចុប្បន្ន និងការព្យាករណ៍ទៅតាមវិស័យដែលមិនទាន់បានរៀបចំផែនការនាពេលនោះ។

ផ្អែកតាមការវិភាគដោយកម្មវិធីហិរញ្ញប្បទានត្រៀមសម្រាប់ការប្រែប្រួលអាកាសធាតុរបស់ GIZ បានគណនាចំនួនថវិកាដែល ខ្វះខាតសម្រាប់អនុវត្តន៍ CCAP ចំនួនពាក់កណ្តាលនៃ ៨៦៥លានដុល្លារសម្រាប់អនុវត្តសកម្មភាពប្រែប្រួលអាកាស ធាតុអាទិភាពរបស់ក្រសួងមួយចំនួនសម្រាប់ឆ្នាំ២០១៨-២០១៩ នៅមិនទាន់មាននៅឡើយ ដែលតម្រូវអោយមាន ការខិតខំប្រឹងប្រែងក្នុងការគៀងគរធនធាន។ តម្រូវការ ដើម្បីទទួលបានថវិកាត្រូវបានកំនត់ដោយកត្តាជាច្រើនដូច ជាសមត្ថភាពក្នុងការអនុវត្ត តំបន់គោលដៅក្នុងការបន្សាំ កម្រិតនៃការប្រៀបធៀបរវាងឥទ្ធិពលនៃការប្រែប្រួល អាកាសធាតុ ការចំណាយលើការបន្សាំ និងកាចំណាយក្រោយការបន្សាំ។

ជាទូទៅការចំណាយលើការបន្សាំនៅកម្ពុជាមានកម្រិតខ្ពស់ ដែលធ្វើអោយមានកង្វះខាតថវិកានៅ CCAP ដែលមានប្រមាណច្រើនជា ៤០០លានដុល្លាររហូតដល់ឆ្នាំ២០១៨។

## ១២.២ ការគៀងគរធនធានសម្រាប់សកម្មភាពបន្សាំ

យុទ្ធសាស្ត្រក្នុងការគៀងគរធនធានបន្ថែម ត្រូវផ្តោតលើប្រភពថវិការមួយចំនួន ដែលថវិកាខាងក្នុងត្រូវបានរំពឹងថា នឹងមានចំនួនច្រើនសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុ។ ធន្ទ:នយោបាយ ការជំរុញនីតិវិធីរៀបចំ ផែនការ និងថវិកាបញ្ជ្រាបការប្រែប្រួលអាកាសធាតុ រួមទាំងកម្មវិធីវិនិយោគសាធារណ:។ យោងតាមថវិការប្រែប្រួល អាកាសធាតុអន្តរជាតិ ក.ជ.អ.ច. ជាមួយការចូលរួមរបស់ GIZ បានសម្រាំងសកម្មភាពអាទិភាពរបស់វិស័យ CCAPs ព្រមទាំងការកំណត់ថវិកាអាទិភាពខ្ពស់ ទាំងនេះជាការអភិវឌ្ឍផ្សេងៗ របស់គម្រោងសំណើរថវិកា ដែលនឹងត្រូវបានបង្ហាញទៅដៃគូម្ចាស់ជំនួយចម្រុះ។

លើសពីនេះទៀត ឧបករណ៍ក្នុងការសម្រាំង ត្រូវបានបង្កើតក្នុងការកែតម្រូវ សម្រាំង ចាត់អាទិភាពសកម្មភាព CCAP សម្រាប់គោលបំណងផ្សេងៗនៅអនាគត។ ធនធានចម្បងរបស់ហិរញ្ញវត្ថុបន្សាំអន្តរជាតិ គឺជាមូលនិធិអាកាសធាតុបៃតង(GCF)។ កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលត្រៀមរួចជាស្រេចដើម្បីទទួលបាន ថវិកាបន្សាំពី GCF តាមរយ:ពហុដៃគូ និងការទទួលបានដោយផ្ទាល់។ លេខាធិការដ្ឋានគណ:កម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានជ្រើសរើសដោយក្រសួងបរិស្ថាន (អាជ្ញាធរជាតិសម្រាប់យន្តការអភិវឌ្ឍស្អាត)ដែលជាស្ថាប័នជាតិដ៏មានសក្តានុពលក្នុងការចុះបញ្ជីជាស្ថាប័នអនុវត្តន៍ជាតិ(NIE) ដែលកំពុងពិនិត្យដំណើរការ ហើយនេះជាអង្គភាពដំបូង ដែល GCF បានជ្រើសរើសសម្រាប់ការផ្តល់មូលនិធិទៅថ្នាក់ក្រោមជាតិ។

# ករណីសិក្សា:

## ករណីសិក្សាទី១: លើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ជនបទរស់នៅក្នុងតំបន់ការពារ នៃប្រទេសកម្ពុជា




រាជរដ្ឋាភិបាលកម្ពុជា បានសហការជាមួយកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ក្នុងការអនុវត្តគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ "ជំរុញភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ជនបទរស់នៅក្នុងតំបន់ការពារ នៃព្រះរាជាណាចក្រកម្ពុជា" ដែលទទួលបានការគាំទ្រថវិកាដោយមូលនិធិបន្សាំ។ ប្រភេទស្ថាប័នអនុវត្តន៍ រួមមានស្ថាប័នអនុវត្តន៍ ពហុភាគី (MIE) ហើយ UNEP គឺជាស្ថាប័នអនុវត្តន៍ ខណ:ដែលក្រសួងបរិស្ថានជាស្ថាប័នប្រតិបត្តិគម្រោង ដែលមានថវិកាប្រមាណ ៤.៩៥៤.២៧៣លានដុល្លារ រយ:ពេលប្រាំឆ្នាំចាប់ពីឆ្នាំ ២០១២-

២០១៧។ គម្រោងមានគោលបំណងក្នុងការដោះស្រាយភាពងាយរងគ្រោះរបស់សហគមន៍ជនបទរស់នៅក្នុងតំបន់ការពារ បានជ្រើសរើសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជួបគ្រោះភ័យនៃការប្រែប្រួលអាកាសធាតុ នាំអោយមានធ្លាក់ភ្លៀងមិនប្រក្រតី ព្រមទាំងបណ្តាលអោយកង្វះខាតស្បៀងអាហារដោយសារភាពរាំងស្ងួតញឹកញាប់ពេក និងការបាត់បង់ស្រទាប់ដីផ្នែកខាងលើ នៅកំឡុងពេលភ្លៀងធ្លាក់ខ្លាំង ព្រមទាំងទឹកជំនន់។ ជារួមមានតំបន់ការពារចំនួនប្រាំ ត្រូវបានជ្រើសរើស ដើម្បីធ្វើការអន្តរាគមន៍ ដូចជា ចកបឹងប្រើយ៍ ជុំធ្លក ស្តុរម្រោច (តំបន់អភិរក្សសត្វព្រៃបឹងពេ) រនុកក្ទីង (តំបន់អភិរក្សសត្វភ្នំព្រេច) និងដុបតាសុក (ឧទ្យានជាតិភ្នំគូលេន)។ គម្រោងថវិកាបន្ស៊ាំ ប្រើបច្ចេកទេសសេដ្ឋកិច្ចកសិកម្ម ដើម្បីពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍។ គម្រោងស្តារភាពសឹករិចរិលព្រៃឈើ ដោយការដាំដើមឈើ ដែលអាចផ្តល់ជាអាហារ អនុផលព្រៃឈើ និងជួយប្រព័ន្ធអេកូ គ្រប់គ្រងសំណឹក និងលំហូរទឹក។ ផលិតកម្មដំណាំបានជំរុញការដាំដុះឈើប្រើប្រាស់ច្រើនប្រភេទ ជាប់ជាមួយដីស្រែកសិកម្ម និងតំបន់ដាំដុះ។ តំបន់សាកល្បងដំណាំស្រូវដែលធន់នឹងភាពរាំងស្ងួត ត្រូវបានរៀបចំ ជាមួយនឹងតំបន់ប្រពលវប្បកម្ម និងពិពិធកម្មកសិកម្មដែលមានស្រាប់។ ហើយការអនុវត្តកសិកម្មអភិរក្ស នឹងត្រូវបានណែនាំនៅក្នុងតំបន់ការពាររបស់សហគមន៍ផងដែរ។

សហគមន៍តំបន់ការពារជួកបានបង្កើតឡើងនៅឆ្នាំ២០០២ ក្រោមការគាំទ្រដោយ IDRC ដែលមានអ្នកចូលរួមសកម្មប្រមាណ ១៩០៧គ្រួសារ នៃសហគមន៍ទាំងប្រាំ នឹងបានបន្តគាំទ្រដោយគម្រោងថវិកាបន្ស៊ាំនៅឆ្នាំ ២០១៣។



រូបថត៖ លោក ឡុង សូណា

យោងតាមការពិភាក្សាជាមួយក្រុមការងារគម្រោង និងអ្នកទទួលផលគម្រោង បានជួបប្រទះនឹងការប្រឈម ដូចជារងឥទ្ធិពលនៃការបំផ្លាញដំណាំស្រូវ ការស្លាប់បសុសត្វ ប៉ះពាល់ដល់ការគម្រាមកំហែងសន្តិសុខស្បៀង បណ្តាលទៅជាការឆ្លងជំងឺ និងកើនឡើងភាពក្រីក្រ រហូតដល់ការធ្វើចំណាកស្រុក ដើម្បីលក់កំលាំងពលកម្ម។ ព្រមទាំងមានការប្រឈមផ្សេងៗទៀត ដូចជា គ្រោះមហន្តរាយផ្សេងៗដែលបណ្តាលមកពីភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ ដែលជះឥទ្ធិពលដល់ ប្រជាសហគមន៍ បសុសត្វ និងដំណាំ ការកាប់បំផ្លាញព្រៃឈើ ដើម្បីដាំដំណាំ ការបាត់បង់ដីមានជីជាតិ កង្វះទឹកសម្រាប់ដំណាំ និងសួនបន្លែ (ចំពោះសហគមន៍ដែលពឹងផ្អែកលើទឹកភ្លៀង ដែលបញ្ហាទាំងនេះបានធ្វើអោយចំណូលធ្លាក់ចុះពី ១០-១២,៥ សម្រាប់មនុស្សម្នាក់ក្នុងមួយខែ និង

បាត់បង់ចំណូលនៅរដូវភ្លៀង។ លើសពីនេះទៀតប្រជាសហគមន៍មានការយល់មានកម្រិតទាក់ទងនឹងច្បាប់តំបន់ការពារ និងផែនការគ្រប់គ្រងតំបន់ការពារ ដែលតម្រូវអោយមានការយាមកាម ដើម្បីបង្ការសកម្មភាពកាប់ឈើខុសច្បាប់។

គម្រោងបានកំណត់ឥទ្ធិពល នៃការប្រែប្រួលអាកាសធាតុ នៅក្នុងសហគមន៍របស់ពួកគាត់ មានដូចជាការកើនឡើងកំដៅ ចំនួនទឹកភ្លៀងធ្លាក់ចុះ កើនឡើងសត្វល្អិត គ្រោះរាំងស្ងួតញឹកញាប់ បាត់បង់បរិមាណទឹកក្រោមដី និងការកាប់ឈើខុសច្បាប់នៅពេលយប់។ គម្រោងបានផ្តល់ការកសាងសមត្ថភាពលើការកែលម្អជីវភាព និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ប្រជាសហគមន៍ ក្នុងការបណ្តុះកូនឈើ ឈើកសិកម្ម អេកូទេសចរណ៍ និងការចិញ្ចឹមមាន់ ស្តារអណ្តូងចំនួន៣០ ជីកស្រះ ផ្តល់ពូជដំណាំ ការចិញ្ចឹមចង្រឹត សួនបន្លែគ្រួសារ។ លើសពីនេះទៀតគម្រោងក៏ទទួលបានការបង្ហាញ និងការណែនាំបច្ចេកទេសពីមន្ទីរកសិកម្មផងដែរ។ ផែនការគ្រប់គ្រងព្រៃឈើតំបន់ការពារ ត្រូវបានពង្រាង ដើម្បីពិភាក្សាជាមួយប្រជាសហគមន៍ ក្នុងការបែងចែកតំបន់ការពារ និងគ្រប់គ្រងការដកហូតផងដែរ។

បច្ចុប្បន្ននេះគណៈកម្មាធិសហគមន៍តំបន់ការពារ អាចពង្រឹងស្ថាប័នរបស់ខ្លួន និងអភិវឌ្ឍន៍ផែនការគ្រប់គ្រងរយៈពេលប្រាំឆ្នាំ និងកែលម្អជីវភាពរស់នៅរបស់ពួកគេ ដោយប្រើជម្រើសផ្សេងៗគ្នាដូចជាអេកូទេសចរណ៍ ចិញ្ចឹមសត្វ ចិញ្ចឹមចង្រឹត សួនបន្លែគ្រួសារ និងមានទឹកគ្រប់គ្រាន់ សម្រាប់វិស័យកសិកម្ម និងសត្វផងដែរ។ ប្រជាសហគមន៍ បានចូលរួមសកម្មបំផុតក្នុងការល្បាតព្រៃយ៉ាងទៀងទាត់ និងបណ្តុះកូនឈើ បំណងស្តារព្រៃឈើឡើងវិញ។

**ការស្រាវជ្រាវនេះមានអនុសាសន៍មួយចំនួនដូចខាងក្រោម៖**

១. ព័ត៌មានគម្រោង គួរត្រូវបានចែករំលែកយ៉ាងទូលំទូលាយ ទៅអាជ្ញាធរ និងសមាជិកសហគមន៍ តាមរយៈការផ្តល់ជូនខិតប័ណ្ណ សម្ភារៈ IEC ផ្ទាំងរូបភាព គេហទំព័រអំពីគម្រោង និងការផ្សព្វផ្សាយដល់សហគមន៍អ្នកទទួលផលគោលដៅ និងសាធារណៈជនទូទៅ។

២. ការកសាងសមត្ថភាពគណៈកម្មាធិសហគមន៍តំបន់ការពារ គួរត្រូវបានផ្តល់បន្ថែមទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ ជម្រើសនៃការបន្ស៊ាំ សហគមន៍អេកូទេសចរណ៍ ការពង្រឹងស្ថាប័នបច្ចេកទេសកសិកម្ម និងផ្សព្វផ្សាយព័ត៌គម្រោង ។ល។

៣. ភាពជាម្ចាស់ និងចីរភាពរបស់សហគមន៍តំបន់ការពារ គួរតែមានភាពម្ចាស់ការ និងអាចពាក់ព័ន្ធនឹងដំណើរការធ្វើការសម្រេចចិត្តទាំងអស់ដែលទាក់ទងទៅនឹងគម្រោង។ មានធនធានអាទិភាពជាច្រើន ដូចជាធម្មជាតិសម្រាប់វិស័យទេសចរណ៍បរិស្ថាន។ ក្រសួងបរិស្ថាន និងសហគមន៍គួរតែរួមបញ្ចូលគ្នាទៅក្នុងវិស័យទេសចរណ៍បរិស្ថាន ការអភិរក្ស និងការធ្វើផែនការ នឹងត្រូវបានផ្តល់ធនធានបន្ថែម និងការផ្តល់មូលនិធិសម្រាប់ការគ្រប់គ្រងប្រកបដោយចីរភាព។ ក្រុមសន្សំមានសារៈសំខាន់ ដើម្បីធានាឱ្យបានការគាំទ្រផ្នែក

ថវិកាសកម្មភាពរបស់សហគមន៍ និងកែលម្អជីវភាពរស់នៅព្រមទាំងកាត់បន្ថយប្រាក់កម្ចីពីភ្នាក់ងារហិរញ្ញវត្ថុខ្នាតតូច។

៤. រចនាសម្ព័ន្ធសហគមន៍ និងប្រព័ន្ធគ្រប់គ្រង ជាលទ្ធផលនៃការពិភាក្សាជាមួយសហគមន៍ ពួកគេបានរាយការណ៍ថាមេដឹកនាំរបស់សហគមន៍ និងសមាជិកដែលត្រូវបានផ្លាស់ប្តូរនៅពេលដែលពួកគាត់គ្មានធនធាន និងកង្វះសមត្ថភាព។ ពួកគេបានបន្ថែមថាសកម្មភាពទាំងអស់របស់សហគមន៍ ជាការស្ម័គ្រចិត្ត និងដោយគ្មានការគាំទ្រថវិកា។ ក្រសួងបរិស្ថានគួរពិចារណាវិភាជន៍មូលនិធិបន្សាំ ដើម្បីគាំទ្រដល់សកម្មភាពរបស់ពួកគេ និងការកសាងសមត្ថភាពរបស់ពួកគេ ដើម្បីគ្រប់គ្រងប្រសិទ្ធភាពជំនួយឥតសំណងទាំងនោះ។

## ករណីសិក្សាទី២៖ អភិបាលកិច្ចមូលដ្ឋាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ

អភិបាលកិច្ចមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ (LGCC) គឺជាគម្រោងមួយដែលបានអនុវត្តន៍ដោយលេខាធិការដ្ឋាន គ.ជ.អ.ប ដោយមានជំនួយបច្ចេកទេសពី UNCDF ។ LGCC បានរៀបចំ និងអនុវត្តន៍នៅក្នុងក្របខ័ណ្ឌនៃកម្មវិធី "ការរស់នៅដោយមានការបន្សាំនឹងអាកាសធាតុមូលដ្ឋាន" (LoCAL) ដោយមជ្ឈមណ្ឌលថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក របស់ UNCDF។ កម្ពុជាក្លាយជាប្រទេសដំបូងដែលបានអនុវត្តន៍កម្មវិធី LoCAL ជាមួយ Bhutan ។ ជាងនេះទៅទៀតគម្រោងសាកល្បងនៅក្នុងប្រទេសឡាវ បង់ក្លាដេស នេប៉ាល់ និងកោះសូលូម៉ុនគឺស្ថិតនៅក្នុងតំណាក់កាលរៀបចំនៅឡើយ ហើយការពិភាក្សាបឋមក្នុងការពង្រីកកម្មវិធីនេះទៅតំបន់អាហ្វ្រិកនិងចាប់ផ្តើមក្នុងរយៈពេលខ្លីខាងមុខនេះ ចំណែកឯនៅក្នុងប្រទេសកម្ពុជាវិញគម្រោងនេះបានជ្រើសរើសខេត្តចំនួនពីរគឺខេត្តតាកែវ និងខេត្តបាត់ដំបង។

គោលបំណងនៃគម្រោងគឺដើម្បីបង្ហាញអំពីតួនាទីរបស់អង្គាធរមូលដ្ឋានក្នុងការជំរុញដល់ការបន្សាំការប្រែប្រួលអាកាសធាតុ ហើយដើម្បីកំណត់ពីមធ្យោបាយអនុវត្តន៍ដើម្បីបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ និងប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ។ គម្រោងនេះបានធ្វើឡើងក្នុងរយៈពេលវែងដោយបញ្ចូលសកម្មភាពការបន្សាំការប្រែប្រួលអាកាសធាតុជាមួយកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិដោយអនុលោមទៅតាមជំនួយផ្អែកលើលទ្ធ

ផល (performance-based grants) តាមរយៈការអនុវត្ត មេរៀនបទពិសោធន៍ ផែនការ និងការណែនាំពីកញ្ចប់ថវិកា និងគណនេយ្យរបស់រដ្ឋ សម្រាប់ស្រុកនិងក្រុងក្នុងច្បាប់ថវិការថ្នាក់ក្រោមជាតិ។

ឃុំនិងសង្កាត់គោលដៅចំនួន១៣ឃុំនិងសង្កាត់ដែលស្ថិតនៅក្នុងស្រុកចំនួន និងសង្កាត់ចំនួន៣ នៅក្នុងខេត្តតាកែវ និង១៥ឃុំ នៅក្នុងស្រុកគោលដៅចំនួន៥ នៅក្នុងខេត្តបាត់ដំបង។ ឧបករណ៍ VRAs និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ បានដាក់បញ្ចូលទៅក្នុងកិច្ចសហប្រតិបត្តិការជាមួយ និងក្រសួងបរិស្ថានសម្រាប់ប្រើក្នុងការរៀបចំយុទ្ធសាស្ត្របន្សាំការប្រែប្រួលអាកាសធាតុថ្នាក់ស្រុក និងការរៀបចំផែនការវិនិយោគឃុំសង្កាត់។ នៅកម្រិតខេត្ត មិនមានផែនការអន្តរវិស័យដែលបានរៀបចំនោះទេ បើទោះបីមានសិក្ខាសាលាជាច្រើនត្រូវបានរៀបចំក៏ដោយ។ សិក្ខាសាលានេះត្រូវបានប្រើប្រាស់ក្នុងការផ្សព្វផ្សាយព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទាំងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីជាជំនួយដល់យុទ្ធសាស្ត្របន្សាំការប្រែប្រួលអាកាសធាតុថ្នាក់ស្រុក។ វាបានបញ្ជាក់ថាវាមិននៅក្នុងយុទ្ធសាស្ត្ររបស់CCA នៅថ្នាក់ខេត្តទេ។ ការចំណាយប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ ទម្រង់បែបបទនៃការប្រើប្រាស់ថវិការដោយនិរន្តរភាព គឺត្រូវបានអនុម័ត ។

ការបែងចែកកញ្ចប់ថវិការត្រូវបានធ្វើឡើងដោយមានការអនុម័តរបស់ CCA នៅក្នុងដំណើរការនៃការរៀបចំកិច្ចព្រមព្រៀងរវាង NCDDS និង UNCDF ។ រាល់ PBCRGs បានរៀបចំឡើងដោយយោងទៅតាមការកំណត់ពីចំណុចអាទិភាពរបស់ CCA តាមរយៈ VRAs នៅក្នុងការពិភាក្សារវាងក្រុមទាំងបី។ ដោយយោងទៅតាមព័ត៌មានជាបឋម និងការអង្កេតនៃការវិនិយោគ និងអន្តរាគមន៍ពី CCA ជាមួយអាជ្ញាធរថ្នាក់ឃុំ វាអាចជាឧបករណ៍មួយដែលមានកំរិតខ្ពស់ជាង ៥០% នៃសកម្មភាពអទិភាពដែលគាំទ្រដោយ CCA ទៅនិងការឆ្លើយតបរបស់ PBCRGs ទៅនិងតម្រូវការរបស់ស្ត្រីដោយភ្ជាប់ទៅនិងមត្រូវការរបស់សហគមន៍ទាំងមូល។

ក្រុមវាយតម្លៃបានកំណត់ថា ខណៈពេលដែលសកម្មភាពនេះបានស្របទៅក្នុងប្រព័ន្ធរបស់ NCDDS វានៅតែមិនទាន់បានបញ្ចូលទៅក្នុងដំណើរការ និងផែនការថ្នាក់ជាតិរបស់ក្រសួងផែនការនៅឡើយ។ កូដសម្រាប់សម្គាល់ពីចំណូលដែលបានវិនិយោគដោយ CCA ត្រូវបានរៀបចំ រួមបញ្ចូលទៅក្នុងតារាងគណនេយ្យថ្នាក់ក្រោមជាតិ។

ទោះបីជាមានការតាំងចិត្តខ្ពស់ពីរដ្ឋាភិបាលក៏ដោយប៉ុន្តែវានៅតែមានបញ្ហាប្រឈមនឹងភាពចន្លោះខ្វះខាតក្នុងការកំណត់ពីភាពខ្វះខាតនៃការភ្ជាប់រវាងអំពីរចនាសម្ព័ននៃអនុគម្រោង និងសេវាបច្ចេកទេសទៅលើការបន្សាំការប្រែប្រួលអាកាសធាតុ CCA កំពុងតែផ្តោតសំខាន់ទៅលើការជំរុញការយល់ដឹងផ្នែកបច្ចេកទេសនៅថ្នាក់ក្រោមជាតិ, កំសោយនៃការបែងចែកមូលនិធិនៅថ្នាក់ស្រុក ភាពខ្វះខាតរបស់ស្ថាប័ន និងយន្តការគ្រប់គ្រងចំណេះដឹង ដែលផ្តល់អោយនៅស្រែពិសោធន៍ និងលទ្ធផលទៅក្នុងការបង្កើតគោលនយោបាយ។ មេរៀនបទពិសោធន៍និងអនុសាស្ត្រត្រូវបានកំណត់ជាអាទិភាព។

- ភាពជាដៃគូ និងការសម្របសម្រួលរវាងអ្នកដើរតួសំខាន់ៗ គឺវាពិបាកនិងជោគជ័យណាស់ជាពិសេសពេលដោះស្រាយជាមួយនឹងប្រធានបទដែលស្មុគស្មាញដូចជា CCAជាដើម

- ការផ្លាស់ប្តូរឥរិយាបទរបស់ប្រជាជន អត្តចរិក និងការអនុវត្តដែលមានភាពស្មុគស្មាញ ជាពិសេសករណីការប្រែប្រួលអាកាសធាតុ ដោយសារតែមិនអាចព្យាករណ៍ពីអាកាសធាតុ, ខ្វះទិន្នន័យ និងមិនអាចកំណត់ពីភាពជោគជ័យនៃការប្រើប្រាស់បច្ចេកទេស និងការអនុវត្តថ្មីៗ

- ការចូលរួមរបស់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ និងអង្គាធរក្នុងស្រុកគឺជាផែនការនិងការអនុវត្តដែលប្រកបទៅដោយជោគជ័យមួយរបស់ CCA នៅថ្នាក់ក្នុងស្រុក។ ទោះបីជាយ៉ាងនេះក្តី

ភាពប្រុងប្រយ័ត្នត្រូវតែអនុវត្តន៍ដើម្បីទប់ស្កាត់បន្ទុកច្រើនទៅលើដៃគូពាក់ព័ន្ធថ្នាក់ស្រុក និងការបង្កើតតារាងផែនការ

- ការចូលរួមក្នុងការរៀបចំផែនការអាចបង្កើតការរំពឹងទុករបស់សហគមន៍នៅខាងក្រោយការបែងចែករបស់គម្រោង និងការយល់ដឹងពីអង្គាធរនៅក្នុងស្រុកគឺវាមានភាពពិបាកក្នុងការកាត់បន្ថយផលប៉ះពាលនៃឧស្ម័នផ្ទះកញ្ចក់

- គំនិតថ្មី រួមទាំងគោលគំនិតនិងកម្មវិធីដូចមាននៅក្នុង PBCRG ទាមទារការគាំទ្រគោលនយោបាយរយៈពេលវែង។ ដើម្បីសម្រួលក្នុងរឿងនេះយន្តការស្ថាប័ន និងការគ្រប់គ្រងធនធានចំណេះដឹងតម្រូវអោយដាក់បញ្ចូលភស្តុតាងខាងក្រៅនៅក្នុងដំណើរការនៃការបង្កើតគោលនយោបាយ

## ករណីសិក្សាទី៣៖ បច្ចេកវិទ្យាកសិកម្មសមស្របត្រូវបានអនុវត្តន៍សាកល្បងនៅក្នុងខេត្តព្រៃវែង



សេចក្តីណែនាំពីប្រសិទ្ធភាពនៃបច្ចេកវិទ្យាកសិកម្ម និងការប្រើប្រាស់ពូជដែលសមស្របអាចជួយអោយប្រជាជនបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្នគម្រោងផ្តល់ជំនួយរបស់ CCCA កំពុងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយកសិករដើម្បីធ្វើការសាកល្បងពីពូជនៅក្នុងខេត្តព្រៃវែង ដែលជាតំបន់ដែលគេបានទទួលស្គាល់ថាជាតំបន់ដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជាភាពរាំងស្ងួតមានរយៈពេលវែង និងទឹកជំនន់។

គម្រោងដែលមានឈ្មោះថា “BUILD-FARM-ADAPT” គឺបានអនុវត្តន៍ដោយសាកលវិទ្យាល័យភូមិន្ទកសិកម្ម សហការជាមួយនិងសាកលវិទ្យាល័យជាស៊ីមកំចាយមារ កំពុងធ្វើការសាកល្បងទៅលើវិធីសាស្ត្រខាងលើនៅក្នុងស្រុកចំនួនបីនៅក្នុងខេត្តព្រៃវែង រួមមាន ស្រុកបាភ្នំ ស្រុកកំចាយមារ និងស្រុកពារាំង។ ពូជស្រូវចំនួនពីរ មានពូជស្រូវ ជលសា និងរាំងជ័យ រួមទាំងការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មទំនើបត្រូវបានណែនាំទៅកសិករដើម្បីបង្កើនទិន្នផល កាត់បន្ថយកត្តាចង្រៃនិងការប្រើប្រាស់ជីគីមី។

ពូជស្រូវជលសា និងរាំងជ័យគឺជាពូជស្រូវដែលស្ថិតនៅក្នុងចំនោមពូជទាំងដប់ដែលរដ្ឋាភិបាលជំរុញអោយកសិករប្រើ។ ជលសាគឺជាពូជស្រូវដែលមានរយៈពេលលូតលាស់ខ្លីដែលអាចប្រមូលផលបានក្នុងរយៈពេលតិចជាង ៩០ថ្ងៃ ហើយកសិករអាចដាំប្រជេញទឹកបាន មុនពេលទឹកលិច និងក្រោយពេលទឹកស្រក។ រាំងជ័យគឺជាពូជស្រូវដែលមានរយៈពេលលូតលាស់វែង ហើយធន់ទ្រាំទៅនិងភាពរាំងស្ងួត ដូចនេះវាអាចដាំបាននៅតំបន់ដែលមានរាំងស្ងួតរយៈពេលយូរ។ ហើយវាក៏អាចធន់ទ្រាំទៅនឹងទឹកលិចបានរយៈពេល ៧ថ្ងៃផងដែរ។

ស្រែបង្ហាញចំនួន ៣កន្លែង ទទួលបានការជោគជ័យ។ វាពិតជាគួរអោយចាប់អារម្មណ៍ណាស់ដែលបានឃើញកសិករព្រមទទួលយកនូវបច្ចេកទេស និងពូជថ្មីដែលបានណែនាំ។ លោក គឿន អេរីរេអឺត ប្រតិភូរបស់សហភាព អឺរ៉ុបប្រចាំនៅកម្ពុជា បាននិយាយថា "ជាទូទៅកសិករមានការស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូរពូជប្រពៃណីរបស់ពួកគេប៉ុន្តែពូជទាំងនេះកសិករនៅតែចាប់អារម្មណ៍ចង់ប្រើ"។

អ្នកទទួលផលពីការធ្វើស្រែបង្ហាញម្នាក់របស់ CCCA នៅក្នុងស្រុកពារាំង ខេត្តព្រៃវែងបានលើកឡើងថា " ខ្ញុំសូមអរគុណដល់ CCCA ដែលបានណែនាំពូជស្រូវជលសាដល់ភូមខ្ញុំ ហើយជួយពួកយើងជាមួយជាមួយនិងបច្ចេកវិទ្យាកសិកម្ម។ ឥឡូវនេះយើងទទួលបានទិន្នផលខ្ពស់ ដែលប្រើប្រាស់ជីអស់តិចហើយអាចប្រមូលផលបានមុនពេលទឹកជំនន់។ ខ្ញុំសង្ឃឹមថា CCCA អាចពង្រីកពូជស្រូវនេះបានពេញទូទាំងភូមិរបស់ខ្ញុំតែម្តង"។

កសិករដែលរស់នៅជិតអ្នកទទួលផលមានចំណាប់អារម្មណ៍ទៅលើពូជទាំងនេះ ហើយបានស្នើរសុំអោយជួយចែករំលែកពូចដំណាំ និងបច្ចេកវិទ្យាអោយបានទូទាំងភូមិតែម្តង។ គម្រោងនេះបានកំណត់រួចជាស្រេចក្នុងកម្មវិធីកិច្ច។

ទោះជាយ៉ាងនេះក្តី កត្តារាំងដែលអ្នកទទួលផលកំពុងតែប្រឈមមុខគឺយន្តការទីផ្សារក្នុងតំបន់ដែលមិនទាន់មានការគាំទ្រពេញលេញនៅឡើយដល់ពូជថ្មីទាំងពីរនេះ(ការផ្គត់ផ្គង់ពូជ និងការចាប់អារម្មណ៍ពីអ្នកទិញពូជថ្មីនេះទាមទាអោយមានការអភិវឌ្ឍ)។

# ១៣. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក កម្ពុជាបានកំពុងត្រៀមខ្លួនរួចជាស្រេចចំពោះការប្រែប្រួលអាកាសធាតុ ដូចជាការរៀបចំស្ថាប័ន ធន្ធៈក្នុងការរៀបចំ និងការអភិវឌ្ឍគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរួមបញ្ចូលទាំង CCCSP CCAPs និងគោលការណ៍ណែនាំសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុចូលទៅថ្នាក់ក្រោមជាតិ។ កិច្ចខិតខំប្រឹងប្រែងសំខាន់ៗក្នុងការបន្សាំ បានកើនឡើងក្នុងបរិបទប្រទេសទាំងមូល រួមទាំងថវិកាមួយចំនួន ដែលបានមកពីដៃគូអភិវឌ្ឍន៍ និងថវិកាជាតិត្រូវបានចំណាយសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ពិសេសសម្រាប់ការបន្សាំ។ ដំណើរការអភិវឌ្ឍ NAP និងផែនទីចង្អុលបង្ហាញត្រូវបានបង្កើតឡើងសម្រាប់បង្កើតប្រភពមូលនិធិ ដើម្បីការអនុវត្ត CCAPs របស់គ្រប់វិស័យទាំងអស់របស់រដ្ឋាភិបាល។ ការកសាងសមត្ថភាព ការគ្រប់គ្រងបច្ចេកទេស ការតាមដានទិន្នន័យ ODA និងការកៀងគរមូលនិធិ នៅតែជាតម្រូវការអភិវឌ្ឍ ពីទីភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

# ១៤. អនុសាសន៍

តាមរយៈវិសាលភាពនៃការស្រាវជ្រាវ ទៅលើការតាមដានមូលនិធិបន្សាំ និងមូលនិធិជាតិសម្រាប់ការបន្សាំ អនុសាសន៍ជាច្រើនត្រូវបានផ្តល់ដូចខាងក្រោម:

- ការពង្រឹងសមត្ថភាពស្ថាប័នក្រសួងបរិស្ថាន និងក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព ដើម្បីធ្វើអោយប្រសើរឡើងនូវការសម្របសម្រួលមូលនិធិដែលទាក់ទងទៅនឹងសកម្មភាពNAP រួមបញ្ចូលទាំងការវាយតម្លៃសំណើមូលនិធិអាកាសធាតុបៃតង (GCF)។ ទំនាក់ទំនងរវាងការដំណើរការ NAP និងមូលនិធិអាកាសធាតុបៃតង (GCF) គឺមិនទាន់បានបង្កើតឡើងនៅឡើយទេ ស្របពេលដែលការវាយតម្លៃសំណើមូលនិធិអាកាសធាតុបៃតងផ្តលឱកាសល្អ ក្នុងការទទួលបានធនធានបន្ថែមសម្រាប់ការវាស់វែងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រសួងបរិស្ថានស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើមក្នុងការរៀបចំនីតិវិធីសម្រាប់ការសម្របសម្រួល និងការដាក់សំណើ រួមបញ្ចូលទាំងការងាររបស់ខ្លួន ជា NDA សម្រាប់មូលនិធិអាកាសធាតុបៃតង។ នៅពេលដែលក្រសួងបរិស្ថាន ត្រូវបានតែងតាំងជា NDA នឹងមិនទាន់មាននាយកដ្ឋាន រឺមន្ត្រីត្រូវបានតែងតាំងឡើយ ដោយសារតែនីតិវិធីនៃការស្នើសុំថវិកាមូលនិធិអាកាសធាតុបៃតង នៅមិនទាន់បង្កើតរួចរាល់នៅឡើយ ។ ដើម្បីទទួលបានមូលនិធិអាកាសធាតុបៃតង ដំណើរការនៃការជ្រើសរើសសម្រាប់គម្រោងមួយ រឺច្រើនរបស់ NIE គួរត្រូវបានបង្កើត ហើយ GSSD ថ្មី នឹងអាចជា NIE ប៉ុន្តែការប្រែក្លាយនេះនៅមិនទាន់បានកំណត់នៅឡើយទេ។ នៅដំណាក់កាលនៃការជ្រើសរើស ការពង្រឹងស្ថាប័នមានសារៈសំខាន់ ដើម្បីផ្តល់ការទទួលស្គាល់ ក្នុងការបំពេញតម្រូវការផ្សេងៗ។
- ពង្រឹងសមត្ថភាពក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការតាមដាន និងវាយតម្លៃឥទ្ធិពលនៃការ

ប្រែប្រួលអាកាសធាតុទៅលើសេដ្ឋកិច្ច ហើយនឹងប្រើប្រាស់សមត្ថភាពនោះក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈដំណើរការនៃថវិកាជាតិ។

- ការប្រែប្រួលអាកាសធាតុមិនទាន់បានរួមបញ្ចូលយ៉ាងពេញលេញទៅក្នុងផែនការអភិវឌ្ឍ និងថវិកានៅថ្នាក់ជាតិ តាមវិស័យ និងថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ រួមមានសូចនាករជាក់លាក់មួយចំនួននៃការប្រែប្រួលអាកាសធាតុរួចទៅហើយ។ ក្រសួងផែនការមានតួនាទីក្នុងការបូកសរុប និងតាមដានផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ ផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ២០១៤-២០២៣ ត្រូវបានបង្កើត។ ក្រសួងពាក់ព័ន្ធមួយចំនួនបានបង្កើតផែនការសកម្មភាពវិស័យជាក់លាក់ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ (CCAP)។ ទោះជាយ៉ាងណា ក្រសួងមួយចំនួន មិនទាន់ត្រូវបានបញ្ជ្រាបចូលទៅក្នុងវិស័យយុទ្ធសាស្រ្តនៅឡើយទេ (ដោយមានករណីលើកលែងមួយចំនួនដូចជាយុទ្ធសាស្រ្តជាតិយេនឌ័ររបស់ក្រសួងកិច្ចការនារី) ដែលជាមូលដ្ឋានសម្រាប់ធ្វើផែនការក្រសួងពាក់ព័ន្ធ និងសម្រាប់ការបែងចែកថវិកាផងដែរ។ មានការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគម្រោង និងដំណើរការថវិកាថ្នាក់ខេត្ត។ មានគោលការណ៍ណែនាំសម្រាប់ឃុំនិងមានសកម្មភាពសាកល្បងដែលកំពុងបន្តនៅបណ្តាខេត្តមួយចំនួន។ ទោះជាយ៉ាងណាសកម្មភាពវិមជ្ឈការ និងវិសហមជ្ឈការ នៅតែស្ថិតក្នុងដំណាក់កាលដំបូង និងការខំប្រឹងប្រែងជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីរួមបញ្ចូលទិដ្ឋភាពនៃការប្រែប្រួលអាកាសធាតុជាទូលំទូលាយនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការធ្វើផែនការនិងថវិកា
- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងថវិកាជាតិដោយសារតែកង្វះការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ និងថវិកា លើសពីនេះទៅទៀតមិនទាន់មានវិធីសាស្រ្តជាក់លាក់សម្រាប់ក្រសួងក្នុងការស្នើការបែងចែកថវិកាឡើងវិញពីថវិកាជាតិ សម្រាប់វាស់វែងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ម្យ៉ាងវិញទៀតក៏មិនមានវិធីសាស្រ្តសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រឺក៏ក្រសួងបរិស្ថាន ដើម្បីតាមដានការអនុវត្តការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការសាកល្បងត្រូវបានគ្រោងទុកសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសាធារណៈការ និងដឹកជញ្ជូន។
- ការផ្លាស់ប្តូរ និងការកែតម្រូវទិន្នន័យ ODA លើមូលនិធិបន្សាំ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) មានតួនាទីយ៉ាងសំខាន់ក្នុងការតាមដានកត់ត្រានូវរាល់គម្រោងវិនិយោគនៅកម្ពុជា ការចាប់យកទិន្នន័យការប្រែប្រួលអាកាសធាតុ អាចរួមបញ្ចូលមុខងារមួយដើម្បីធ្វើការចង្អុលបង្ហាញ ក្នុងករណីគម្រោងត្រូវបានអនុវត្តន៍ដោយភ្នាក់ងារច្រើន។ នេះនឹងធ្វើឱ្យការប៉ាន់ស្មាននៃការចំណាយក្នុងក្រសួងមានលក្ខណៈកាន់តែប្រសើរ។ ការវិភាគ នៃវិស័យនេះ និងអនុវិស័យ ដែលបានប្រើក្នុងមូលដ្ឋានទិន្នន័យ CDC នឹងអាចផ្ទៀងផ្ទាត់ CPER ជាមួយនឹងសកម្មភាព និងស្នើឱ្យមានភាពប្រសើរឡើងនូវសក្តានុពលមួយចំនួន។
- ការតាមដានការប្រែប្រួលអាកាសធាតុក្នុងប្រព័ន្ធព័ត៌មានការគ្រប់គ្រងហិរញ្ញវត្ថុ៖ បច្ចុប្បន្នប្រព័ន្ធ

កំពុងត្រូវបានអភិវឌ្ឍន៍ និងសាកល្បង ដែលនឹងគាំទ្រដល់ការចាត់ថ្នាក់ផ្សេងៗរាប់ពីផែនការ ទៅដល់ការប្រតិបត្តិ នៅពេលអនាគត ប្រព័ន្ធគួររួមបញ្ចូលអន្តរបញ្ហាដូចជាការប្រែប្រួលអាកាសធាតុ ដែលនឹងងាយស្រួលសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការតាមដានការវិនិយោគ ខណៈពេលដែលប្រព័ន្ធបែបនេះបានបង្កើតរួចមកហើយ នៅប្រទេសមួយចំនួនដូចជាឥណ្ឌូនេស៊ី ហ្វីលីពីន និងនេប៉ាល់។

- ផ្តល់ហិរញ្ញវត្ថុទាក់ទងនឹងការប្រែប្រួលអាកាសធាតុបន្ថែម ស្របតាមការប្តេជ្ញាចិត្តរបស់ UNFCCC ប៉ុន្តែត្រូវធានាថាទិន្នន័យគម្រោង ODA គឺ "កម្មវិធី វៃឆ្លាតអាកាសធាតុ"
- សម្រាប់គម្រោងដែលបានកំណត់ថាពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវធានាថានៅក្នុងដំណាក់កាលបង្កើតគម្រោងគួរមានការផ្តល់ធាតុចូលពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ឬពីក្រុមការងារការប្រែប្រួលអាកាសធាតុរបស់ក្រសួង រួមបញ្ចូលទាំងបទដ្ឋាន ចំណាយ និងធាតុចូលផ្សេងៗ
- ការគាំទ្រតាមវិស័យ ឬថវិកាគាំទ្រទូទៅត្រូវរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងក្របខ័ណ្ឌលទ្ធផល (ស្របតាម CCCSP និងក្របខ័ណ្ឌការតាមដាន និងវាយតម្លៃសម្រាប់គម្រោងការប្រែប្រួលអាកាសធាតុ) ព្រមទាំងផ្តល់នូវហិរញ្ញវត្ថុអាកាសធាតុ ដើម្បីគាំទ្រទៅដល់គោលបំនងទាំងនេះ
- បង្កើនថវិកាសម្រាប់ការប្រែប្រួលអាកាសធាតុទៅដល់ថ្នាក់មូលដ្ឋានតាមរយៈ CSF, DMF និង SNIF, ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងនីតិវិធីនៃការធ្វើផែនការ និងថវិកាសម្រាប់គម្រោងទាំងនេះ
- បញ្ចូលការគាំទ្រការអភិវឌ្ឍសមត្ថភាព និងការអន្តរាគមន៍ទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ ដល់មន្ត្រី និងស្ថាប័ន (កំនត់បទដ្ឋាន ក្បួនច្បាប់ នីតិវិធី ការស្រាវជ្រាវ និងការអភិវឌ្ឍ)។

# ឯកសារយោង


1. ADB (2015); Climate Investment Fund/SPCR Programme
2. GSSD-MoE. (2015). Climate Change Finance Framework (CCFF), Cambodia
3. GSSD-MoE. (2016). Climate Public Expenditure Review update 2009-2014
4. GSSD-MoE. (2015). *Cambodia's Second National Communication under the United Nations Framework Convention on Climate Change.* Kingdom of Cambodia.
5. GIZ-USAID, (2016). Costing for National Adaptation Plan
6. MoE (2006), Natioal Adaptation Programme in Action on climate change
7. MoE (2013), Third National Climate Change Forum Report
8. MoE and CDRI (2015). Public perspective on climate change
9. MME. (2013). *National Policy, Strategy and Action Plan on Energy Efficiency in Cambodia (draft).*
10. Ministry of Information (2015) Climate Change Action Plan for Ministry of Information (2015-2018). Cambodia
11. Ministry of Land Management, Urban Planning and Construction (2015) Climate Change Action (2015-2018). Cambodia
12. Ministry of Tourism (2015) Climate Change Action Plan in Tourism Sector (2015-2018). Cambodia
13. Ministry of Environment (2014) Climate Change Action Plan (2014-2018). Cambodia
14. Ministry of Health (2014) National Climate Change Action Plan for Public Health (2014-2018). Cambodia
15. Ministry of Women's Affairs (2014) Gender and Climate Change Action Plan (2014-2018). Cambodia
16. Ministry of Education, Youth and Sports (2014) Climate Change Action Plan for Education (2014-2018). Cambodia
17. Ministry of Public Works and Transport (2014) Climate Change Action Plan for Transport Sector (2014-2018). Cambodia
18. RGC (2014) Climate Change Action Plan for Manufacturing Industry and Energy sectors (2014-2018). Cambodia
19. Ministry of Rural Development (2014) Climate Change Action Plan for Rural Development Sector (2014-2018). Cambodia

20. Ministry of Water Resources and Meteorology (2014) Climate Change Action Plan for Water Resources and Meteorology (2015-2018). Cambodia
21. National Disaster Management Committee (2014) Climate Change Action Plan for Disaster Management (2014-2018). Cambodia
22. National Institute of Statistics - Ministry of Planning. (2007). *Cambodia Socio-economic Survey.*
23. National Institute of Statistics. (2014). *Cambodia Socio-economic Survey.*
24. NGOF, (2013). Climate Change Financing in Cambodia
25. ODI. (2012). *Cambodia Climate Public Expenditure and Institutional Review.*
26. OECD-DAC. (2011). *Climate Markers.*
27. UNDP, CFADE (2015) A methodological Guidebook on Climate Public Expenditure and Institutional Review (CPEIR).
28. UNDP, CFADE (2015) Draft Paper: Climate Change Tagging. The Case Studies of Bangladesh, Indonesia, Nepal and the Philippines.
29. RGC (2013) Cambodia Climate Change Strategic Plan 2014-2023. National Climate Change Committee, Cambodia
30. RGC (2014) National Strategic Development Plan (2014-2018). Cambodia

Website

1. AF (2016) https://www.adaptation-fund.org/about/
2. CRDB/CDC database: climate finance under UNFCCC mechanism; http://odacambodia.com/Reports/reports_by_updated.asp? $status=0
3. DCC/GSSD (2016): Sectoral CCAPs and Strategic plans; http://www.camclimate.org.kh/ en/documents-and-media/library.html
4. MEF (2016): Budget Briefing 2016; http://www.mef.gov.kh/budget-in-brief.html
5. NCDD-S (2016): mainstreaming climate change into sub national planning; http://www.ncdd.gov.kh/km/media-center/13-latest-news/3689-integrate_ climate _ changein_to_cip
6. CFU (2016); Briefing all climate financing flow and trend; http://www.climatefundsupdate.org/
7. UNFCCC (2016); situation of climate financing in the world http://unfccc.int/focus/climate _finance/items/7001.php